ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2013, 17:01
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៨)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(28)

**នៅចំពោះមុខ៖** **ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម Agnieszka KLONOWIECKA-MILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទ៖** **ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣**
**ភាសា៖** **ខ្មែរ/អង់គ្លេស/បារាំង**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខឆ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី នួន ជា៖**
សុន អរុណ
Victor KOPPE

**ជនជាប់ចោទ÷**

ខៀវ សំផន

នួន ជា

**មេធាវីការពារក្តី ខៀវ សំផន÷**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី÷**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល "បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២" ដែលបានដាក់នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")[1] និង"បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងដីកាសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី" ដែលបានដាក់ដោយ នួន ជា នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខរបស់ នួន ជា" និង "សារណាតបរបស់ នួន ជា")[2]។

## I. សេចក្តីផ្តើម

2. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និង បណ្តឹងសាទុក្ខរបស់ នួន ជា (ហៅរួមថា "បណ្តឹងសាទុក្ខ") ពាក់ព័ន្ធនឹងសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានចេញផ្ទាល់មាត់នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដែលមានសំអាងហេតុជាលាយលក្ខណ៍អក្សរត្រូវបានដាក់នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ដើម្បីបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងបច្ចុប្បន្ន ("សំណុំរឿង ០០២") ជាសវនាការដាច់ដោយឡែកពីគ្នា ("សេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២") និងដើម្បីកម្រិតវិសាលភាពនៃសវនាការលើកទីមួយ ("សំណុំរឿង ០០២/០១) មកត្រឹមតែបទចោទមួយចំនួន[3]។ សេចក្តីសម្រេចដែលរងការជំទាស់នេះចេញ បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលបានប្រកាសថាសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីស្រដៀងគ្នានេះលើសំណុំរឿង ០០២ ពុំមានសុពល

---

[1] ឯកសារ E284/2/1។

[2] ឯកសារ E284/4/1។

[3] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ E1/176.1, ទំព័រ ១ ដល់ ៤; សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចដែលរងការជំទាស់")។

ភាព ("សេចក្តីសម្រេចលើកទីមួយ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២" និង "សេចក្តីសម្រេចរបស់ អ.ជ.ត.ក")[4]។

## ក. សាវតារ

3. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដោយចោទប្រកាន់ នួន ជា និង ខៀវ សំផន (ហៅរួមថា "សហជនជាប់ចោទ") ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពានបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និងដោយបានបង្ហាញការចោទប្រកាន់លើអង្គហេតុដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេច ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[5]។ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ជាបន្តបន្ទាប់ អង្គបុរេជំនុំជម្រះបានដំកល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមានការកែប្រែចំណុចមួយចំនួន[6]។ អនុលោមតាមវិធាន ៧៩ និង ៨០ *ស្ទួន* នៃវិធាន

---

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ឯកសារ E163/5/1/13, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[5] ដីកាដំណោះស្រាយ, ឯកសារ D427, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ និង បានដាក់នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ")។ អៀង ធីរិទ្ធ និង អៀង សារី ក៏ត្រូវបានចោទប្រកាន់រួមគ្នាជាមួយសហជនជាប់ចោទដែរ។ បទចោទនានាប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបានបំបែកចេញ និង កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ត្រូវបានផ្អាក ដោយសារមានការសន្និដ្ឋានថា គាត់ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ។ *សូមមើល* សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារ E138/1/10, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២; សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ, ឯកសារ E138, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។ កិច្ចដំណើរការនីតិវិធីប្រឆាំង អៀង សារី ត្រូវបានបញ្ចប់បន្ទាប់ពីគាត់បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។ *សូមមើល* សេចក្តីសម្រេចលើការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី, ឯកសារ E270/1, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។ *សូមមើល ផងដែរ* សេចក្តីសម្រេចលើសណ្តឹងសាទុក្ខភ្លាមៗ*ក្រោយមរណភាព*របស់ អៀង សារី, ឯកសារ E238/9/1/5, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៣។

[6] *សូមមើល* សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/1/30, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/2/15 *និង* ឯកសារ D427/3/15, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយៈ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន, ឯកសារ D427/1/27, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយៈ សំអាងហេតុសម្រាប់ការបន្តការឃុំខ្លួនបណ្តោះអាសន្ន, ឯកសារ D427/2/13 *និង* ឯកសារ D427/3/13, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/4/15, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១; សាល

ផ្ទៃក្នុង[7] អង្គជំនុំជម្រះសាលាដំបូងបានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានរៀបចំសវនាការបឋមពីថ្ងៃទី ២៧ ដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១[8]។ នៅឯសវនាការបឋមនោះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសនូវលំដាប់លំដោយនៃកិច្ចដំណើរការដែលខ្លួននឹងត្រូវធ្វើ នៅក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២[9]។

4. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ដោយអនុវត្តតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ជាលើកដំបូង ទៅជាសវនាការតូចៗដាច់ដោយឡែកពីគ្នា ដែលសវនាការនីមួយមានផ្នែកជាក់លាក់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសវនាការនេះនីមួយៗ នឹងត្រូវបញ្ចប់ពេញលេញដោយមានសាលក្រម និងការសម្រេចផ្តន្ទាទោស នៅពេលដែលមានការសម្រេចពីពិរុទ្ធភាព("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ")[10]។ ពាក់ព័ន្ធនឹងសវនាការលើកទីមួយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា វិសាលភាពនៃសវនាការលើកទីមួយនេះ គឺកម្រិតត្រឹម៖ ប្រវត្តិ និងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់សហជនជាប់ចោទ មុនពេល និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពេលវេលាពួកគេទទួលការចាត់តាំងឲ្យបំពេញតួនាទី ការទទួលខុសត្រូវរបស់ពួកគេ និងវិសាលភាពនៃសិទ្ធិអំណាចរបស់ពួកគេ បណ្តាញនៃការទំនាក់ទំនង ការផ្លាស់ទីលំនៅប្រជាជនចេញពីក្រុងភ្នំពេញនៅឆ្នាំ ១៩៧៥ ("ដំណាក់កាលទី ១") ការផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្តាល (ឧត្តរចាស់) បស្ចិម និងបូព៌ា ពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ ("ដំណាក់កាលទី

---

ដីកាលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ, ឯកសារ D427/5/10, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/1/26, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/2/12, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ឯកសារ D427/4/14, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១; សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ, ឯកសារ D427/5/9, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

[7] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក, វិសោធនកម្មលើកទី ៨, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។

[8] *សូមមើល* ប្រតិចារឹក, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E1/4.1, ប្រតិចារឹក, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E1/5.1, ប្រតិចារឹក, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E1/6.1, *និង* ប្រតិចារឹក, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E1/7.1 (រួមគ្នាហៅថា "សវនាការបឋម")។

[9] *សូមមើល* ប្រតិចារឹក, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E1/4.1, ទំព័រ ៧ ដល់ ៨។

[10] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ឯកសារ E124, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

២”) និង បទឧក្រិដ្ឋទាំង៥ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយមូលហេតុសាសនា) ការជម្លៀសដោយបង្ខំ និង ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ) ប៉ុន្តែបញ្ហាទាំងអស់នេះ ពាក់ព័ន្ធត្រឹមតែដំណាក់កាលទី ១ និង ទី ២ ប៉ុណ្ណោះ[11]។ អង្គជំនុំជម្រះសាលាដំបូងក៏បានចង្អុលបង្ហាញផងដែរថា៖

> អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬ អង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី ៣ នឹងមិនត្រូវបានលើកយកមកជម្រះនៅក្នុងការជំនុំជម្រះលើកដំបូងនេះទេ។ លើសពីនេះទៀត *បទចោទប្រកាន់ទាំងអស់ ដូចជា* បទប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ត្រូវទុក ដើម្បីលើកយកមកជម្រះនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀត នៅក្នុងសំណុំរឿង ០០២[12]។

5. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានជំទាស់ថា ខ្លួនពុំត្រូវបានអញ្ជើញឱ្យដាក់សេចក្តីសន្និដ្ឋានទៅលើខ្លឹមសារនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ មុនពេលចេញដីកានេះ[13] ហើយបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ និងកែប្រែដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយត្រង់កន្លែងថា វិសាលភាពនៃការជំនុំជម្រះលើកទី ១ ត្រូវបញ្ចូលដំណាក់កាលទី ១ ប៉ុន្តែពុំត្រូវបញ្ចូលដំណាក់កាលទី ២ ហើយ ដាក់បន្ថែមនូវទីតាំងឧក្រិដ្ឋកម្ម ៩ កន្លែងដូចជា៖ ទីតាំងសម្លាប់មនុស្សនៅស្រុក ១២ និងទួលពោធិ៍ជ្រៃ, មន្ទីរសន្តិសុខ ស-២១ ដែលរួមបញ្ចូលការបោះសំអាត

---

[11] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ, កថាខណ្ឌ ១ និង ៥។

[12] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ, កថាខណ្ឌ ៧។

[13] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញទៅលើ “ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩*ស្ទួនពីរ*”), ឯកសារ E124/2, ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ (“សំណើសុំឱ្យពិចារណាឡើងវិញ”), កថាខណ្ឌ ២, ៧ ១៤ ដល់ ១៦, ២០ ដល់ ២៣។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញលើពាក្យ “ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង”, ឯកសារ E124/1, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ (“សេចក្តីជូនដំណឹងពីសំណើសុំឱ្យពិចារណាឡើងវិញ”), កថាខណ្ឌ ៤(ខ)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានជំទាស់ទៅនឹងការណ៍ដែលមិនបានទទួលដំណឹងអំពីខ្លឹមសារនៃសេចក្តីសម្រេចបំបែកសំណុំរឿងលើកទីមួយ ហើយក៏បានស្នើសុំឱ្យការពិចារណាឡើងវិញស្រដៀងគ្នាដែរ។ *សូមមើល* សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យពិចារណាឡើងវិញនូវខ្លឹមសារក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលេខ E124, ឯកសារ E124/8, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ (“សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យពិចារណាឡើងវិញ”)។ *សូមមើលផងដែរ* ការជូនដំណឹងអំពីសំណើរបស់សហមេធាវីនាំមុខស្នើសុំពិចារណាឡើងវិញចំពោះការសម្រេចនៅក្នុងដីកាបំបែកនីតិវិធី អនុលោនតាមវិធាន ៨៩*ស្ទួនពីរ*, ឯកសារ E124/4, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១ (“សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យពិចារណាឡើងវិញ”)។

កម្មាភិបាលមកពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្តាល (ឧត្តរចាស់) និង ភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១, ប៉ុន្តែពុំបានរួមបញ្ចូលការដ្ឋានព្រៃ ស, ភូមិភាគឧត្តរ, មន្ទីរសន្តិសុខក្រាំងតាចាន់ និងអូរកន្សែង, ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង និងសហករណ៍នៅត្រាំកក់[14]។ សហព្រះរាជអាជ្ញាបានលើកជាទឡ្ហីករណ៍ថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយពុំបានបម្រើផលប្រយោជន៍យុត្តិធម៌ទេ ដោយសារបទចោទដែលបានជ្រើសរើសសម្រាប់ការជំនុំជម្រះលើកទីមួយ ដែលខ្លួនជំទាស់ថា ទំនងជាសវនាការតែមួយគត់ក្នុងសំណុំរឿង ០០២[15] ពុំមែនជាតំណាងឱ្យការប្រព្រឹត្តដែលជាបទឧក្រិដ្ឋរបស់សហជនជាប់ចោទដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ[16] ហើយពុំបានលើកកម្ពស់ដល់កំណត់ត្រាជាប្រវត្តិសាស្ត្រមួយដ៏សុក្រឹតទេ[17] និងធ្វើឱ្យថយចុះនូវតម្លៃនៃកេរតំណែលរបស់ អ.វ.ត.ក ក្នុងដំណើរឆ្ពោះទៅរកការផ្សះផ្សារជាតិ[18]។ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំឱ្យពិចារណាឡើងវិញនោះទាំងស្រុង[19]។

6. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពង្រីកវិសាលភាពនៃការជំនុំជម្រះលើកទីមួយ ដោយបន្ថែមទីតាំងឧក្រិដ្ឋកម្ម ៣ កន្លែងក្នុងចំណោមទាំង ៩

[14] សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ១, ៣៦, ៤២ ដល់ ៤៣។ សហព្រះរាជអាជ្ញាក៏បានស្នើសុំ ជាជម្រើសម្យ៉ាងទៀតថា អង្គជំនុំជម្រះសាលាដំបូង "ស្តាប់សក្ខីកម្មសាក្សី ទោះបីជាលាយលក្ខណ៍អក្សរក្តី ឬដោយផ្ទាល់មាត់ក្តី ទៅលើទម្រង់ផ្សេងៗទៀតនៃការបំបែកសំណុំរឿង ០០២"។ *សូមមើល* សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៤៥(២)។ *សូមមើលផងដែរ* សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ១។

[15] សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៣, ១៥, ២៤ ដល់ ២៧, ២៩ ដល់ ៣០, ៣៦។

[16] សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៣, ១៨ ដល់ ១៩, ២១ ដល់ ២៤, ២៩ ដល់ ៣២, ៣៦, ៤៤។ *សូមមើល ផងដែរ* សេចក្តីជូនដំណឹងពីសំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៤(ក)។

[17] សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៣, ៣២ ដល់ ៣៤។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងពីសំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៤(ក)។

[18] សំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៣, ៣២, ៣៤។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងពីសំណើសុំឱ្យពិចារណាឡើងវិញ, កថាខណ្ឌ ៤(ក)។

[19] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ឯកសារ E124/7, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ")។

កន្លែងដែលបានស្នើសុំពីមុន រួមមានទីតាំងសម្លាប់មនុស្សនៅស្រុក ១២ (“ស្រុក ១២”)[20] ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ (“ទួលពោធិ៍ជ្រៃ”)[21] និងមន្ទីរសន្តិសុខ ស-២១ (រួមជាមួយនឹងទីតាំងសម្លាប់មនុស្សនៅជើងឯកដែលពាក់ព័ន្ធផងដែរ) ដោយរួមទាំងការសម្រិតសម្រាំងកម្មាភិបាលពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្តាល (ឧត្តរចាស់) និង ភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ តែមិនបានបញ្ចូលការដ្ឋាននៅព្រៃសទេ (“មន្ទីរ ស-២១”)[22]។ នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា ខ្លួនមានបំណងពង្រីកវិសាលភាពនៃការជំនុំជម្រះលើកទីមួយ ទៅតាមសំណើរបស់សហព្រះរាជអាជ្ញា និងបានអញ្ជើញភាគីឱ្យដាក់សារណាលើបញ្ហានេះនៅឯកិច្ចប្រជុំរៀបចំសវនាការនាពេលបន្ទាប់[23] ដែលបានរៀបចំធ្វើនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២[24]។

7. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំពង្រីកវិសាលភាពពាក់ព័ន្ធនឹងស្រុក ១២ និងមន្ទីរ ស-២១[25] តែបានទទួលយកសំណើសុំបញ្ចូលទួលពោធិ៍ជ្រៃ “ដោយសារ

[20] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១, ឯកសារ E163, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ (“សំណើសុំពង្រីកវិសាលភាព”), កថាខណ្ឌ ៤(ក), ៣៣(ក), *យោងលើ* ដីកាដំណោះស្រាយ, កថាខណ្ឌ ៦៩១, ៦៩៣ ដល់ ៦៩៧។

[21] សំណើសុំពង្រីកវិសាលភាព, កថាខណ្ឌ ៤(ខ), ៣៣(ខ), *ដោយយោងទៅលើ* ដីកាដំណោះស្រាយ, កថាខណ្ឌ ៦៩៨ ដល់ ៧១១។

[22] សំណើសុំពង្រីកវិសាលភាព, កថាខណ្ឌ ៤(គ), ៣៣(គ), *ដោយយោងទៅលើ* ដីកាដំណោះស្រាយ, កថាខណ្ឌ ១៩២ ដល់ ២០៤, ៤១៥ ដល់ ៤៧៥។

[23] អនុស្សរណៈពីលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា “ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ”, ឯកសារ E218, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ (“អនុស្សរណៈចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២”), កថាខណ្ឌ ១៣ ដល់ ១៥។ *សូមមើលផងដែរ* អនុស្សរណៈពីលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា “សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)”, ឯកសារ E218.1, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ (“ឧបសម្ព័ន្ធនៃ អនុស្សរណៈចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២”)។

[24] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E1/114.1 (“កិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២”)។

[25] អនុស្សរណៈពីលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា “សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និង ពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញ

ការកាប់សម្លាប់មនុស្សទាំងនេះ [...] បានកើតឡើងភ្លាមៗបន្ទាប់ពីមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ [...] តែពុំសំដៅដល់គ្របដណ្តប់លើការកាប់សម្លាប់នានាផ្សេងទៀតនៅទីតាំងនេះ ដែលបានកើតឡើងនៅចន្លោះពីឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៧៧ ឡើយ”[26]។ នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីលើការពង្រីកវិសាលភាព ដោយស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលបញ្ចូលស្រុក ១២ និងមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើកទីមួយ(“បណ្តឹងសាទុក្ខលើកទី ១ របស់សហព្រះរាជអាជ្ញាលើការបំបែកកិច្ចដំណើរការនីតិវិធី”)[27]។

8. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ក្នុងការបកស្រាយលើវិសាលភាពនៃឆន្ទានុសិទ្ធិរបស់ខ្លួន តាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដោយបដិសេធចោលនូវភាពចាំបាច់ ក្នុងការបង្ហាញសំអាងហេតុគ្រប់គ្រាន់អំពីផលប្រយោជន៍យុត្តិធម៌ ក្នុងការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ ដូចគ្នាដែរ បដិសេធនូវភាពចាំបាច់ក្នុងការស្តាប់ភាគីក្នុងសំណុំរឿង ០០២ ទៅលើលក្ខខណ្ឌនៃការបំបែកកិច្ចដំណើរការនីតិវិធីនេះដែរ[28]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបកស្រាយវិធាន *៨៩ស្ទួនពីរ* នៃវិធានផ្ទៃក្នុង បានបណ្តាលឱ្យមានការរំលោភសិទ្ធិភាគី ក្នុងការទទួលបានការសម្រេចមួយដោយមានសំអាងហេតុ និងសិទ្ធិក្នុងការទទួលបានការស្តាប់ពីតុលាការ និងកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដែលធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិដទៃទៀត[29]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ទោះបីជាមានការបញ្ជាក់ នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយដែលថា “ព័ត៌មានបន្ថែមទាក់ទងនឹងរឿងក្តីបន្តបន្ទាប់ដែលត្រូវជំនុំជម្រះ ក្នុងសំណុំរឿង ០០២ នឹងត្រូវផ្តល់ឱ្យភាគីនិងសាធារណជនតាមពេលវេលាសមស្រប”,[30] ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់នូវព័ត៌មានជាក់លាក់ច្បាស់លាស់ណាមួយ ទាក់ទងនឹង ចំនួន វិសាលភាព ឬ អំឡុងពេល នៃការជំនុំជម្រះដែលបាន

---

ដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន”, ឯកសារ E163/5, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ (“សេចក្តីសម្រេចលើការពង្រីកវិសាលភាព”), កថាខណ្ឌ ២។

[26] សេចក្តីសម្រេចលើការពង្រីកវិសាលភាព, កថាខណ្ឌ ៣។

[27] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង “សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿង ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II)”, ឯកសារ E163/5/1/1, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[28] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៨។

[29] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៨។

[30] ដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយទំព័រ ៤។

ប្រមើលទុក បន្ទាប់ពីការជំនុំជម្រះលើកទីមួយរួច[31] ហើយថា ការខកខានក្នុងការបង្កើតផែនការទាក់ទងនឹងការដោះស្រាយលើបទចោទដែលនៅសេសសល់ ដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២ នោះ បណ្ដាលឱ្យមានការប៉ះពាល់ដល់សិទ្ធិផងដែរ[32]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អានុភាពនៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងស្ទួនៗនេះ បណ្ដាលឱ្យការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ អស់សុពលភាព ដែលរួមមាន ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ សេចក្ដីសម្រេចស្ដីពីការពិចារណាឡើងវិញ និងសេចក្ដីសម្រេចលើការពង្រីកវិសាលភាព រួមជាមួយនឹងអនុស្សរណៈនានាទាំងអស់ដែលពាក់ព័ន្ធ[33]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់ថា សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ពុំបានធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកសំណុំរឿង ០០២ ទេ ប៉ុន្តែ "ជាដំបូង អង្គជំនុំជម្រះត្រូវអញ្ជើញភាគីនានាដាក់សារណាលើលក្ខខណ្ឌនៃដីកានេះ ហើយនៅពេលដែលអត្ថប្រយោជន៍របស់ភាគី *ទាំងអស់* ត្រូវបានធ្វើឱ្យមានតុល្យភាពចំពោះកត្តាពាក់ព័ន្ធផ្សេងៗហើយនោះ ការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ អាចធ្វើទៅបានប្រកបដោយភាពត្រឹមត្រូវ"[34]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងក៏កំណត់កាលបរិច្ឆេទបើកសវនាការភ្លាម និងបានផ្ដល់បញ្ជីពិស្ដារលើបញ្ហាទាំង ៩ ដែលពាក់ព័ន្ធនឹងការបំបែកសំណុំរឿង ០០២ ឡើងវិញដែលមានសក្ដានុពល ដើម្បីឱ្យភាគីឆ្លើយតប[35] ដែលបានដាក់នៅថ្ងៃទី ១៨ និង ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣[36]។ បន្ទាប់ពីបានស្ដាប់សេចក្ដីសន្និដ្ឋាននៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ រួចមក អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយទៀតនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយស្នើសុំព័ត៌មានបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការលើកទីមួយដែលអាចមាន[37] ដែលភាគីបានផ្ដល់ឱ្យក្នុងអំឡុងពេលសវនាការបន្ថែមនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣[38]។

---

[31] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ២៣។

[32] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៨។

[33] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៩។

[34] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០ (សេចក្ដីបញ្ជាក់បន្ថែមពីឯកសារដើម)។

[35] អនុស្សរណៈពីលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការណែនាំដល់ភាគីនានាដោយសារតែមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13)", ឯកសារ E163/5/1/13/1, ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និង ដាក់នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[36] ប្រតិចារឹក, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E1/171.1; ប្រតិចារឹក, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E1/172.1។

[37] អនុស្សរណៈពីលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សំណួរបន្ថែមទៅភាគីក្រោយសវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខ

9. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសនៅក្នុងតុលាការថា អង្គជំនុំជម្រះបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ជាថ្មី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ហើយថា វិសាលភាពនៃសំណុំរឿង ០០២/០១ នឹងកំហិតត្រឹមតែបទចោទនានាដែលពាក់ព័ន្ធនឹងដំណាក់កាលទី ១ ដំណាក់កាលទី ២ និង ទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ[39]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុរបស់ខ្លួនជាលាយលក្ខណ៍អក្សរនៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

## ខ. បណ្តឹងសាទុក្ខ

10. នៅថ្ងៃទី ១០ និងទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា និង នួន ជា បានដាក់បណ្តឹងសាទុក្ខរបស់ខ្លួន ដោយលើកឡើងថា បណ្តឹងសាទុក្ខទាំងនោះ អាចទទួលយកបាន ហើយថា សេចក្តីសម្រេចដែលរងការជំទាស់មានកំហុសលើអង្គច្បាប់ អង្គហេតុ និងកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[40]។ ហេតុនេះ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការកែប្រែសេចក្តីសម្រេចដែលរងការជំទាស់ ដើម្បីបញ្ចូល មន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃ សំណុំរឿង ០០២/០១[41] ចំណែក នួន ជា ស្នើសុំឲ្យមោឃៈសេចក្តីសម្រេចដែលរងការជំទាស់ដោយប៉ះពាល់ដល់ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនាពេលអនាគត ឬ ជាជម្រើសម្យ៉ាងទៀត ដែលពាក់ព័ន្ធនឹងការពង្រីកវិសាលភាពនៃ សំណុំរឿង ០០២/០១ ដើម្បីបញ្ចូលបទចោទនានាដូចជាបទប្រល័យពូជសាសន៍ និងបទចោទនានាដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋាននានា[42]។

11. ចម្លើយតបរបស់ នួន ជា ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ដោយបញ្ចូលទៅក្នុងបណ្តឹងសាទុក្ខរបស់ នួន ជា[43] ដែលបានដាក់ជាសារណា

---

ភ្លាមៗរបស់ សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារ E163/5/1/13)", ឯកសារ E264, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[38] ប្រតិចារឹក, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ E1/173.1។

[39] ប្រតិចារឹក, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ E1/176.1, ទំព័រ ៤។

[40] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣, ១៥ ដល់ ៧៩; បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៧ ដល់ ៨៣។

[41] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៨៥។

[42] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៨៤។

[43] *សូមមើលខាងលើ*, កថាខណ្ឌ ១។

បន្ថែមនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣[44]។ សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតប និងដាក់សារណាតបស្រដៀងគ្នាដែរទៅលើបណ្តឹងសាទុក្ខ និងចម្លើយតបរបស់ នួន ជា ជាទម្រង់រួមគ្នាតែមួយនៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣[45]។ នួន ជា បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣[46] និងបានដាក់សារណាបន្ថែមនៅថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៣[47] ដែលសហព្រះរាជអាជ្ញាបានឆ្លើយតបវិញនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣[48]។ ខៀវ សំផន និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានដាក់សារណាអ្វីទេ។

## គ. សារណាបន្ថែម

12. នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាទទួលយកសារណាបន្ថែមទាំងពីររបស់ខ្លួន និងសុំឱ្យពិចារណាសារណាទាំងនោះរួមជាមួយនឹងបណ្តឹងសាទុក្ខរបស់ខ្លួន[49]។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធនូវសារណាបន្ថែមភ្ជាប់ទៅនឹងសារណាតបរបស់ នួន ជា ថា

---

[44] សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខភ្លាមប្រឆាំងនឹងសេចក្តីសម្រេចលើកទី ២ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, ឯកសារ E284/4/2, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ("សារណាបន្ថែមភ្ជាប់ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា")។

[45] សារណាតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់នឹងដីកាសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, ឯកសារ E284/4/3, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ("សារណាតបរបស់សហព្រះរាជអាជ្ញា" និង"ចម្លើយតបរបស់សហព្រះរាជអាជ្ញា" អាចជំនួសគ្នាបាន)។

[46] ចម្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនៃសំណុំរឿង ០០២, ឯកសារ E284/4/4, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ("ចម្លើយតបរបស់ នួន ជា")។

[47] សារណាបន្ថែមលើចម្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, ឯកសារ E284/4/5, ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៣ ("សារណាបន្ថែមលើចម្លើយតបរបស់ នួន ជា")។

[48] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹង"សារណាបន្ថែមរបស់ នួន ជា លើចម្លើយតបទៅនឹងសារណាតបរបស់ ក.ស.ព ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី", ឯកសារ E284/4/6, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ("សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមលើចម្លើយតបរបស់ នួន ជា")។

[49] សារណាបន្ថែមលើបណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៧; សារណាបន្ថែមលើចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ២៥។

"មិនទាន់ដល់ពេល មិនទាន់ទុំជោរ មិនពាក់ព័ន្ធ និងគ្មានខ្លឹមសារ"[50]។ ក្របខណ្ឌច្បាប់នៅ អ.វ.ត.ក មិនបាន ចែងជាក់លាក់ពីការដាក់សារណាបន្ថែម ឬសេចក្ដីសន្និដ្ឋានបន្ថែមណាក្រៅពីបណ្ដឹងសាទុក្ខ សារណាតប និងចម្លើយតបទេ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដំណើរការសម្រាប់ការ ទទួលយកសេចក្ដីសន្និដ្ឋានបន្ថែមជារឿងធម្មតានៅកម្រិតអន្តរជាតិ ដោយសារថា ការអនុញ្ញាតឲ្យទទួល យកឯកសារទាំងនេះត្រូវបានធ្វើឡើងជាមុន ឬជាមួយនឹងសារណាដែលបានដាក់[51]។ ជាងនេះទៀត វិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយ ណាដែលធ្វើក្រោយពីពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ ឃើញថាត្រឹមត្រូវសមហេតុផល។

13. ដោយផ្អែកលើមូលដ្ឋាននេះ និងពាក់ព័ន្ធនឹងភាពសំខាន់នៃបញ្ហាដែលកំពុងពិភាក្សាក្នុងបណ្ដឹងសាទុក្ខ ទាំងនេះផង អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វាជាប្រយោជន៍យុត្តិធម៌ដែលត្រូវទទួលយក សារណាបន្ថែមចំពោះបណ្ដឹងសាទុក្ខរបស់ នួន ជា, សារណាបន្ថែមចំពោះចម្លើយតបរបស់ នួន ជា និង ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមចំពោះចម្លើយតបរបស់ នួន ជា។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាទៅលើសេចក្ដីសន្និដ្ឋាននានា ដែលមាននៅក្នុងឯកសារទាំងនោះ។ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីនានាថា ការសុំការអនុញ្ញាតគួរធ្វើចំពោះអង្គជំនុំជម្រះដែលពាក់ព័ន្ធ នៅ ពេលដាក់សារណាបន្ថែម និងសារណាតប ឬ ចម្លើយតបណាមួយនាពេលខាងមុខ។

## ឃ. សេចក្ដីសន្និដ្ឋានផ្ទាល់មាត់

14. វិធាន ១០៩(១) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចធ្វើសេចក្ដីសម្រេចពិចារណាលើបណ្ដឹង សាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីតែ ប៉ុណ្ណោះ។ ដោយពិចារណាថា សារណាជាលាយលក្ខណ៍អក្សរពីភាគីជាការគ្រប់គ្រាន់ហើយនោះ អង្គជំនុំ

---

[50] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមលើចម្លើយតបរបស់ នួន ជា, កថាខណ្ឌ ៣។ *សូមមើលផងដែរ* កថាខណ្ឌ ១៥។

[51] *សូមមើល ក្នុងចំណោមនោះ* វិធាន ១១៣ នៃវិធាននីតិវិធី និងភស្តុតាងនៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL" និង "វិធាននៃតុលាការ SCSL") ("(ក) ម្ចាស់បណ្ដឹងឧទ្ធរណ៍អាចដាក់សេចក្ដីសន្និដ្ឋានឆ្លើយតបក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីអ្នកឆ្លើយតបបានដាក់សារណា។ (ខ) ពុំមានការដាក់សេចក្ដីសន្និដ្ឋានបន្ថែមទេ លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំ ជម្រះសាលាឧទ្ធរណ៍")។ *សូមមើលផងដែរ* វិធាន ៧២(ឆ) ("នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយោងទៅដល់សំណើមួយ ទៅសាលាឧទ្ធរណ៍ អនុលោមតាមអនុវិធាន (ង) ឬ (ច) ខាងលើ [នោះគឺសំណើបឋម] ភាគីដែលមានបំណងដាក់សេចក្ដីសន្និ ដ្ឋានបន្ថែមជាលាយលក្ខណ៍អក្សរត្រូវស្នើសុំការអនុញ្ញាតពីសាលាឧទ្ធរណ៍ ដែលនឹងកំណត់ពេលកំណត់សម្រាប់ដាក់សេចក្ដី សន្និដ្ឋានបន្ថែម ចម្លើយតប និងសារណាតប ប្រសិនបើផ្ដល់ការអនុញ្ញាត")។

ជម្រះតុលាការកំពូលយល់ថា ពុំចាំបាច់ត្រូវស្ដាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ក្នុងករណីនេះទេ ហើយសូមចេញសេចក្ដីសម្រេចតែម្ដង។

## II. បទដ្ឋាននៃការពិនិត្យលើបណ្ដឹងសាទុក្ខ

15. អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង មានតែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោមដែលត្រូវបើផ្លូវឱ្យប្ដឹងសាទុក្ខភ្លាមៗ៖ (ក).សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី (ខ).សេចក្ដីសម្រេចអំពីការឃុំខ្លួននិងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន ៨២ (គ).សេចក្ដីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) និង (ឃ).សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះតាមវិធាន ៣៥(៦)។ សេចក្ដីសម្រេចផ្សេងទៀត អាចប្ដឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដី។

16. អនុលោមតាមវិធាន ១០៤(១) និងវិធាន ១០៥(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ដោយផ្អែកលើមូលដ្ឋាននានាដូចតទៅ៖ (ក) កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ (ខ) កំហុសនៃអង្គហេតុ ដែលនាំឱ្យសាលក្រមលើអង្គសេចក្ដី ឬ សេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ (គ) កំហុសដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ។

## III. ភាពអាចទទួលយកបាន

17. សហព្រះរាជអាជ្ញា និង នួន ជា បានលើកឡើងថា បណ្ដឹងសាទុក្ខរបស់ខ្លួនត្រូវបានដាក់ទាន់ពេលវេលាអនុលោមតាមវិធាន ១០៧(១) នៃវិធានផ្ទៃក្នុង និងអាចទទួលយកបានអនុលោមតាមវិធាន ១០៤(៤)(ក) និង វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង[52]។

### ក. ភាពទាន់ពេលវេលា

18. វិធាន ១០៧(១) នៃវិធានផ្ទៃក្នុងចែងថា បណ្ដឹងសាទុក្ខភ្លាមៗត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។ វិធាន ៣៩(៣) នៃវិធានផ្ទៃក្នុងចែងថា ពេលវេលាកំណត់ត្រូវផុតរលត់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យជាតិរបស់កម្ពុជា ពេលវេលាកំណត់ត្រូវបន្តជាស្វ័យប្រវត្តិទៅថ្ងៃធ្វើការបន្ទាប់។ សេចក្ដីសម្រេចដែលរងការជំទាស់នេះ ត្រូវ

---

[52] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១, ៣, ១៥ ដល់ ១៩; បណ្ដឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៨។

បានដាក់ និងជូនដំណឹងនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ ១៤ ថ្ងៃក្រោយ គឺនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ហើយបណ្តឹងសាទុក្ខរបស់ នួន ជា ត្រូវបានដាក់ ៣១ ថ្ងៃក្រោយ គឺនៅថ្ងៃច័ន្ទ ទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣។ ភាពទាន់ពេលវេលានៃការដាក់បណ្តឹងសាទុក្ខទាំងនេះពុំមានចោទជាបញ្ហាទេ។

19. ហេតុនេះ បណ្តឹងសាទុក្ខត្រូវបានដាក់ទាន់ពេលវេលាតាមវិធាន ៣៩(៣) និង វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង។

## ខ. វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

20. សហព្រះរាជអាជ្ញាបានលើកឡើងថា សេចក្តីសម្រេចដែលរងការជំទាស់បានបញ្ចប់យ៉ាងមានប្រសិទ្ធភាពនូវការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ រួមមានការចាប់ខ្លួន ការឃុំឃាំង ការធ្វើទារុណកម្ម និង ការសម្លាប់ប្រជាជនកម្ពុជារាប់សែននាក់នៅតាមបណ្តាលមន្ទីរសន្តិសុខនានានៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[53]។ សហព្រះរាជអាជ្ញាបានអះអាងថា ការសម្រេចមិនបញ្ចូលមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃ សំណុំរឿង ០០២/០១ នាំឲ្យមាន "ការផ្អាកដល់កិច្ចដំណើរការនីតិវិធីទាក់ទិននឹងបទចោទប្រកាន់នានា ដែលពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មមន្ទីរ ស-២១ ដំណោះស្រាយអំពីរឿងនេះនៅក្នុងសាលក្រមលើអង្គសេចក្តីគឺគ្មានទេ ព្រោះនៅឆ្ងាយណាស់"[54]។ នួន ជា យល់ស្របជាមួយសហព្រះរាជអាជ្ញា តែបានចង្អុលបង្ហាញថា សេចក្តីសម្រេចដែលត្រូវបានជំទាស់ មិនត្រឹមតែមិនបានបញ្ចូលមន្ទីរ ស-២១ ទៅក្នុងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តប៉ុណ្ណោះទេ ថែមទាំងពុំបានបញ្ចូលនូវតុល្យភាពនៃដីកាដំណោះស្រាយទៀតផង[55]។ សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងភាពទទួលយកបាននៃបណ្តឹងសាទុក្ខរបស់ នួន ជា ទេ[56]។

21. អង្គជំនុំជម្រះតុលាការកំពូលរម្លឹកឡើងវិញថា សិទ្ធិប្តឹងសាទុក្ខដែលមានចែងក្នុងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងធានាថា ជម្រើសធ្វើបណ្តឹងសាទុក្ខអាចធ្វើទៅបាន នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយពុំបានចេញសាលក្រម បើពុំដូច្នេះទេ ភាគីពុំមានឱកាសក្នុងការប្តឹងសាទុក្ខជំទាស់ទៅ

---

[53] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១(ខ)។

[54] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៦ ដល់ ១៨។

[55] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៨។

[56] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២, ៥។

នឹងសាលក្រម[57]។ អង្គជំនុំជម្រះតុលាការកំពូលបានបកស្រាយវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដើម្បីបញ្ចូលសេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី ដែលមិនបានសន្យាច្បាស់លាស់ណាមួយនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ ដែលធ្វើឱ្យមានការរារាំងដល់ការចេញសាលក្រមលើអង្គសេចក្តី[58]។

22. ក្នុងការពិនិត្យទៅលើដីកាសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា សេចក្តីសម្រេចលើការពង្រីកវិសាលភាពដែលបដិសេធការបញ្ចូលមន្ទីរ ស-២១ និង ស្រុក ១២ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើកទីមួយនោះ មានអានុភាពនាំឱ្យបញ្ចប់នូវកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទទាំងនោះ[59] ហើយថា បណ្តឹងសាទុក្ខលើកទីមួយរបស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសេចក្តីសម្រេចលើការបំបែកនីតិវិធី អាចទទួលយកបានអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង[60]។ មូលដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបែបនេះគឺថា ដូចគ្នានឹងសេចក្តីសម្រេចដាក់លាក់ស្តីពីទម្រង់នៃការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ដែរ សេចក្តីសម្រេចលើការពង្រីកវិសាលភាព អាចធ្វើឱ្យផ្អាក*ជាក់ស្តែង* កិច្ចដំណើរការនីតិវិធីទាក់ទិននឹងបទចោទទាំងអស់ ដែលពុំស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះលើកទីមួយ ហើយថា ដោយផ្អែកតាមកាលៈទេសៈនាពេលបច្ចុប្បន្ន ការផ្អាកនេះពុំមានការសន្យាច្បាស់លាស់ណាមួយនៃការបន្តកិច្ចដំណើរការនីតិវិធីឡើងវិញ ដើម្បីអាចឈានទៅដល់ការចេញសាលក្រមលើអង្គសេចក្តីឡើយ[61]។

23. កាលៈទេសៈប្រែប្រួលដែលកើតមានឡើង នៅពេលមានសេចក្តីសម្រេចរបស់ អ.ជ.ត.ក មានដូចជា៖ អាយុកាន់តែច្រើន និងសុខភាពដុនដាបរបស់សហជនជាប់ចោទ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់ផែនការច្បាស់លាស់ ឬផ្តល់ព័ត៌មានណាមួយមកទល់ពេលនេះ ទាក់ទិននឹងរឿងក្តី

---

[57] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២២, *ដោយយោងទៅលើ*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឯកសារ E95/8/1/4, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២, កថាខណ្ឌ ៩។

[58] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២២, *ដោយយោងទៅដល់* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ឯកសារ E138/1/7, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ("សេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ"), កថាខណ្ឌ ១៥។

[59] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៥។

[60] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៦។

[61] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៥។

00964348



បន្តបន្ទាប់ដែលត្រូវជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ការលំបាកដែលអង្គជំនុំជម្រះបានលើកឡើងថ្មីៗនេះដើម្បីបំពេញទៅតាមតម្រូវការនៃបន្ទុកការងារ និងការពិតដែលថា នៅក្នុងបរិបទរបស់ អ.វ.ត.ក សាលក្រមលើអង្គសេចក្ដី ពុំទាន់ជាស្ថាពរនៅឡើយទេ ដរាបណាសាលក្រមនេះបានឆ្លងកាត់ដំណាក់កាលនៃការប្ដឹងសាទុក្ខ និងតាមទស្សនៈរបស់ភាគី និងអង្គជំនុំជម្រះសាលាដំបូងគឺថា ការជំនុំជម្រះលើកទីមួយ អាចជាសវនាការតែមួយគត់ ដែលឈានទៅដល់ការចេញសាលក្រមលើអង្គសេចក្ដីបាន[62]។

24. ពាក់ព័ន្ធនឹងការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្ដល់ផែនការច្បាស់លាស់ ឬផ្ដល់ព័ត៌មានណាមួយទាក់ទិននឹងរឿងក្ដីបន្តបន្ទាប់ ដែលត្រូវជំនុំជម្រះ បន្ទាប់ពីការជំនុំជម្រះលើកទីមួយរួចនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានភ្ជាប់ជាឧបសម្ព័ន្ធនូវអ្វីដែលហៅថា "ផែនការបណ្ដោះអាសន្នសម្រាប់ការជំនុំជម្រះនាពេលអនាគតក្នុងសំណុំរឿង ០០២"[63] ជាមួយនឹងសេចក្ដីសម្រេចដែលរងការជំទាស់នេះ[64]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជាក់លាក់ថា ខ្លួន "នៅមិនច្បាស់អំពីការព្យាករណ៍ទៅលើការជំនុំជម្រះនាពេលអនាគត ថាអាចរៀបចំផែនការប្រកបដោយអត្ថន័យបាននោះទេ"[65]។ អង្គជំនុំជម្រះសាលាដំបូងក៏បានចៀសវាងមិនដោះស្រាយបញ្ហាថា តើការជំនុំជម្រះបន្តបន្ទាប់នឹងត្រូវរៀបចំដោយរបៀបណា ហើយជាពិសេសមិនដឹងពេលណាដែលសវនាការទីពីរក្នុងសំណុំរឿង ០០២ ("សំណុំរឿង ០០២/០២") នឹងត្រូវចាប់ផ្ដើមនោះឡើយ[66]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យ"រៀបចំកិច្ចប្រជុំរៀបចំសវនាការមួយនៅចុងឆ្នាំនេះ ជាពេលដែលត្រូវធ្វើការពិនិត្យមើលឡើងវិញលើបញ្ហានេះ ដោយសារតែការកែប្រែស្ថានភាពកើតមានឡើង"[67]។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាថ្មីម្ដងទៀត អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្ដល់នូវផែនការច្បាស់លាស់ពាក់ព័ន្ធនឹងរឿងក្ដីបន្តបន្ទាប់ដែលត្រូវជំនុំជម្រះ បន្ទាប់ពីសំណុំរឿង ០០២/០១ បានបញ្ចប់ទៅ។

---

[62] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៤។

[63] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៥៣។

[64] សេចក្ដីសម្រេចដែលរងការជំទាស់, ទំព័រ ៧១ ដល់ ៧៤។

[65] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៥៣។

[66] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៥៤ ដល់ ១៥៥។

[67] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៥៥។

25. កាលៈទេសៈប្រែប្រួលចាំបាច់ដទៃទៀតដែលកើតមានឡើង ក្នុងពេលមានសេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅតែអាចអនុវត្តបាននាពេលបច្ចុប្បន្ននេះដែរ។ នៅក្នុងការសម្រេចបំបែកកិច្ចដំណើរការក្នុងសំណុំរឿង ០០២ ជាថ្មី អង្គជំនុំជម្រះសាលាដំបូងបានអះអាងសាជាថ្មីហើយថា ការពិចារណារបស់ខ្លួនជាបឋម គឺដើម្បីរក្សាឱ្យបាននូវលទ្ធភាពក្នុងការចេញ"សាលក្រមណាមួយ" ក្នុងសំណុំរឿង ០០២[68] ដោយបានចង្អុលបង្ហាញនូវកត្តាជាក់ស្តែងនៃមរណភាពរបស់ អៀង សារី នាពេលថ្មីៗនេះ[69]។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូង បានលើកពីភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងថិរវេលា និងនិរន្តរភាពនៃការគាំទ្រផ្នែកថវិកាដល់ អ.វ.ត.ក[70]។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបន្ថែមទៀតថា ពុំមានការសម្រេចលើការពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ តទៅទៀតឡើយ[71]។

26. ពាក់ព័ន្ធនឹងបញ្ហានានាដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសម្រេចដែលរងការជំទាស់ អាចធ្វើឱ្យផ្អាក *ជាក់ស្តែង* កិច្ចដំណើរការនីតិវិធី ទាក់ទិននឹងបទចោទទាំងអស់ដែលពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយថា ដោយស្ថិតក្រោមកាលៈទេសៈនាពេលបច្ចុប្បន្ននេះ ការផ្អាកនេះមិនបានសន្យាច្បាស់លាស់ណាមួយនៃការបន្តកិច្ចដំណើរការនីតិវិធីឡើងវិញ ដើម្បីឱ្យឈានដល់ការចេញសាលក្រមលើអង្គសេចក្តី។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ និងសេចក្តីសម្រេចក្នុងការកំហិតវិសាលភាពនៃសំណុំរឿង ០០២/០១ មកត្រឹមបទចោទ ដែលពាក់ព័ន្ធនឹងដំណាក់កាលទី ១ ដំណាក់កាលទី ២ និង ទួលពោធិ៍ជ្រៃ មានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងតុល្យភាពនៃបទចោទដែលនៅសេសសល់ក្នុងដីកាដំណោះស្រាយ។

27. ហេតុនេះ បណ្តឹងសាទុក្ខអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង។

## IV. អង្គសេចក្តី

28. ដូចបានរំលឹកខាងលើរួចមកហើយ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលរងការជំទាស់នេះ ដែលក្នុងនោះ បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ ក្នុងសំណុំរឿង ០០២ ដែលដូចគ្នាទៅនឹងដីកាពីដំបូង គឺថា បានកំហិតវិសាល

[68] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៨, ១៣៥, ១៦១។

[69] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៤, ២៨, ៤៧, ១២៩, ១៣២, ១៣៥, ១៦១។

[70] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៤៥ ដល់ ១៤៦, ១៥៣, ១៥៥, ១៦១។

[71] សេចក្តីសម្រេចដែលត្រូវបានជំទាស់, ទំព័រ ៧០។

ភាពនៃសំណុំរឿង ០០២/០១ បញ្ចូលត្រឹមតែបទចោទនានាដែលពាក់ព័ន្ធនឹងដំណាក់កាលទី ១ ដំណាក់កាលទី ២ និង ទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ[72]។

29. សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានក្នុងការអនុវត្តបទដ្ឋានគតិយុត្តិសម្រាប់ការបំបែកកិច្ចដំណើរការនីតិវិធី ដែលកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល[73]។ សហព្រះរាជអាជ្ញាជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយធ្វើការសន្និដ្ឋានថា វិសាលភាពនៃសំណុំរឿង ០០២/០១ ដែលមានស្រាប់ គឺជាតំណាងយ៉ាងពេញលេញនៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដោយពុំចាំបាច់បន្ថែមមន្ទីរ ស-២១[74] និងដោយធ្វើការសន្និដ្ឋានថា ការបន្ថែមមន្ទីរ ស-២១ នឹងនាំឱ្យមានការពន្យារពេលសវនាការដោយឥតសមហេតុផល[75]។ ដោយពិចារណាទៅលើអាយុ និងសុខភាពរបស់សហជនជាប់ចោទ សហព្រះរាជអាជ្ញាបានលើកឡើងនូវទឡ្ហីករណ៍បន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការស្នើឡើងឱ្យមានសវនាការបន្តបន្ទាប់គ្នាជាច្រើននាពេលអនាគត[76]។ ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ធ្វើការកែប្រែសេចក្ដីសម្រេចដែលរងការជំទាស់នេះ ដើម្បីបញ្ចូលមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[77]។

30. នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ជាថ្មី[78] និងខកខានក្នុងការបញ្ចូលបទចោទនានាដែលពាក់ព័ន្ធនឹងបទប្រល័យពូជសាសន៍ និងសហករណ៍ និងការដ្ឋាននានាក្នុងសំណុំរឿង ០០២/០១[79]។ ហេតុនេះ ជនជាប់ចោទស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល មោឃៈសេចក្ដីសម្រេចដែលរងការជំទាស់នេះ ដោយសារធ្វើឱ្យប៉ះពាល់ដល់ដីការបំបែកកិច្ចដំណើរការនីតិវិធីនានា នាពេលអនាគត ឬ ជាជម្រើសម្យ៉ាងទៀត ពង្រីក

[72] *សូមមើលខាងលើ,* កថាខណ្ឌ ២ និង ៤ ដល់ ៩។ *សូមមើលផងដែរ* សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៤, ៨៥ ដល់ ១៦១, ទំព័រ ៧០។

[73] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២០ ដល់ ២៧។

[74] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៨ ដល់ ៥០។

[75] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៥១ ដល់ ៧៥។

[76] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧៦ ដល់ ៧៩។

[77] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៨៤។

[78] បណ្ដឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៩ ដល់ ២៧។

[79] បណ្ដឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ២៨ ដល់ ៥៥។

វិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីបញ្ចូលបទចោទនៃបទប្រល័យពូជសាសន៍ និងបទចោទនានា ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋាននានា[80]។

## ក. ការចោទប្រកាន់អំពីភាពមិនត្រឹមត្រូវនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរក្នុងសំណុំរឿង ០០២

31. នៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយបញ្ហាជាបឋម"ថាតើ ការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី នៅដំណាក់កាលចុងក្រោយនៃការជំនុំជម្រះនេះ គឺជាការសមស្រប ដែរ ឬយ៉ាងណា"[81]។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "នៅពេលដែលការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានសម្រេចឡើងជាលើកដំបូង [...] មុនពេលចាប់ផ្ដើមសវនាការ នោះគឺដោយសារអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានភាពចំបាច់ចំពោះផលប្រយោជន៍យុត្តិធម៌ ដើម្បីអាចឲ្យជំនុំជម្រះសាលាដំបូងមានលទ្ធភាពចេញសាលក្រមណាមួយក្នុងសំណុំរឿង ០០២ បានទាន់ពេលវេលា"[82]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា "ឧបសគ្គដែលនាំឲ្យមានភាពចាំបាច់ដល់ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងខែ កញ្ញា ឆ្នាំ ២០១១ (មានដូចជា អាយុចាស់ជរា និងការបន្តចុះខ្សោយខាងរាងកាយរបស់សហជនជាប់ចោទទាំងអស់ក្នុងសំណុំរឿង ០០២ និងភាពមិនច្បាស់លាស់ដែលថា បទចោទទាំងអស់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ អាចត្រូវបានធ្វើសវនាការក្នុងអំឡុងពេលដែលជនជាប់ចោទនៅមានជីវិត ឬនៅមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីការចូលរួមសវនាការនោះ) ឧបសគ្គទាំងនេះ នៅតែជាបញ្ហាប្រឈមមុខ និងកាន់តែនាំឲ្យមានការព្រួយបារម្ភថែមទៀត ដោយសារតែការវិវត្តនានា ចាប់តាំងពីពេលដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ មកនោះ"[83]។ ផ្អែកទៅលើមូលហេតុទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មីនៃសំណុំរឿង ០០២ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតែជាលក្ខខណ្ឌតម្រូវដើម្បីផលប្រយោជន៍នៃយុត្តិធម៌"[84]។

32. នួន ជា បានលើកឡើងថា នៅក្នុងការសម្រេចបំបែកកិច្ចកិច្ចដំណើរការនីតិវិធីជាថ្មី អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការពិចារណាទៅលើសារណារបស់

[80] បណ្ដឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៨៤។

[81] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៨៥។

[82] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៨៦។

[83] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៨៧។

[84] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៩០។

សហជនជាប់ចោទអំពីបញ្ហានេះទេ[85] និងពុំបានបង្កើតជាផែនការមួយគ្រប់គ្រាន់ ដើម្បីដោះស្រាយឧបសគ្គនានាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែង នៅក្នុងការរៀបចំសវនាការជាបន្តបន្ទាប់នៅ អ.វ.ត.ក ឡើយ[86]។ ជាពិសេស ជនជាប់ចោទជំទាស់តវ៉ាថា មុនពេលចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីសម្រាប់បទចោទរួម អង្គជំនុំជម្រះសាលាដំបូង ត្រូវបានស្នើសុំឲ្យធ្វើការពិចារណាទៅលើការប៉ះពាល់ជាសក្តានុពលដល់សិទ្ធិរបស់ជនជាប់ចោទ និងបន្ទុកសំខាន់ទៅលើសាក្សីនានា និង“កត្តាផ្សេងៗទៀតទាក់ទងទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ ជាពិសេស លទ្ធភាពពាក់ព័ន្ធដែលអាចសម្រាប់អង្គជំនុំជម្រះ និងភាគីនានានៃការជំនុំជម្រះរឿងក្តីតែមួយ ទល់នឹង ការជំនុំជម្រះរឿងក្តីដាច់ដោយឡែក”[87]។ ជនជាប់ចោទអះអាងបន្ថែមថា ការបំបែកកិច្ចដំណើរការនីតិវិធី គឺមិនស្របទៅនឹងសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ ដោយសារបទពិសោធកន្លងមក ក្នុងអំឡុងពេលដីកាបំបែកកិច្ចដំណើរការនីតិវិធីទីមួយក្នុងសំណុំរឿង ០០២ បានបង្ហាញថា ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ មានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំង ដែលមិនអនុញ្ញាតឲ្យមានការបំបែកទៅជាការជំនុំជម្រះក្តីដាច់ដោយឡែកពីគ្នានោះទេ[88]។ ជនជាប់ចោទបានជំទាស់តវ៉ាថា ការខិតខំប្រឹងប្រែងធ្វើដូច្នេះបានបង្កឲ្យមានព្យសនកម្មមកលើរូបគាត់ ហើយធ្ងន់ធ្ងរបំផុតនោះ គឺដោយការបង្អាក់ដល់លទ្ធភាពរបស់គាត់ ក្នុងការជំទាស់តវ៉ាទៅនឹងភស្តុតាងប្រឆាំងមកលើរូបគាត់ និងក្នុងការការពារខ្លួនឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដោយការលុបបំបាត់សេចក្តីរំពឹងនៃសំណុំរឿង ០០២ ទាំងមូល[89]។ ជនជាប់ចោទបន្ថែមទៀតថា ការបំបែកកិច្ចដំណើរការនីតិវិធីដែលបានសម្រេចសារជាថ្មីនេះ ពុំមានលក្ខណៈសមស្របនោះទេ ពីព្រោះថា ការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយនៃសំណុំរឿង ០០២ បានបណ្តាលឲ្យជំនុំជម្រះលើកទីមួយ មិនអាចចាត់ចែងបាន[90] និងដោយសារថា អង្គជំនុំជម្រះសាលាដំបូងពុំមានលទ្ធភាពបំពេញកិច្ចដោយមិនលម្អៀង នៅក្នុងសំណុំរឿង ០០២/០២ បាន

---

[85] បណ្តឹងសាទុក្ខរបស់ នួន ជា ត្រង់កថាខណ្ឌ ៩ និងពីកថាខណ្ឌ ២២ ដល់ ២៤។

[86] បណ្តឹងសាទុក្ខរបស់ នួន ជា ត្រង់កថាខណ្ឌ ៩។

[87] បណ្តឹងសាទុក្ខរបស់ នួន ជា ត្រង់កថាខណ្ឌ ១១។

[88] បណ្តឹងសាទុក្ខរបស់ នួន ជា ពីកថាខណ្ឌ ១២ ដល់ ២១។ សារណាបន្ថែមរបស់ នួន ជា ឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ពីកថាខណ្ឌ ២១ ដល់ ២៤។

[89] បណ្តឹងសាទុក្ខរបស់ នួន ជា ពីកថាខណ្ឌ ១២ ដល់ ២០។ សារណាបន្ថែមរបស់ នួន ជា ឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ពីកថាខណ្ឌ ១៣ ដល់ ២១។ *សូមមើលផងដែរ* ការឆ្លើយតបរបស់ នួន ជា ត្រង់កថាខណ្ឌ ៥។

[90] បណ្តឹងសាទុក្ខរបស់ នួន ជា ត្រង់កថាខណ្ឌ ១២ និងកថាខណ្ឌ ២០។

ទេ ក្រោយពេលចេញសាលក្រមលើសំណុំរឿង ០០២/០១ រួចមក[91]។ ជនជាប់ចោទជំទាស់តវ៉ាថា កំហុសទាំងអស់នេះតម្រូវឱ្យធ្វើមោឃភាពចំពោះសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ[92]។

33. សហព្រះរាជអាជ្ញាឆ្លើយតបថា នួន ជា ត្រូវបានហាមឃាត់មិនឱ្យជំទាស់តវ៉ាទៅលើភាពមិនត្រឹមត្រូវនៃគោលការណ៍បំបែកកិច្ចដំណើរការនីតិវិធី ដោយហេតុថា ចាប់តាំងពីពេលដែលការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានសម្រេចនៅក្នុងខែ កញ្ញា ឆ្នាំ ២០១១ មក គាត់បានបង្ហាញជំហរមួយ ដែលពិតជាផ្ទុយគ្នាស្រឡះទៅនឹងជំហររបស់គាត់នាពេលនេះ។ ហើយវាជាគោលការណ៍ទូទៅនៃច្បាប់ដែលថា ភាគីនៃរឿងក្តីមិនអាចទទួលបានជោគជ័យពីការលើកឡើងនូវការជំទាស់តវ៉ា ដែលមិនស្របគ្នាទៅនឹងសេចក្តីដ្ឋានមុនៗរបស់ខ្លួននោះឡើយ[93] ។ ជាគោលការណ៍ សហព្រះរាជអាជ្ញាបានជំទាស់តវ៉ាបន្ថែមទៀតថា ការបំបែកកិច្ចដំណើរការនីតិវិធីពីសំណុំរឿង ០០២ ពិតជាស្របទាំងស្រុងទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងថា គាត់ខកខានមិនបានគាំទ្រឱ្យបានពេញលេញដល់ការជំទាស់តវ៉ារបស់គាត់ថា ការបំបែកកិច្ចដំណើរការនីតិវិធីពិតជារំលោភសិទ្ធិទាំងនោះមែននោះ[94] ។

34. នួន ជា ឆ្លើយតបថា ទស្សនៈនានាដែលមេធាវីការពារក្តីរបស់ខ្លួន បានលើកឡើងពីមុន ពាក់ព័ន្ធនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ពុំមានឥទ្ធិពលទៅលើការសម្រេចនៅក្នុងបណ្តឹងសាទុក្ខនេះទេ និងថា ពុំមានភាពមិនស៊ីសង្វាក់គ្នាណាមួយកើតមានទាក់ទងទៅនឹងជំហរពីដំបូងរបស់គាត់ឡើយ[95]។

35. ការបំបែកកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវបានប្រមើលឃើញជាមុន នៅក្រោមវិធាន ៨៩ *ស្ទួន*នៃវិធានផ្ទៃក្នុងដូចតទៅៈ

> នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប។

---

[91] បណ្តឹងសាទុក្ខរបស់ នួន ជា ត្រង់កថាខណ្ឌ ២១។ សារណាបន្ថែមរបស់ នួន ជា ឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌ២២។

[92] បណ្តឹងសាទុក្ខរបស់ នួន ជា ត្រង់កថាខណ្ឌ ១២ និងពីកថាខណ្ឌ ២៥ ដល់ ២៧។

[93] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ពីកថាខណ្ឌ ៦ ដល់ ៧។

[94] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ពីកថាខណ្ឌ ៨ ដល់ ១៦។

[95] សារណាតបរបស់ នួន ជា ពីកថាខណ្ឌ ៣ ដល់ ៤។

36. អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា នៅក្នុងការប្រកាសអំពីមោឃភាពនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់ហើយថា សេចក្តីសម្រេចរបស់ អ.ជ.ត.ក ពុំបានធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកសំណុំរឿង ០០២ នោះទេ ប៉ុន្តែ "អង្គជំនុំជម្រះសាលាដំបូងត្រូវអញ្ជើញភាគីនានាឱ្យដាក់សារណារបស់ខ្លួនលើលក្ខខណ្ឌនៃដីកានេះ ហើយនៅពេលដែលអត្ថប្រយោជន៍របស់*ភាគីទាំងអស់* ត្រូវបានធ្វើឱ្យមានតុល្យភាពចំពោះកត្តាពាក់ព័ន្ធ*ផ្សេងៗ*ហើយនោះ ទើបការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ អាចធ្វើទៅបានប្រកបដោយភាពសមស្រប"[96]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់នូវការណែនាំជាក់លាក់ស្តីពីសញ្ញាណដែលថា ការបំបែកកិច្ចដំណើរការនីតិវិធី គឺត្រូវតែផ្អែកលើ"ផលប្រយោជន៍យុត្តិធម៌"៖

> អត្ថន័យនៅក្នុងវិធាន *៨៩ស្ទួន* នៃវិធានផ្ទៃក្នុងបង្ហាញថា សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមិនមែនជាឆន្ទានុសិទ្ធិសុទ្ធសាធនោះទេ ដែលនៅក្នុងសេចក្តីសម្រេចនោះត្រូវតែផ្តល់យុត្តិកម្មដោយផ្អែកលើ "ផលប្រយោជន៍យុត្តិធម៌" តែផ្ទុយទៅវិញ សេចក្តីសម្រេចនោះមិនបានផ្តល់ការណែនាំថាកាលៈទេសៈអ្វីខ្លះដែលអាចបំពេញលក្ខខណ្ឌបែបនោះបាន។ តាមទស្សនៈរបស់អង្គជំនុំជម្រះតុលាការកំពូល "ផលប្រយោជន៍យុត្តិធម៌" ក្នុងការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវតែបកស្រាយដោយបង្ហាញនូវលក្ខខណ្ឌដែលជនជាប់ចោទ និង/ឬ បទចោទ ដែលត្រូវបានជំនុំជម្រះដាច់ដោយឡែកនោះ អាចបម្រើគោលដៅនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងគោលការណ៍នានាដែលជាគោលការណ៍សម្អាងបានប្រសើរជាង។ ដូចដែលបានយល់កន្លងមក "ផលប្រយោជន៍យុត្តិធម៌" ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីនឹងត្រូវពឹងផ្អែកទៅលើកត្តាផ្សេងៗជាច្រើន ដែលតម្រូវឱ្យសម្រេចទៅតាមករណីជាក់ស្តែង ក្រោយពីបានធ្វើការពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចបំបែកសំណុំរឿងមួយបានដោយរបៀបណានោះ។ ប៉ុន្តែ ទោះបីជាឆន្ទានុសិទ្ធិដែលបានផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកកិច្ចដំណើរការនីតិវិធីមានភាពទូលំទូលាយយ៉ាងណាក៏ដោយ ក៏ "ផលប្រយោជន៍យុត្តិធម៌" ចាំបាច់តម្រូវឱ្យបង្ហាញសម្អាងហេតុឱ្យបានគ្រប់គ្រាន់ ដោយលើកឡើងពីកាលៈទេសៈជាប់ពាក់ព័ន្ធឱ្យបានច្បាស់លាស់ ហើយចាំបាច់ត្រូវពន្យល់ពីអានុភាពរួមទៅលើសំណុំរឿងដែលបានបំបែកនោះឱ្យបានក្បោះក្បាយទាំងស្រុង[97]។

[96] *សូមមើលខាងលើ* កថាខណ្ឌ ៨, ដក់ស្រង់សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០ (សេចក្តីបញ្ជាក់បន្ថែមពីឯកសារដើម)។

[97] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៥។

37. ទោះបីជាមានការបំភ្លឺយ៉ាងនេះក្ដី នៅត្រង់ចំណុចដែលថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ឆន្ទានុសិទ្ធិដែលទទួលបានតាមវិធាន *៨៩ស្ទួន* នៃវិធានផ្ទៃក្នុង ពុំត្រូវបានកំហិត ឬមានលក្ខណៈច្បាស់លាស់[98] ហេតុនេះ ខ្លួនគប្បីត្រូវស្វែងរកការណែនាំនៅក្នុងវិធានស្ដីពីនីតិវិធី ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[99]។ តាមពិតទៅ ដោយហេតុថាតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាទូទៅ ទទួលបានឆន្ទានិសិទ្ធិដ៏ទូលំទូលាយ ដើម្បីបំបែកបទចោទ ឬបំបែកការជំនុំជម្រះទៅលើជនជាប់ចោទច្រើនរូប[100]។ ដូចនេះ ការអនុវត្តនៃឆន្ទានុសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របទៅតាមបទដ្ឋាននៃលក្ខណៈវិនិច្ឆ័យដូចជា "អត្ថប្រយោជន៍យុត្តិធម៌","វិសមភាពនៃផលប្រយោជន៍" និង"ការប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ" ទោះបី

[98] *សូមមើល* សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២៥ (ធ្វើការសន្និដ្ឋាន"ថា កត្តានានាដែលចាំបាច់ត្រូវធ្វើការវាយតម្លៃ គឺជាឆន្ទានុសិទ្ធិក្នុងការពិភាក្សារៀបចំសវនាការ" ដោយមានមូលដ្ឋានអះអាងថា សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ពុំបានផ្ដល់"នូវការរៀបរាប់យ៉ាងលំអិតអំពីកត្តា"ទាំងអស់" ឬ"ដទៃផ្សេងទៀតដែលជាប់ពាក់ព័ន្ធ" ដែលខ្លួនអាចធ្វើការពិចារណា មុខពេលចាប់ផ្ដើមនីតិវិធីបំបែកកិច្ចដំណើរការនីតិវិធី ឬសម្រេចពីវិសាលភាពនៃការជំនុំជម្រះ")។

[99] មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក")។ មាត្រា ៣៣ *ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់បង្កើត អ.វ.ត.ក") និងវិធាន ២ នៃវិធានផ្ទៃក្នុង។

[100] *ជាឧទាហរណ៍ សូមមើល* វិធាន ៨៤ វិធាន ៤៩ វិធាន ៧២(ក)(iii) និងវិធាន ៨២(ខ) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ហៅថា "វិធានសម្រាប់តុលាការ ICTY" និង"ICTY") វិធាន ៤៨ វិធាន ៤៨ស្ទួន វិធាន ៤៩ វិធាន ៧២(ក)(iii) និងវិធាន ៨២(ខ) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ("ICTR") វិធាន ៤៨ វិធាន ៤៩ វិធាន ៧២(ខ)(iii) និងវិធាន ៨២(ខ) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសសៀរ៉ាលេអូន ("SCSL") ហើយជាប់ទាក់ទងទៅនឹងការបំបែកការជំនុំជម្រះមកលើជនជាប់ចោទច្រើននាក់វិញ មាត្រា ៦៤(៥) នៃលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងវិធាន ១៣៦ នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ *សូមមើលផងដែរ* តុលាការ ICTY, *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង MLADIĆ,* សំណុំរឿងលេខ IT-09-92-PT សេចក្ដីសម្រេចលើសំណើរួមគ្នារបស់អយ្យការសុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីរៀបចំសវនាការដាច់ដោយឡែកពីគ្នា និងដើម្បីកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១១ ("សេចក្ដីសម្រេចលើ *រឿងក្ដី Mladić*"), កថាខណ្ឌ ២២ ("អង្គជំនុំជម្រះ [សាលាដំបូង] មានអំណាចបំបែកបទចោទប្រកាន់រួមគ្នានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយ និងរៀបចំសវនាការដាច់ពីគ្នា"); តុលាការ ICTY, *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Slobodan MILOŠEVIĆ,* សំណុំរឿងលេខ IT-99-37-AR73, សំអាងហេតុសម្រាប់សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្អូពីការជំទាស់នឹងដីកាបដិសេធ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ("សេចក្ដីសម្រេចលើ *រឿងក្ដី Milošević*"), កថាខណ្ឌ ២៦ ("ប្រសិនបើផលប្រយោជន៍នៃប្រតិសកម្ម អង្គជំនុំជម្រះសាលាដំបូងយល់កាន់តែច្បាស់ថា សវនាការបានបង្កើតឡើងតាមវិធីបែបនេះដែលក្លាយទៅជាមិនអាចគ្រប់គ្រងបាន [...] អង្គជំនុំជម្រះសាលាដំបូងនឹងនៅតែមានឱកាសក្នុងការចេញដីកាបំបែកបទចោទនៅដំណាក់កាលនេះបាន")។

ជាលក្ខណៈវិនិច្ឆ័យទាំងនេះពុំមាននៅក្នុងលក្ខន្តិកៈ និងក្នុងវិធាននៃនីតិវិធីក៏ដោយ[101]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីដំបូង សេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី គឺត្រូវជាប់ពាក់ព័ន្ធទៅនឹងការធ្វើឱ្យមានតុល្យភាពនូវអត្ថប្រយោជន៍ផ្សេងៗគ្នាដែលស្របច្បាប់ ដោយធ្វើការប្រៀបធៀបរវាងផលប្រយោជន៍ និងគុណវិបត្តិនៃការបើកការជំនុំជម្រះតែមួយលើបទចោទទាំងអស់ដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខុសប្លែកពីផលប្រយោជន៍ និងគុណវិបត្តិនៃការបើកការជំនុំជម្រះច្រើនលើបទចោទដូចៗគ្នា[102]។

38. កត្តាមួយចំនួនដែលត្រូវបានយកមកពិចារណា *ក្នុងចំណោមកត្តាជាច្រើន* រួមមាន ការធ្វើឱ្យប៉ះពាល់ជាសក្ដានុពលដល់សិទ្ធិរបស់ជនជាប់ចោទ ប្រសិទ្ធភាព និងភាពអាចចាត់ចែងបាននៃកិច្ចដំណើរការនីតិវិធី គោលបំណងជៀសវាងភាពពុំស៊ីសង្វាក់គ្នារវាងការជំនុំជម្រះដាច់ដោយឡែកពីគ្នា និងការទទួលបន្ទុកទៅលើសាក្សី[103]។ ការធ្វើឱ្យប៉ះពាល់ជាសក្ដានុពលដល់សិទ្ធិរបស់ជនជាប់ចោទ ត្រូវបានយកមក

---

[101] *សូមមើលជាឧ.* សេចក្ដីសម្រេចលើ *រឿងក្ដី* *Mladić* កថាខណ្ឌ ១៦ និង ២៨។ Suzannah LINTON in Göran SLUITER, Håkan FRIMAN, Suzannah LINTON, Salvatore ZAPPALA, Sergey VASILIEV (eds.), *នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ, វិធាន និងគោលការណ៍*, ការបោះពុម្ពលើកទី ១ (Oxford: Oxford University Press, 2013) ("Sluiter et al. ICP Book"), ទំព័រ ៥២៥។

[102] *សូមមើល*សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០។

[103] *នៅក្នុងចំណោមបញ្ហាជាច្រើន សូមមើល* សេចក្ដីសម្រេចទៅលើ *រឿងក្ដី* *Mladić* កថាខណ្ឌ ១៥ កថាខណ្ឌ ២៥ ដល់ ២៦ និង កថាខណ្ឌ ២៨ ដល់ ៣៧។ សេចក្ដីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍របស់ *Milošević* កថាខណ្ឌ ២២ និង កថាខណ្ឌ ២៤ ដល់ ៣០។ *សូមមើលផងដែរ* តុលាការ ICTY *រឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Radoslav BRĐANIN* និង *Momir TALIĆ* សំណុំរឿងលេខ IT-99-36-T សេចក្ដីសម្រេចទៅលើសំណើផ្ទាល់មាត់របស់រដ្ឋអាជ្ញាសុំឱ្យមានការបំបែកការជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ("សេចក្ដីសម្រេចលើ *រឿងក្ដី Talič*") កថាខណ្ឌ ២៦ និងកថាខណ្ឌ ២៨។ *រឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Jadranko PRLIĆ និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-PT សេចក្ដីសម្រេចលើសារណារបស់ក្រុមមេធាវីការពារក្ដីចំពោះការជំនុំជម្រះដាច់ដោយឡែក និងការបំបែកបទចោទ ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។ តុលាការ ICTR *រឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Théoneste BAGOSORA និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ ICTR-98-41-T សេចក្ដីសម្រេចលើសំណើនានាដែលដាក់ដោយ Ntabakuze ចំពោះការបំបែកកិច្ចដំណើរការនីតិវិធី និងដើម្បីកំណត់កាលវិភាគប្រកបដោយហេតុផលសម្រាប់ការបង្ហាញភស្តុតាងរបស់សាក្សីដាក់បន្ទុក ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៣ កថាខណ្ឌ ២២។ *រឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Théoneste BAGOSORA* (សំណុំរឿងលេខ ICTR-96-7) រឿងក្ដី *Gratien KABILIGI* (សំណុំរឿងលេខ ICTR-97-34) រឿងក្ដី *Aloys NTABAKUZE* (សំណុំរឿងលេខ ICTR-97-30) និង*រឿងក្ដី* *Anatole NSENGIYUMVA* (សំណុំរឿងលេខ ICTR-96-12) សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាចំពោះការជំនុំជម្រះរួមគ្នា ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០០ ("សេចក្ដីសម្រេចលើសំណើរួមរបស់ *Bagosora*") កថាខណ្ឌ ១៤៧។ តុលាការ SCSL *រឿងក្ដីរវាង រដ្ឋអាជ្ញា ទល់នឹង* *Issa Hassan SESAY* (សំណុំរឿងលេខ SCSL-2003-05-PT) រឿងក្ដី *Alex Tamba BRIMA SESAY*

ពិចារណាជាចម្បង ចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយមិនមានការអូសបន្លាយពេលវេលា ដោយសារតែកាលៈទេសៈនានាពាក់ព័ន្ធនឹងជនជាប់ចោទជាក់លាក់មួយចំនួន ឬ "ទាក់ទងទៅនឹងភស្តុតាងដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ប៉ុន្តែមិនពាក់ព័ន្ធនឹងជនជាប់ចោទដទៃទៀត នៅក្នុងការជំនុំជម្រះរួមគ្នានោះទេ"[104]។ ជាពិសេស មានការពិចារណាថា ការបំបែកបទចោទអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ជនជាប់ចោទ នៅក្នុងការចូលរួមរៀបចំការការពារខ្លួននៅក្នុងសវនាការលើកទីពីរ ដោយសារថា វាតម្រូវឱ្យមានការចូលរួមពីសំណាក់ជនជាប់ចោទក្នុងពេលជំនាលគ្នា នៅក្នុងរឿងក្តីពីរ[105]។ លើសពីនេះទៀត ការជាប់ពាក់ព័ន្ធនោះគឺ ហានិភ័យនៃការបំបែកកិច្ចដំណើរការនីតិវិធីដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ដោយមិនមានការពន្យារពេលវេលា ទាក់ទងនឹងបទចោទដែលត្រូវបានយកមកវិនិច្ឆ័យនៅក្នុងជំនុំជម្រះលើកទីពីរ[106] ដោយពិចារណាឃើញថា "សវនាការពីរបន្តបន្ទាប់គ្នា [...] ពិតជាត្រូវការចំណាយពេលវេលាច្រើនជាងសវនាការតែមួយ ដោយជៀសមិនរួចឡើយ"[107]។ ជាករណីលើកលែង សេចក្តីសម្រេច*ប្រឆាំងនឹង*ការជំនុំជម្រះរួមគ្នា ដោយមានជនជាប់ចោទច្រើននាក់ កើតចេញពីការពិចារណាទៅលើ "លទ្ធភាពជាចម្បង ឬលទ្ធភាពពិត គឺមិនមែនដោយសារតែទំនាស់ផលប្រយោជន៍នៃយុត្តិសាស្ត្រការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែ ក៏ដោយសារលទ្ធភាពនៃការចោទប្រកាន់ដាក់គ្នាទៅវិញទៅមករវាង [ជនជាប់ចោទ] ផងដែរ"[108]។

39. សរុបមក ការព្រួយបារម្ភអំពីប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការពិចារណាទៅលើភាពអាចចាត់ចែងបានសម្រាប់អង្គជំនុំជម្រះ និងភាគីនានា នោះសវនាការតែមួយ *ទល់នឹង* សវនាការច្រើន និងការពិចារណាថាតើ ការព្រួយបារម្ភអំពីការរៀបចំចាត់ចែងនេះ អាចត្រូវបានធ្វើឱ្យប្រសើរឡើងដោយ

---

(សំណុំរឿងលេខ SCSL-2003-06-PT) *រឿងក្តី Morris KALLON* (សំណុំរឿងលេខ SCSL-2003-07-PT) *រឿងក្តី Augustine GBAO* (សំណុំរឿងលេខ SCSL-2003-09-PT) *រឿងក្តី Brima Bazzy KAMARA* (សំណុំរឿងលេខ SCSL-2003-10-PT) និងរឿងក្តី *Santigie Borbor KANU* (សំណុំរឿងលេខ SCSL-2003-10-PT) សេចក្តីសម្រេច និងដីកាសម្រេចទៅលើសំណើនានារបស់រដ្ឋអាជ្ញាចំពោះការជំនុំជម្រះរួមគ្នាចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើរឿងក្តី *Sesay*") កថាខណ្ឌ ២៨ និងពីកថាខណ្ឌ ៤២ ដល់ ៤៤។

[104] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី *Mladić* កថាខណ្ឌ ២៥។

[105] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី *Mladić* កថាខណ្ឌ ៣១។

[106] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី *Mladić* កថាខណ្ឌ ៣២។

[107] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី *Mladić* កថាខណ្ឌ ២៧។

[108] សេចក្តីសម្រេចលើ*រឿងក្តី Sesay* កថាខណ្ឌ ៤១។ *សូមមើលផងដែរ នៅតុលាការ* ICTY, *រឿងក្តី រដ្ឋអាជ្ញាទល់នឹង Radoslav BRĐANIN និង Momir TALIĆ*, សំណុំរឿងលេខ IT-99-36-T, សេចក្តីសម្រេចលើសំណើរបស់ Momir Talić សុំការជំនុំជម្រះដាច់ដោយឡែកពីគ្នា និងសុំដាក់ចម្លើយតប ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២៩។

ការបើកសវនាការដាច់ដោយឡែក ដែរ ឬយ៉ាងនោះ[109]។ ប្រសិទ្ធភាពនៃការបើកសវនាការច្រើន ជាជាងការបើសវនាការតែមួយ ត្រូវបានពិនិត្យពិចារណាយ៉ាងគួរឱ្យកត់សម្គាល់ ទាក់ទងនឹងៈ (i) ឧទាហរណ៍ ការបង្ហាញភស្តុតាងដែលអាចមានភាពត្រួតគ្នា ដោយការពិចារណាថា ភស្តុតាងជាក់លាក់មួយចំនួនទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់ជនជាប់ចោទ អាចត្រូវបានបង្ហាញ និងត្រូវបានពិចារណានៅក្នុងសវនាការនីមួយៗ (ii) អំឡុងពេលសរុបនៃកិច្ចដំណើរការនីតិវិធី (iii) ការរៀបចំចាត់ចែង និងការសម្របសម្រួលដល់ការផ្តល់សក្ខីកម្មរបស់សាក្សីនានាសម្រាប់សវនាការទីពីរ ក្រោយពេលសាក្សីទាំងនោះបានផ្តល់សក្ខីកម្មនៅក្នុងសវនាការលើកទីមួយរួចហើយ (iv) ការជំទាស់តវ៉ាទៅលើបញ្ហានីតិវិធីដែលត្រូវយកមកពិចារណាទ្វេដង (v) ការបាត់បង់ផលប្រយោជន៍ដែលអាចកើតមានឡើងទាក់ទងនឹងទម្លាប់ និងចរិតលក្ខណៈនៃប្រតិបត្តិការ ដែលបានបង្កើតឡើងនៅក្នុងសវនាការលើកទីមួយ និងដែលអាចមិនត្រូវបានយកមកអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូងទីពីរ ប្រសិនបើសវនាការជាបន្តបន្ទាប់ត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះផ្សេងនោះ (vi) ការព្រួយបារម្ភអំពីផ្លូវច្បាប់ និងការចាត់ចែង ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះដដែលត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវទាំងសំណុំរឿងទីមួយ និងសំណុំរឿងទីពីរផងនោះ រួមទាំង លទ្ធភាពនៃសេចក្តីលម្អៀង និងការបង្ហាញនូវសេចក្តីលម្អៀងរបស់អង្គជំនុំជម្រះ ដែលអាចត្រូវបានគេលើកឡើង ក៏ដូចជាល្បឿននៃសវនាការទីពីរ ប្រសិនបើអង្គជំនុំជម្រះមមាញឹកនឹងការធ្វើសេចក្តីព្រាងសាលក្រមនៅក្នុង

---

[109] *សូមមើល* ការបំបែកបទចោទ សេចក្តីសម្រេចលើ*រឿងក្តី* Mladić កថាខណ្ឌ ១៥ និងពីកថាខណ្ឌ ២៨ ដល់ ៣៨ និងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ *Milošević* ពីកថាខណ្ឌ ២៦។ *សូមមើលផងដែរ ការបំបែកសវនាការរបស់សហជនជាប់ចោទ* សេចក្តីសម្រេចលើ*រឿងក្តី* *Talić* កថាខណ្ឌ ២៦ ("យុត្តិសាស្ត្ររបស់តុលាការនេះឆ្លុះបញ្ចាំងពីការលើកឡើងរបស់រដ្ឋអាជ្ញាដែលថា បញ្ហាថវិការបស់តុលាការ និងភាពជឿនលឿនទៅមុខនៃការជំនុំជម្រះ គឺជាបុរេលក្ខខណ្ឌដ៏សំខាន់ពីរដែលគួរត្រូវបានយកមកពិចារណា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាលើករណីដែលស្ថិតនៅក្រោមវិធាន ៨២(ខ)")។ សេចកក្តីសម្រេចលើរឿងក្តីរបស់ *Sesay* កថាខណ្ឌ ២៨(ច)(i) (ដែលចែងថា "កត្តានានាដែលត្រូវយកមកពិចារណា ថាតើផលប្រយោជន៍យុត្តិធម៌នឹងត្រូវបានបំពេញដោយការជំនុំជម្រះដែរឬយ៉ាងណា" *នៅក្នុងចំណោមបញ្ហាជាច្រើន* រួមមាន "ផលប្រយោជន៍សាធារណៈនៅក្នុងការសន្សំថវិកា ការចំណាយថវិកា និងពេលវេលា") និងកថាខណ្ឌ ៤២(ក) និង(ច)។ តុលាការ ICTR *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង* *Clement KAYISHEMA* (សំណុំរឿងលេខ ICTR-95-I-T) *រឿងក្តី* *Gérard NTAKIRUTIMANA* (សំណុំរឿងលេខ ICTR-96-10-T និងសំណុំរឿងលេខ ICTR-96-17-T) និងសំណុំរឿង *Obed RUZINDANA* (សំណុំរឿងលេខ ICTR-95-1-T និង សំណុំរឿងលេខ ICTR-96-10-T) សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាចំពោះការបំបែកកិច្ចដំណើរការនីតិវិធី ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវយកមកជំនួស និងចំពោះការកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវយកមកជំនួស ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៧ ពីកថាខណ្ឌ ៤ ដល់ ៥។

សំណុំរឿងទីមួយ[110]។ បន្ថែមទៅលើការព្រួយបារម្ភចំពោះការរៀបចំចាត់ចែង ដែលទាក់ទងទៅនឹងការចាត់ចែងឲ្យមានការផ្តល់សក្ខីកម្មច្រើនដោយសាក្សីដដែល នោះបន្ទុកពិសេសទៅលើសាក្សី ត្រូវបានសង្កត់ធ្ងន់ទៅលើការការពារជាចាំបាច់ ការឈឺចាប់ខាងផ្លូវអារម្មណ៍ និងការរំខានទៅលើជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់[111]។ ជាចុងក្រោយ មានការបង្ហាញអំពីការពេញចិត្តចង់បានការរៀបចំការជំនុំជម្រះក្តីរួមគ្នាមួយ ដើម្បីកាត់បន្ថយភាពមិនស៊ីចង្វាក់គ្នាលើការយកចិត្តទុកដាក់លើភ័ស្តុតាង ការកំណត់ទោស និង ការសម្រេចលើបញ្ហាច្បាប់ផ្សេងៗទៀត[112]។ នៅក្នុងរឿងក្តីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មានការបង្ហាញយ៉ាងច្បាស់លាស់នូវទំនោរទៅរកការជំនុំជម្រះរួមគ្នា[113]។

---

[110] *សូមមើល* សេចក្តីសម្រេចលើសំណុំរឿង *Mladić* ពីកថាខណ្ឌ ២៤ ដល់ ២៦។ *សូមមើលផងដែរ* ភាពត្រួតគ្នានៃភស្តុតាង *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់* *Milošević* កថាខណ្ឌ ៣០។ សេចក្តីសម្រេចលើរឿងក្តីរបស់ *Sesay* កថាខណ្ឌ ២៨(ច)(iv) និង(ឆ) និងកថាខណ្ឌ ៤២(ឃ) (ដែលសង្កត់ធ្ងន់ពី"តម្រូវការសម្រាប់ការបង្ហាញភស្តុតាងឲ្យស៊ីចង្វាក់គ្នា និងជាលម្អិត") *និងអំឡុងពេលសរុបនៃកិច្ចដំណើរការនីតិវិធី* សេចក្តីសម្រេចលើការជំនុំជម្រះរួមគ្នាទៅលើរឿងក្តីរបស់ *Bagosora* កថាខណ្ឌ ១៥៥។

[111] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី *Mladić* កថាខណ្ឌ២៨ និងកថាខណ្ឌ ៣៧ ("ការកោះហៅសាក្សីនៅក្នុងសវនាការច្រើនលើក គឺជាការព្រួយបារម្ភទៅលើការរៀបចំចាត់ចែងការជំនុំជម្រះ ប៉ុន្តែ ក៏ជាការព្រួយបារម្ភចំពោះសាក្សីខ្លួនឯងផងដែរ ជាពិសេសនៅពេលដែលអំឡុងពេលសំខាន់ៗចន្លោះពីសវនាការទីមួយ និងសវនាការទីពីរ អាចមានរយៈពេលយូរអង្វែង និងការពិចារណាជាក់ស្តែងទៅលើការរំខានដល់ជីវិតប្រចាំថ្ងៃរបស់សាក្សី"។ សេចក្តីសម្រេចលើ*រឿងក្តី* *Sesay* កថាខណ្ឌ ២៨(ច)( iv) និងកថាខណ្ឌ ៤២(ង) (ដែលសង្កត់ធ្ងន់ទៅលើតម្រូវការឲ្យមាន "ការការពារឲ្យបានល្អប្រសើរដល់សុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ និងសាក្សី ដោយការលុបបំបាត់តម្រូវការឲ្យពួកគាត់ធ្វើដំណើរច្រើនលើក"។ *សូមមើលផងដែរ* សេចក្តីសម្រេចលើរឿងក្តី *Talić* កថាខណ្ឌ ២៨ និង*រឿងក្តីរដ្ឋអាជ្ញានៃតុលាការ ICTY ទល់នឹង Jadranko PRLIĆ និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ IT-04-74-PT សេចក្តីសម្រេចលើសារណារបស់មេធាវីការពារក្តីចំពោះការជំនុំជម្រះដាច់ដោយឡែក និងការបំបែកបទចោទ ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ២៣។

[112] *សូមមើលសេចក្តីសម្រេចលើរឿងក្តី* *Sesay*, កថាខណ្ឌ ២៨(ច)(ii)-(iii), ៤២(ខ)-(គ), ៤៤(ជ)។ *សូមមើលផងដែរ សេចក្តីសម្រេចរួម* *Bagosora* កថាខណ្ឌទី ១៤៣ ("ក៏ជាការប្រាថ្នាចង់បានមួយផងដែរ និង ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ប្រកបដោយតម្លាភាព គេ គប្បីចេញសាលក្រមដូចគ្នា និង ប្រព្រឹត្តឲ្យដូចគ្នាទៅលើជនទាំងអស់ដែលត្រូវបានជំនុំជម្រះក្តីរួមគ្នា ពាក់ព័ន្ធនឹងបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងលក្ខណៈដូចគ្នា។ ការធ្វើដូច្នេះ គឺដើម្បីចៀសវាងភាពមិនស៊ីសង្វាក់គ្នា ដែលអាចកើតមានឡើងដោយចៀសមិនរួចពីការបំបែកការជំនុំជម្រះក្តី ដែលមានជនជាប់ចោទច្រើនរូបនោះឡើយ") *ដកស្រង់ចេញពីរឿងក្តីព្រះរាជអាជ្ញាទល់នឹង Zejnil DELALIĆ និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ IT-96-21-T។ សេចក្តីសម្រេចស្តីពីពាក្យសុំរបស់ជនជាប់ចោទ Delalic ស្នើសុំនីតិវិធីសម្រាប់ការសម្រេចចុងក្រោយអំពីបទចោទប្រឆាំងរូបគាត់ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៩៨ កថាខណ្ឌទី ៣៥។

[113] *សូមមើល* វិធាន ១៣៦ នៃ វិធានរបស់ ICC ។

40. កន្លងមក សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ*ពិសេស*បានរកឃើញថា កត្តានានាដូចបានរៀបរាប់ខាងលើ បានគាំទ្រឲ្យមានការជំនុំជម្រះក្តីទោលមួយ និងបានបដិសេធមិនបំបែកបទចោទដែលកើតចេញពីព្រឹត្តិការណ៍ ដែលពាក់ព័ន្ធគ្នាយ៉ាងខ្លាំងនោះ[114]។ នៅពេលតុលាការចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី គឺដីកានេះមានបំណងបំបែកការជំនុំជម្រះក្តីលើបុគ្គលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយដែលមានជនជាប់ចោទច្រើនរូប[115] ដោយផ្អែកលើភាពចាំបាច់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីឲ្យបានឆាប់រហ័ស នៅពេលដែលកាលៈទេសៈពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ បានពន្យារពេលដល់ការជំនុំជម្រះក្តីរបស់ជនជាប់ចោទដទៃទៀតតែប៉ុណ្ណោះ[116]។ ដូចគ្នានឹងករណីនេះដែរ ពាក់ព័ន្ធនឹងបញ្ហាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័សនេះ ប្រសិនបើគេរកឃើញថាមានផលប៉ះពាល់ជាក់លាក់ណាមួយទៅលើកិច្ចដំណើរការនិតិវិធីឆាប់រហ័សបែបនេះ គេនឹងបដិសេធមិនចូលរួមការជំនុំជម្រះក្តីរួមគ្នានេះទេ[117]។

41. យុត្តិសាស្ត្រនេះឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រនិយាម ដែលបានអនុម័តនៅក្នុងយុត្តាធិការជាតិមួយចំនួន ទាំងនៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ដូចជានៅប្រទេស កាណាដា សហរដ្ឋអាមេរិក អង់គ្លេស និង ប្រទេសវែល និងប្រព័ន្ធច្បាប់ស៊ីវិល ដូចជា អ៊ីតាលី អាល្លឺម៉ង់ និងបារាំង ដែល សាលាដំបូងបានថ្លឹងថ្លែងអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយ យុត្តិធម៌ និងឲ្យបានឆាប់រហ័ស ទល់នឹងផលប្រយោជន៍សង្គម នៅក្នុងការមើលឃើញថា យុត្តិធម៌ត្រូវកើត មានក្នុងលក្ខណៈសមស្រប និងប្រកបដោយប្រសិទ្ធភាពដែលអាចទទួលយកបាន និងបំណងប្រាថ្នាបញ្ចៀសនូវសេចក្តីសម្រេចដែលមិនស៊ីសង្វាក់គ្នា[118]។

---

[114] *សូមមើល* សេចក្តីសម្រេចក្នុងរឿងក្តី *Mladić និង* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Milošević* ។

[115] *សូមមើល* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌទី ៣៣ និង *លេខចុងទំព័រ* ៨៦។

[116] *សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Pavle STRUGAR និង Vladimir KOVAČEVI*, សំណុំរឿងលេខ IT-01-04-PT, សេចក្តីសម្រេចលើពាក្យសុំរបស់ព្រះរាជអាជ្ញា ស្នើសុំបំបែកការជំនុំជម្រះក្តី និងដីកាកំណត់កាលបរិច្ឆេទកិច្ចប្រជុំត្រៀមរៀបចំសវនាការរបស់អង្គបុរេជំនុំជម្រះ និង ការចាប់ផ្តើមការជំនុំជម្រះក្តីលើ Pavle Struga ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ សេចក្តីសម្រេចលើ *រឿងក្តី Talić* កថាខណ្ឌទី ២៦។

[117] *សូមមើល* សេចក្តីសម្រេចលើរឿងក្តី *Sesay* កថាខណ្ឌទី ៤៦ (នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេស SCSL បដិសេធមិនបញ្ចូលកិច្ចដំណើរការនីតិវិធីប្រឆាំងលើជនជាប់ចោទ ដែលធ្លាប់មានតួនាទីនៅក្នុងអង្គភាពយោធាពីរដាច់ដោយឡែកពីគ្នា ដើម្បីធ្វើយ៉ាងណាឲ្យកិច្ចដំណើរការនីតិវិធីផ្តោត និងពង្រឹតភាពយុត្តិធម៌ និងភាពឆាប់រហ័សនៃការជំនុំជម្រះក្តីបាន)។

[118] នៅក្នុង**ប្រទេសកាណាដា** *សូមមើល*មាត្រា ៥៩១ នៃក្រមព្រហ្មទណ្ឌប្រទេសកាណាដា។ រឿងក្តី *R.* ទល់នឹង *Last*, [2009] 3 S.C.R. 146, កថាខណ្ឌ ១៦ ("ផលប្រយោជន៍យុត្តិធម៌ក្តោបនូវសិទ្ធិរបស់ជនជាប់ចោទដែលត្រូវជំនុំជម្រះដោយផ្អែកលើភស្តុតាង

00964361



ដែលអាចទទួលយកបានប្រឆាំងនឹងរូបគាត់ ព្រមទាំងផលប្រយោជន៍របស់សង្គម នៅក្នុងការមើលឃើញថា យុត្តិធម៌ត្រូវកើតមានក្នុងលក្ខណៈសមស្រប និងប្រកបដោយប្រសិទ្ធភាពដែលអាចទទួលយកបាន។ ហានិភ័យយ៉ាងច្បាស់ក្រឡែត នៅពេលដែលបទចោទនានាត្រូវបានយកមកជំនុំជម្រះជាមួយគ្នា គឺថា ភស្តុតាងដែលអាចទទួលយកបានអំពីបទចោទមួយ នឹងមានឥទ្ធិពលទៅលើសាលក្រម លើបទចោទមួយដែលមិនពាក់ព័ន្ធ") និងកថាខណ្ឌ ១៨ ("កត្តានានាដែលតុលាការយកមកប្រើប្រាស់យ៉ាងត្រឹមត្រូវ រួមមាន៖ ផលប៉ះពាល់ជាទូទៅលើជនជាប់ចោទ, ចំណងទាក់ទងផ្នែកអង្គហេតុ និងអង្គច្បាប់រវាងបទចោទទាំងឡាយ, ភាពស្មុគស្មាញនៃភស្តុតាង, បញ្ហាថាតើជនជាប់ចោទមានបំណងផ្តល់សក្ខីកម្មទៅលើបទចោទមួយ មិនមែនបទចោទមួយផ្សេងទៀត ឬយ៉ាងណា, លទ្ធភាពនៃសាលក្រមដែលមិនស៊ីសង្វាក់គ្នា, បំណងប្រាថ្នាក្នុងការបញ្ចៀសកុំឱ្យមានកិច្ចដំណើរការនីតិវិធីច្រើនលើក, ការប្រើប្រាស់ភស្តុតាងអង្គហេតុស្រដៀងគ្នានៅពេលសវនាការ, រយៈពេលនៃសវនាការដោយពិចារណាទៅលើភស្តុតាង ដែលត្រូវបានស្នើសុំឱ្យដាក់, ផលប៉ះពាល់ដែលអាចកើតមានទៅលើជនជាប់ចោទ ទាក់ទិនទៅនឹងសិទ្ធិដែលត្រូវជំនុំជម្រះក្នុងពេលវេលាដ៏សមស្រប, និង អត្ថិភាពនៃការការពារខ្លួនជាបដិបក្ខរវាងសហជនជាប់ចោទ")។ នៅក្នុង**សហរដ្ឋអាមេរិក** *សូមមើល* វិធាន ១៤(ក) នៃនីតិវិធីព្រហ្មទណ្ឌ របស់សហព័ន្ធអាមេរិក (ដែលចែងអំពីលទ្ធភាពក្នុងការបំបែកបទចោទ ឬបង្គាប់ឱ្យបំបែកការជំនុំជម្រះ ប្រសិនបើការដាក់បទចោទបញ្ចូលគ្នា "បង្ហាញឱ្យឃើញមាននូវផលប៉ះពាល់ដល់ចុងចម្លើយ ឬរដ្ឋាភិបាល")។ *រឿងក្តី Zafiro ទល់នឹង សហរដ្ឋអាមេរិក*, 506 U.S. 534 ("ការបំបែកកិច្ចដំណើរការនីតិវិធី គួរតែអនុញ្ញាតឱ្យមាន ប្រសិនបើមានហានិភ័យធ្ងន់ធ្ងរដែលការជំនុំជម្រះរួមគ្នានឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការជំនុំជម្រះជាក់លាក់
របស់ចុងចម្លើយដែលចូលរួមជាមួយគ្នាយ៉ាងត្រឹមត្រូវ ឬរារាំងមិនឱ្យគណៈវិនិច្ឆ័យធ្វើការសម្រេចដែលគួរឱ្យជឿជាក់ បានអំពីពិរុទ្ធភាព ឬនិរទោស។ ហានិភ័យនៃផលប៉ះពាល់ នឹងខុសគ្នាផ្នែកអង្គហេតុនៅក្នុងរឿងក្តីនីមួយៗ ហើយវិធាន ទុកឱ្យតុលាការតំបន់ដែលមានឆន្ទានុសិទ្ធិសមហេតុផលសម្រេចអំពីហានិភ័យ និងវិធីនៃដំណោះស្រាយចាំបាច់")។ *រឿងក្តី* Nichols និង *Gillespie ទល់នឹង State of Arkansas,* CA CR 99-354 (សាលាឧទ្ធរណ៍រដ្ឋ Arkansas) ("សាលាដំបូង មានឆន្ទានុសិទ្ធិអនុញ្ញាត ឬបដិសេធការបំបែកកិច្ចដំណើរការនីតិវិធី ហើយសាលាឧទ្ធរណ៍នឹងមិនកែប្រែការសម្រេច ដែលពុំមានការរំលោភឆន្ទានុសិទ្ធិឡើយ។ វិធាននៃការដាក់បញ្ចូលគ្នា និងការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានតាក់តែងឡើងដើម្បីជំរុញឱ្យមានការសម្រេចសេចក្តីឱ្យបានឆាប់រហ័ស នៃរឿងក្តីព្រហ្មទណ្ឌ ដែលទន្ទឹមពេលគ្នានោះដែរ មិនត្រូវឱ្យប៉ះពាល់ដល់ចុងចម្លើយម្នាក់ៗឡើយ")។ នៅក្នុង**ប្រទេសអង់គ្លេស** និង**ប្រទេសវែល** *សូមមើល* ផ្នែក ៥(១) នៃច្បាប់វិសោធនកម្មច្បាប់ទាក់ទងនឹងការចោទប្រកាន់ ឆ្នាំ ១៩១៥ (Indictments Act 1915) (ចែងថា "មុនពេលជំនុំជម្រះ ឬនៅដំណាក់កាលជំនុំជម្រះ នៅពេលដែលតុលាការយល់ឃើញថា បុគ្គលដែលត្រូវបានចោទប្រកាន់ អាចត្រូវបានប៉ះពាល់ ឬធ្វើឱ្យអាម៉ាស់នៅក្នុងការការពារខ្លួនរបស់គាត់ ដោយសារតែត្រូវបានចោទប្រកាន់ពីបទល្មើសលើសពីមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយ ឬថា សម្រាប់ហេតុផលផ្សេងទៀត វាជាការសមហេតុផលដែលថា បុគ្គលនោះគួរតែត្រូវបានជំនុំជម្រះដាច់ដោយឡែកសម្រាប់បទល្មើសមួយ ឬលើសពីមួយ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តុលាការអាចបង្គាប់ឱ្យមានសវនាការលើអង្គហេតុមួយ ឬអង្គហេតុលើសពីមួយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដាច់ចេញពីគ្នា")។ *រឿងក្តី Ludlow ទល់នឹង Metropolitan Police Commissioner,* [1971] A.C. 29 ("ចៅក្រមពុំមានកាតព្វកិច្ចក្នុងការបង្គាប់ឱ្យមានសវនាការដាច់ចេញ ពីគ្នាឡើយ អនុលោមតាមផ្នែក ៥(៣) [នៃ Indictments Act 1915] លុះត្រាតែនៅក្នុងយោបល់របស់គាត់ មានលក្ខណៈពិសេស មួយចំនួននៃរឿងក្តីដែលនាំឱ្យការជំនុំជម្រះរួមទៅលើបទចោទច្រើន ប៉ះពាល់ ឬធ្វើឱ្យអាម៉ាស់ដល់ជនជាប់ចោទ ហើយសវនាការដោយឡែកពីគ្នាជាការចាំបាច់ដើម្បី *ផលប្រយោជន៍នៃយុត្តិធម៌* [...]")។ **នៅអាល្លឺម៉ង់** សំណុំរឿងព្រហ្មទណ្ឌអាចត្រូវបានបំបែកដោយផ្អែកលើ

42. យុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្ស គឺជាការជាប់ពាក់ព័ន្ធជាមួយនឹងការបញ្ចូលគ្នា និងការបំបែកកិច្ចដំណើរការនីតិវិធី ជាពិសេស នៅក្នុងទិដ្ឋភាពនៃសិទ្ធិក្នុងការទទួលបាននូវសេរីភាព និងការជំនុំជម្រះក្តីឱ្យបានឆាប់រហ័ស។ ជាក់ស្តែង តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (“ECtHR”) យល់ឃើញថា សេចក្តីសម្រេចរបស់តុលាការជាតិស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបែបនេះ មិនបានបណ្តាលឱ្យមានការពន្យារពេល

---

ហេតុផលនៃភាពងាយស្រួល *សូមមើល* ផ្នែក ២ និង ៤ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ភាពងាយស្រួលមានន័យទូលំទូលាយថាវាត្រូវបានរំពឹងថានឹងមានភាពងាយស្រួលសម្រាប់ការធ្វើសវនាការនៅថ្ងៃខាងមុខ។ វាស្ថិតក្រោមឆន្ទានុសិទ្ធិរបស់តុលាការដើម្បីកំណត់និយមន័យនៃភាពងាយស្រួលនៃការបំបែកសំណុំរឿង។ *សូមមើល* Pfeiffer, Strafprozessordnung, Kommentar, C.H.BECK, បោះពុម្ពលើកទីប្រាំ ឆ្នាំ ២០០៥ មាត្រា ២ កថាខណ្ឌ ៤។ ការអនុវត្តឆន្ទានុសិទ្ធិនេះអាចបើកផ្លូវប្តឹងឧទ្ធរណ៍ ដោយអនុលោមតាមមាត្រា ៣០៤(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ((OLG Hamm, 3 Ws 386/01; OLG Frankfurt, StV 1983, កថាខណ្ឌ ៩២។ នៅបារាំង ការបំបែកបទចោទអាចអនុញ្ញាតិដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ប៉ុន្តែត្រឹមតែនៅក្នុងករណីដែលបទចោទពុំអាច“បំបែកបាន”។ *សូមមើល* មាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ; Henri Angevin, *Jurisclasseur,* Fasc. 20 : Cour d’Assises – Procédure préparatoire aux sessions d’assises – Actes facultatifs ou exceptionnels, ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧ (« Angevin »), កថាខណ្ឌ ៥៨ (« *la disjonction pouvait être ordonnée ‘quand il s’agit de faits qui, bien que connexes, sont néanmoins distincts par le temps et les lieux et peuvent être débattus et jugés séparément’* ») *យោងទៅលើ* Cass. Crim., ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៨៧៣, Bull. Crim. 1873, no. 224; Cass. Crim., ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៦៤, Bull. Crim. 1964, no. 181; Cass. Crim., ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៦៩, Bull. Crim. 1969, no. 244។ *សូមមើលផងដែរ* Crim. Cass. ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៦៤, Bull. Crim. 1964, no. 181 ។ ការបំបែកការជំនុំជម្រះគឺត្រូវបានបង្គាប់ធ្វើនៅក្នុងសំណុំរឿងដែលមានជនជាប់ច្រើន ដែលកិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទម្នាក់ ពន្យារពេលជំនុំជម្រះជនជាប់ចោទដទៃទៀត។ *សូមមើល* Angevin, កថាខណ្ឌ ៦០។ ការបំបែកបទចោទត្រូវបានបង្គាប់ធ្វើ នៅក្នុងករណីដែលបទចោទខ្លះ ពុំទាន់រួចរាល់ដើម្បីវិនិច្ឆ័យ។ *សូមមើល* Crim. Cass. ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៧២ លេខ150។ នៅអ៊ីតាលី ការបំបែកសំណុំរឿងធ្វើឡើងដើម្បីធានាបានការផ្ទេរឆាប់រហ័សនៃបញ្ហាស្វយ័តទាំងអស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ *សូមមើល* មាត្រា ១៧-១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី។ ចៅក្រមត្រូវតែបង្គាប់ឱ្យបំបែកសំណុំរឿង ជាឧទាហរណ៍ ក្នុងអំឡុងពេលសវនាការបឋម នៅពេលដែលគ្មានលទ្ធភាពដើម្បីសម្រេចបានឆាប់រហ័សចំពោះជនជាប់ចោទខ្លះ បើទោះជាវាចាំបាច់ដើម្បីអនុវត្តកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងជនជាប់ចោទដទៃទៀតក្តី ហើយក្នុងករណីដែលកិច្ចនីតិវិធីប្រឆាំងជនជាប់ចោទខ្លះ ឬទាក់ទងនឹងបទចោទជាក់លាក់ត្រូវបានផ្អាក និងប្រសិនបើសវនាការលើភស្តុតាងទាក់ទងជនជាប់ចោទខ្លះ ឬបទចោទខ្លះត្រូវបានបញ្ចប់ បើទោះបីទាក់ទងនឹងជនជាប់ចោទផ្សេង ឬបទចោទផ្សេងក៏ដោយ ក៏មានការចាំបាច់ដើម្បីចាត់វិធានការបន្ថែម។ ក្រៅពីករណីដូចមានបញ្ជាក់នៅក្នុងលក្ខខ្ខិកៈទាំងនេះ ចៅក្រមអាចបំបែបកិច្ចនីតិវិធីប្រសិនបើយល់ថាវិធានការនេះ ជួយពន្លឿនសវនាការ។ យ៉ាងណាក្តី វាអាចធ្វើទៅបានលុះត្រាតែមានការឯកភាពពីសំណាក់ភាគី។ គោលការណ៍ទូទៅនៃការបំបែកសំណុំរឿងពុំអនុវត្តចំពោះការវិនិច្ឆ័យរួមនៃធាតុផ្សំនានានៃអង្គហេតុ ដែលលើកឡើងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះថាចាំបាច់បំផុតដើម្បីធានាថាសេចក្តីសម្រេចទាំងមូលគឺត្រឹមត្រូវ និងយុត្តិធម៌។ ស្ថានភាពនេះកើតឡើង ជាពិសេសនៅក្នុងករណីដែលធាតុផ្សំនៃអង្គហេតុនៃបទចោទជាច្រើន ពាក់ព័ន្ធគ្នាទៅវិញទៅមក និងលម្អៀង។ *សូមមើល* Luigi Tramontano, Codice di procedura penale spiegato, មាត្រា ១៨ La Tribuna, 2013។

ដែលមិនសមហេតុផល ឬម្យ៉ាងវិញទៀត រំលោភទៅលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ នោះឡើយ។ ផ្ទុយទៅវិញ បញ្ហាគឺថា តើបញ្ហានៃការបំបែកកិច្ចដំណើរការនីតិវិធីបានបង្កឲ្យមានអសកម្មភាពរបស់អាជ្ញាធរស៊ើបអង្កេត ឬស្ថាប័នតុលាការ[119]។ នៅក្នុងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "ការបន្តឃុំខ្លួនជនជាប់ចោទត្រូវមានការជាប់ពាក់ព័ន្ធទៅនឹងបទចោទជាក់លាក់ដែលតម្រូវឲ្យមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ"[120] ហើយថា យោងតាមយុត្តិសាស្ត្ររបស់តុលាការតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស"[ភាពស្មុគស្មាញនៃរឿងក្តី] អាចបន្តធ្វើយុត្តិកម្មបានតែក្នុងករណីនៃការបន្តដកហូតសេរីភាព នៅពេលដែលស្ថាប័នមានសមត្ថកិច្ច បានបង្ហាញឲ្យឃើញនូវ"ការយកចិត្តទុកដាក់ពិសេស" ក្នុងការរៀបចំកិច្ចដំណើរការនីតិវិធី ប៉ុណ្ណោះ"[121]។

43. សេចក្តីសន្និដ្ឋានខាងក្រោមនេះ មានលក្ខណៈចាំបាច់ណាស់ទៅលើការពិនិត្យឡើងវិញនេះ។ ទីមួយ ទោះបីជាមានដ៏ទូលំទូលាយនូវឆន្ទានុសិទ្ធិដែលបានផ្តល់ឲ្យសាលាដំបូង (រួមទាំង ប្រព័ន្ធច្បាប់ប្រទេស អ៊ីតាលី ដែលគាំទ្រនូវការបំបែកកិច្ចដំណើរការនីតិវិធី នៅពេលដែលមានបទចោទមួយដែលត្រូវយកមកធ្វើការវិនិច្ឆ័យ) យ៉ាងណាក៏ដោយ ក៏សេចក្តីសម្រេចលើការបំបែកសំណុំរឿង មិនត្រូវធ្វើឡើងស្រេចតែអំពើចិត្តឡើយ ប៉ុន្តែត្រូវតែសំអាងទៅលើបទដ្ឋាន និងថ្លឹងថ្លែងនូវផលប្រយោជន៍ផ្សេងគ្នា ដែលជាមូលដ្ឋាននៅក្នុងសិទ្ធិមនុស្ស និងគោលការណ៍នៃប្រសិទ្ធិភាព។ ក្តីកង្វល់ជាក់លាក់អំពីកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស ជាទូទៅមិនត្រូវបានដោះស្រាយដោយការវិនិច្ឆ័យលើបទចោទដែលពាក់ព័ន្ធជាសត្យានុម័ត តាមរយៈការជំនុំជម្រះក្តីច្រើនលើក នោះឡើយ។ ដូច្នេះ អានុភាពនៃការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានវាយតម្លៃទាក់ទិនទៅនឹងបទចោទ ទាំងមូលដែលបានកំណត់ មិនមែនគ្រាន់តែផ្នែកតូចមួយនោះឡើយ[122]។

[119] *សូមមើល ឧទាហរណ៍..*, តុលាការ ECtHR *រឿងក្តី Kudła ទល់នឹង* ប្រទេសប៉ូឡូញ សាលក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ពាក្យសុំលេខ 30210/96។

[120] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ឯកសារ E275/2/3 ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចលើការឃុំខ្លួនរបស់ អ.ជ.ត.ក") កថាខណ្ឌ ៤៨។

[121] សេចក្តីសម្រេចលើការឃុំខ្លួនរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០ យោងទៅលើ *ក្នុងចំណោមប្រការផ្សេងទៀត* តុលាការ ECtHR *រឿងក្តី Kudła ទល់នឹង*ប្រទេសប៉ូឡូញ សាលក្រម ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ពាក្យសុំលេខ 30210/96 កថាខណ្ឌ ១២៤។ *រឿងក្តី Letellier ទល់នឹងប្រទេសបារាំង* សាលក្រម ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩១ ពាក្យសុំលេខ 12369/86 កថាខណ្ឌ ៣៥។ *រឿងក្តី Idalov ទល់នឹងប្រទេសរុស្ស៊ី* សាលក្រម ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ពាក្យសុំលេខ 5826/03 កថាខណ្ឌ ១២៤, ១៤០។

[122] *សូមមើល*សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៥ ("ទោះបីជាមានដ៏ទូលំទូលាយឆន្ទានុសិទ្ធិដែលបានផ្តល់ឲ្យសាលាដំបូងក្នុងការសម្រេចលើការបំបែកក៏ដោយ "ផលប្រយោជន៍យុត្តិធម៌"ចាំបាច់ត្រូវតែបង្ហាញជាមួយសំអាងហេតុគ្រប់គ្រាន់ ដែល

ដូច្នេះនៅពេលដែលចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី លក្ខណៈទាំងស្រុងនៃបទចោទដែលដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានដោះស្រាយ ហើយពុំមាននីតិវិធីព្រហ្មទណ្ឌដែលចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះបានឆាប់រហ័ស និងគោលការណ៍នៃប្រសិទ្ធភាព ពុំអនុញ្ញាតឱ្យទុកផ្នែកដែលត្រូវបានបំបែកចោលមិនដោះស្រាយនោះទេ។ ប៉ុន្តែ ការផ្អែកទៅលើកាលៈទេសៈអង្គហេតុ និងផលវិបាកផ្លូវច្បាប់ សំណុំរឿងដែលបានបំបែកត្រូវបន្តដំណើរការ ឬត្រូវផ្អាក ឬបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូល នឹងពិភាក្សាលើទិដ្ឋភាពនៃរឿងក្តីនេះនៅក្នុងផ្នែកខាងក្រោមនេះ។

44. អង្គជំនុំជម្រះសាលាដំបូងបានកំណត់កត្តាខាងក្រោមនេះថា មាន"ភាពជាប់ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ក្នុងគោលបំណងធានាបានសាលក្រមទាន់ពេលវេលាមួយលើសំណុំរឿង ០០២/០១"[123]៖

(១) អាយុច្រើន និងភាពទ្រុឌទ្រោមផ្នែកផ្លូវកាយរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២ ដែលនៅសេសសល់

(២) ផលប្រយោជន៍សាធារណៈ នៅក្នុងការសម្រេចបានសាលក្រមមួយទាក់ទងយ៉ាងហោចណាស់ទៅនឹងផ្នែកនៃដីកាដំណោះស្រាយនៃសំណុំរឿង ០០២

(៣) លទ្ធភាពចាត់ចែង និងគ្រប់គ្រងបាននៃសំណុំរឿង ០០២/០១ នៅដំណាក់កាលចុងក្រោយនេះ រួមទាំងការដែលអាចមានផលប៉ះពាល់ចំពោះជនជាប់ចោទ ប្រសិនបើមានការពង្រីកវិសាល ភាពនៃការជំនុំជម្រះបន្ថែមទៀត

(៤) ភាពមិនច្បាស់លាស់មួយទៅលើថិរវេលានៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំ រឿង ០០២/០១ ប្រសិនបើមានការដាក់បញ្ចូលមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះ និង

(៥) ភាពមិនច្បាស់លាស់ទាក់ទងនឹងថិរវេលានៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ អ.វ.ត.ក។

45. តាមទស្សនរបស់អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចដែលរងការជំទាស់បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តការថ្លឹងថ្លែងឱ្យមានតុល្យភាពដ៏ចាំបាច់ ត្រឹមវិសាលភាពមួយមានកំណត់ប៉ុណ្ណោះ។ កត្តា (១), (២), (៣) និង (៤) ទាក់ទិននឹងគោលបំណងនៃភាពឆាប់រហ័សដូចគ្នា ដែលអង្គជំនុំ

---

លើកឡើងពីកាលៈទេសៈជាប់ពាក់ព័ន្ធ និងជាក់លាក់ ហើយចាំបាច់ត្រូវពន្យល់នូវអានុភាពរួមទៅលើសំណុំរឿងដែលបានបំបែកនោះឱ្យបានក្បោះក្បាយទាំងស្រុង"។

[123] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២៥។

ជម្រះសាលាដំបូងចាត់ទុកភាពចាំបាច់នៃការរក្សារយៈពេលនៃកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២/០១ ក្នុងកម្រិតអប្បបរមាបំផុត ថាមានសារៈសំខាន់ជាងអ្វីៗទាំងអស់។ កត្តា (៣) មិនបានយោង ទៅលើប្រសិទ្ធភាព និងភាពអាចគ្រប់គ្រងបាននៃកិច្ចដំណើរការនីតិវិធី ទាក់ទិនទៅនឹងសំណុំរឿង ០០២ ទាំងមូល ឡើយ ប៉ុន្តែគ្រាន់តែមានការជាប់ទាក់ទិនទៅនឹងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ ដោយសារតែ ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគណនាពេលវេលាដែលចាំបាច់ ដើម្បីធ្វើការវិនិច្ឆ័យផ្នែកបន្ថែមនៃបទចោទ ដែលពុំទាន់បានធ្វើការជំនុំជម្រះ។

46. លទ្ធភាពប៉ះពាល់ជាសក្តានុពលដល់សិទ្ធិរបស់សហជនជាប់ចោទ ត្រូវបានពិចារណាផ្អែកតាមកត្តា (៣) ដូចគ្នា ប៉ុន្តែគ្រាន់តែតាមរយៈមធ្យោបាយនៃការពន្យារពេលវេលាដែលមិនអាចជៀសបាន ដែលតម្រូវ ឱ្យសម្រេចលើសំណុំរឿង ០០២/០១ ប្រសិនបើវិសាលភាពរឿងក្តីនេះត្រូវបានពង្រីកក៏ដោយក្តី។ អង្គជំនុំ ជម្រះតុលាការកំពូលពិចារណាឃើញថា ការពន្យារថិរវេលានៃការជំនុំជម្រះដើម្បីរៀបចំបទចោទប្រកាន់ ដែលមិនទាន់ជំនុំជម្រះ មិនមែនជាការពន្យារពេលក្នុងន័យពិចារណាអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ឆាប់រហ័សនោះទេ។ សូម្បីតែមេធាវីការពារក្តី ក៏មិនយល់ឃើញបែបនេះផងដែរ[124]។ ប៉ុន្តែ ភាពអន្តរាយ ចំពោះការជំនុំជម្រះឱ្យបានឆាប់រហ័ស កើតចេញពីការពន្យារសំណុំរឿង ០០២/០២ រហូតទាល់តែអង្គជំនុំ ជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើសំណុំរឿង ០០២/០១ ដែលជាចំណុចមួយ មិនត្រូវបានលើក យកមកពិភាក្សានៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នោះទេ។ ស្រដៀងគ្នានេះដែរ មិនមានការ ពិភាក្សាអំពីលទ្ធភាពប៉ះពាល់ដល់សិទ្ធិរបស់សហជនជាប់ចោទ ដែលបង្កឡើងដោយភាពលំអៀងរបស់ តុលាការជាក់ស្តែង ឬតាមការយល់ឃើញនៅក្នុងការជំនុំជម្រះបន្តបន្ទាប់ ប្រសិនបើក្រោយមកមានការ ផ្តន្ទាទោសនៅក្នុងសំណុំរឿង ០០២/០១។

47. កត្តាដែលត្រូវបានពិភាក្សាដោយត្រួសៗនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ពាក់ព័ន្ធនឹងលទ្ធ ភាពប៉ះពាល់ដល់រឿងក្តីរបស់ព្រះរាជអាជ្ញា ដែលការបំបែកកិច្ចដំណើរការនីតិវិធី អាចធ្វើឱ្យលំបាកដល់ លទ្ធភាពរបស់សហព្រះរាជអាជ្ញាក្នុងការបំពេញនូវភស្តុតាងដាក់បន្ទុកអំពីការចោទប្រកាន់ដែលទាក់ទិននឹង ធាតុផ្សំសត្យានុម័ត ដែលត្រូវបានបំបែក៖

> អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិសាលភាពនៃសំណុំរឿង ០០២/០១ ដូចដែលសហព្រះរាជ អាជ្ញាស្នើឡើង ពុំបង្កើតបានជាបទចោទ និងការចោទប្រកាន់ផ្អែកអង្គហេតុ “កម្រិតអប្បបរមាដែលពុំ អាចកាត់បន្ថយបាន” ដូចរៀបរាប់ក្នុងក្របខណ្ឌនៃរឿងក្តី *Haradinaj* ដែលការកាត់បន្ថយនោះ ធ្វើឱ្យ ប៉ះពាល់ដល់លទ្ធភាពរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញភស្តុតាងអំពីវិសាលភាពនៃការវាយ

[124] *សូមមើល ឧទា.* បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៥។

ប្រហារជាប្រព័ន្ធ ឬជាទូទៅ ដែលត្រូវបានចោទប្រកាន់ និងសហឧក្រិដ្ឋកម្មរួមនោះឡើយ។ ពីដើម ដំបូង អង្គជំនុំជម្រះបានសម្រេចថា ភាគីទាំងអស់អាចបង្ហាញភ័ស្តុតាងទាក់ទងនឹងតួនាទី និងការទទួល ខុសត្រូវរបស់[សហ]ជនជាប់ចោទ ទាក់ទងនឹងគោលនយោបាយនៃរបបខ្មែរក្រហម។ គ្មានអ្វីដែល រារាំងមិនឱ្យសហព្រះរាជអាជ្ញាប្រើប្រាស់ភស្តុតាងច្រើនឱ្យអស់លទ្ធភាព ដែលមាននៅចំពោះមុខ អង្គជំនុំជម្រះទាក់ទងនឹង ស-២១ ឡើយ ក្នុងកម្រិតដែលពាក់ព័ន្ធនឹងថ្នាក់ដឹកនាំ ឬរចនាសម្ព័ន្ធទំនាក់ ទំនងការងារ ឬសំណុចសំខាន់ទូទៅផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០១ នោះទេ[125]។

អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញា ពុំបានលើកឡើងអំពីលទ្ធភាពក្នុង ការបង្ហាញភស្តុតាង នៅក្នុងសំណុំរឿងនេះទេ ដូចដែលត្រូវបានបំបែកនៅក្នុងបណ្តឹងសាទុក្ខបច្ចុប្បន្នរបស់ ខ្លួននោះទេ ហើយអាស្រ័យហេតុនេះ អង្គជំនុំជម្រះចាត់ទុកថាជាការលើកឡើងមិនត្រឹមត្រូវដើម្បីពិភាក្សា លើលក្ខខណ្ឌភស្តុតាងនៃសំណុំរឿង។

48. កត្តានានាដែលមិនត្រូវបានលើកយកមកពិភាក្សាទាល់តែសោះ គឺបន្ទុកភស្តុតាងលើសាក្សី និងការ ចង់បានដើម្បីជៀសវាងភាពមិនស៊ីសង្វាក់គ្នានៃការជំនុំជម្រះដាច់ដោយឡែកពីគ្នា។ ទោះបីជាយ៉ាងណាក៏ ដោយ អង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូង ពុំបានលើកឡើងច្បាស់លាស់អំពីកត្តាទាំងនេះនៅក្នុងការ បំបែកសំណុំរឿង ០០២ ជាថ្មីនេះ មិនមែនមានន័យសំខាន់ថា អង្គជំនុំជម្រះមិនបានយកកត្តាទាំងនេះមក ពិចារណានោះទេ។ អង្គជំនុំជម្រះសាលាដំបូង ពុំតម្រូវឱ្យបញ្ជាក់ឱ្យច្បាស់អំពីវិធីទាំងអស់នៃសំអាងហេតុ របស់ខ្លួននៅក្នុងសេចក្តីសម្រេចរបស់ខ្លួននីមួយៗនោះទេ[126] ដរាបណាការផ្តល់នូវសំអាងហេតុ មាន លក្ខណៈច្បាស់លាស់គ្រប់គ្រាន់។

49. កត្តា (៥) គឺជាទឡ្ហីករណ៍ដែលលើកឡើងថ្មីមួយ ដែលសំអាងលើ"ការព្រួយបារម្ភអំពីបញ្ហាហិរញ្ញ វត្ថុរបស់ អ.វ.ត.ក" ដែលបង្កប់ន័យថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការរក្សាវិសាល ភាពដើមនៃការជំនុំជម្រះដំបូង គឺជាការបង្ខំពេលវេលា ពោលគឺការចង់បានចេញសាលក្រមមុនពេលដែល អ.វ.ត.ក អាចនឹងលែងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ[127]។ ផ្អែកលើសំអាងហេតុដែលនឹងត្រូវបានលើក ឡើងពេញលេញកាន់តែច្បាស់ខាងក្រោម អង្គជំនុំជម្រះតុលាការកំពូល ចាត់ទុកភាពមិនប្រាកដប្រជារបស់ ប្រទេសម្ចាស់ជំនួយក្នុងការផ្តល់ថវិកាដល់ អ.វ.ត.ក ថា ជាកត្តាមិនពាក់ព័ន្ធ និងមិនសមហេតុផល ក្នុងការ

---

[125] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១១៧ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

[126] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៦ *និងសេចក្តីយោងដែលដកស្រង់នៅទីនោះ*។

[127] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៤៦។ *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២៥(៥)។

ពិចារណានៅក្នុងកិច្ចដំណើរការធ្វើការសម្រេចចិត្តរបស់តុលាការនាពេលបច្ចុប្បន្ន នៅចំពោះមុខ អ.វ.ត.ក[128]។

50. ជាសេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានការផ្លាស់ប្តូរមួយនៅក្នុងយុត្តិកម្មរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ការបំបែកសំណុំរឿង ០០២ ជាថ្មីនេះ។ ដោយហេតុថា វិសាលភាព និងភាពស្មុគស្មាញនៃសំណុំរឿង ០០២ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឱ្យអង្គជំនុំជម្រះសាលាដំបូងបំបែកកិច្ចដំណើរការនីតិវិធី ឱ្យក្លាយជាការជំនុំជម្រះឆាប់រហ័ស ប្រសិទ្ធភាព និងគ្រប់គ្រងបាន នៅពេលដែលចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ លើកទីមួយ[129] នៅត្រង់ចំណុចនេះ កត្តាដែលអង្គជំនុំជម្រះសាលាដំបូងផ្អែកលើដើម្បីចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២លើកទីពីរ បង្ហាញថា អង្គជំនុំជម្រះមានហេតុផលជឿជាក់ថា ការចោទប្រកាន់ទាំងអស់នៅក្នុងដីកាដំណោះស្រាយ មិនអាច ឬនឹងមិនសម្រេចបានទេ បើពិចារណាលើវ័យចាស់ជរា និងភាពទ្រុឌទ្រោមផ្នែករូបរាងកាយកាន់តែខ្លាំងរបស់សហជនជាប់ចោទ[130]។ គោលបំណងដែលលើកឡើងម្តងហើយម្តងទៀតរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការសម្រេចចិត្តលើការបំបែកសំណុំរឿង០០២ជាថ្មីនេះ គឺការរក្សានូវលទ្ធភាពដើម្បីចេញ "សាលក្រមឱ្យទាន់ពេលវេលា"[131]។

51. អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា នៅពេលដែលបញ្ជាក់ច្បាស់លាស់ គោលបំណងបែបនេះ ត្រូវបានរួមបញ្ចូលតាមរយៈសញ្ញាណនៃ "ផលប្រយោជន៍យុត្តិធម៌"ដោយក្នុងនោះ គោលដៅបែបនេះ

---

[128] *សូមមើលខាងក្រោម* កថាខណ្ឌ ៧៥។

[129] *សូមមើល*សេចក្តីសម្រេចរបស់អ.ជ.ត.ក កថាខណ្ឌ។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៨ ដល់ ៩ *ហើយ ជាពិសេស* កថាខណ្ឌ ១០ ("អង្គជំនុំជម្រះសាលាដំបូង នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ត្រូវជំរុញទឹកចិត្តធ្វើឡើយដោយ គោលបំណងដូចតទៅ: បំបែកសំណុំរឿង ០០២ ទៅជាផ្នែកៗដែលងាយស្រួលចាត់ចែងដែល ចំណាយពេលខ្លីក្នុងការសម្រេច, ធានាថា ការជំនុំជម្រះលើកទីមួយ ត្រូវរួមបញ្ចូលការពិនិត្យយ៉ាងល្អិតល្អន់នូវបញ្ហាជាមូលដ្ឋាន និងការចោទប្រកាន់នានាលើជនជាប់ចោទទាំងអស់, ផ្តល់ជាមូលដ្ឋានសម្រាប់ការពិនិត្យយ៉ាងល្អិតល្អន់បន្ថែមទៀត ដល់បទចោទដែលនៅសេសសល និងការចោទប្រកាន់លើអង្គហេតុប្រឆាំងនឹងជនជាប់ចោទ នៅក្នុងការជំនុំជម្រះលើកក្រោយៗទៀត, បន្តគ្នាជាលំដាប់លំដោយតាមដីកាដំណោះ (ប្រហាក់ប្រហែលក្នុងអំឡុងពេល ១៩៧៥ ដល់ ១៩៧៦), ធានាថា បញ្ហាទាំងនេះដែលត្រូវបានពិនិត្យ នៅក្នុងការជំនុំជម្រះលើកទីមួយ នឹងផ្តល់ជាមូលដ្ឋានសម្រាប់ធ្វើការពិចារណាអំពីទម្រង់នៃការទទួលខុសត្រូវនៃបទឧក្រិដ្ឋស្តីពីសហឧក្រិដ្ឋកម្មរួម ដោយបានរួមបញ្ចូលជនជាប់ចោទទាំងអស់, និងជ្រើសរើសការចោទប្រកាន់ផ្នែកអង្គហេតុទាំងនោះ ដែលប៉ះពាល់ដល់ជនរងគ្រោះជាច្រើន")។

[130] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៨៦, ១២៥(១)។

[131] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៤, ៤១, ៨៦, ១២២, ១៣៧, ១៤៩, ១៦១, ទំព័រ ៧០។ *សូមមើលផងដែរ* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ១២៥(២)។

អាចសំខាន់ជាងការព្រួយបារម្ភផ្សេងទៀត។ ស្ថិតនៅក្នុងដែនកំណត់នៃអត្ថប្រយោជន៍យុត្តិធម៌ដូចដែលបានបញ្ជាក់ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដែលសម្រេចឱ្យរឿងក្តីនេះបំបែកចេញជាការជំនុំជម្រះដាច់ដោយឡែកនោះ គឺមានលក្ខណៈទូលំទូលាយ[132] ហើយ ហេតុដូច្នេះ មានបន្ទុកច្រើនទៅលើម្ចាស់បណ្តឹងសាទុក្ខក្នុងការបង្ហាញការរំលោភបំពានណាមួយនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ ដែលបណ្តាលឱ្យប៉ះពាល់លើរូបគាត់។ ការវាយតម្លៃធាតុផ្សំដែលពាក់ព័ន្ធនឹងកត្តាពន្លឿនដំណើរការនីតិវិធី ជាពិសេសដូចជាបញ្ហាសុខភាពរបស់សហជនជាប់ចោទ និងដំណាក់កាលដែលអង្គជំនុំជម្រះសាលាដំបូងអាចដំណើរការនីតិវិធី ពិតជាត្រូវការនូវឆន្ទានុសិទ្ធិយ៉ាងច្រើនណាស់។ ដោយសារតែបាត់បង់នូវជនជាប់ចោទចំនួនពីររូប អៀង ធីរិទ្ធ និង អៀង សារី ដោយសារតែមូលហេតុបញ្ហាគ្មានសម្បទាគ្រប់គ្រាន់ និងមរណភាព[133] ការជួបប្រទះជាមួយនឹងការបង្អាក់ការជំនុំជម្រះជាច្រើនលើកច្រើនសារដោយសារតែពាក់ព័ន្ធនឹងសុខភាព និងភាពចាស់ជរានៃជនជាប់ចោទដែលនៅមានជីវិត[134] ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកដីកាចោទប្រកាន់ ដើម្បីធានាថា យ៉ាងហោចណាស់ផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវជំនុំជម្រះនៅក្នុងពេលរស់រានមានជីវិតរបស់សហជនជាប់ចោទនោះ គឺមានលក្ខណៈសមហេតុផល។

52. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលលើកឡើងថា ការបំបែកសំណុំរឿង០០២ជាថ្មី គឺចាំបាច់សម្រាប់ផលប្រយោជន៍យុត្តិធម៌ មិនចាំបាច់ឱ្យមានការអន្តរគមន៍ប្តឹងសាទុក្ខ។ ទាក់ទងនឹងទឡ្ហីករណ៍ផ្សេងទៀតរបស់ នួន ជា ត្រង់ចំណុចការរារាំងមិនឱ្យបង្ហាញភស្តុតាង ក្នុងសំណុំរឿងសម្រាប់មេធាវីការពារក្តីប្រឆាំងនឹងសាវតាអង្គហេតុទូលំទូលាយ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់លើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលលើកឡើងថា "គ្មានអ្វីដែលរារាំងមិនឱ្យសហព្រះរាជអាជ្ញាប្រើប្រាស់ភស្តុតាងច្រើនឱ្យអស់លទ្ធភាព ដែលមាននៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងមន្ទីរ ស-២១ ឡើយ ក្នុងកម្រិតដែលពាក់ព័ន្ធនឹងថ្នាក់ដឹកនាំ ឬរចនាសម្ព័ន្ធទំនាក់ទំនងការងារ ឬចំណុចសំខាន់ទូទៅផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០១ នោះទេ"[135]។ អាស្រ័យហេតុនេះ នួន ជា ទទួលបាននូវលទ្ធភាពដូចគ្នា ក្នុងការបង្ហាញភស្តុតាង។

---

[132] *សូមមើល* សេចក្តីសម្រេចរបស់អ.ជ.ត.ក កថាខណ្ឌ ៣៥, ៤០។

[133] *សូមមើល ខាងលើ* ជើងទំព័រ ៥។

[134] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២៨-១៣២។

[135] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៧។

00964369



53. យោងតាមសំអាងហេតុខាងលើ សំណើសុំរបស់ នួន ជា ដែលស្នើសុំឱ្យបដិសេធចោលសេចក្តីសម្រេចបំបែកសំណុំរឿង ០០២ លើកទីពីរ ត្រូវបានបដិសេធចោល។

## ខ. ការភ័ន្តច្រឡំដែលចោទប្រកាន់នៅក្នុងទម្រង់នៃសេចក្តីសម្រេចបំបែកសំណុំរឿង០០២ លើកទីពីរ

54. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងការប្រកាសអសុពលភាពនៃសេចក្តីសម្រេចបំបែកសំណុំរឿង០០២ លើកទីមួយ ការបំបែកថ្មីនេះ គឺមានភាពចាំបាច់សម្រាប់បង្កើតផែនការច្បាស់លាស់ជាក់ស្តែងសម្រាប់ការជំនុំជម្រះលើបទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការពិចារណាសមស្របទៅលើការតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅជាការជំនុំជម្រះតូចជាងនេះ[136]។ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសញ្ញាណនៃ"ការតំណាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"ថា "គ្មានន័យ"[137] ដោយបានអះអាងបញ្ជាក់ថា "រាល់បទចោទទាំងអស់ នឹងត្រូវធ្វើការជំនុំជម្រះ លើកលែងតែ ជនជាប់ចោទគ្មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ឬកិច្ចដំណើរការនីតិវិធីទាំងនេះត្រូវបញ្ចប់នូវពេលជនជាប់ចោទទទួលមរណភាព"[138]។ ទោះជាយ៉ាងណាក្តី នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុវត្តនូវលក្ខណៈវិនិច្ឆ័យនេះសម្រាប់ធ្វើការលើកជាទឡ្ហីករណ៍ ខ្លួនបានធ្វើការសន្និដ្ឋាន ថា ការដាក់បន្ថែមនូវមន្ទីរ ស-២១ លើវិសាលភាពនៃការជំនុំជម្រះលើកទីមួយ ពុំមាន"ភាពចាំបាច់ដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យណាមួយនៃភាពជាតំណាងដ៏សមហេតុផលឡើយ"[139] និងបានពិចារណាឃើញថា ការដាក់បញ្ចូលទួលពោធិ៍ជ្រៃទៅក្នុងវិសាលភាពដំបូងនៃសំណុំរឿង ០០២/០១ គឺបានបំពេញលក្ខខណ្ឌ"នៅក្នុងកាលៈទេសៈដែលជាប់ពាក់ព័ន្ធទាំងអស់"[140]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមបន្តកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១ ត្រង់ចំណុចដែលខ្លួនបានធ្វើកន្លង ត្រឹមពេលដែល អ.ជ.ត.ក បានចេញសេចក្តីសម្រេចរបស់ខ្លួន[141] ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួនសម្រេចមិនបញ្ចូលបទចោទបន្ថែមណាមួយ "ដោយហេតុថា អង្គជំនុំជម្រះ

---

[136] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០។

[137] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨៨។

[138] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨៨។

[139] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៦។ *សូមមើលផងដែរ* សេក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២២ និង ១៤៧។

[140] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៨។

[141] សេចក្តីចសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧០។

អាចប្រឈមនឹងបញ្ហាជាច្រើនដែលមិនអាចជំនះបាន នៅក្នុងការជ្រើសរើសដោយយុត្តិធម៌ និងសមធម៌ រវាងចំណុចនានាជាច្រើន ដែលស័ក្តិសមដូចៗគ្នា សម្រាប់ដាក់បញ្ចូលទៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះ”[142]។

55. អង្គជំនុំជម្រះសាលាដំបូងក៏បានប្រកាសថា អង្គជំនុំជម្រះ“នៅមិនច្បាស់ថា ការព្យាករណ៍ទៅលើការជំនុំជម្រះនាពេលអនាគត អាចរៀបចំផែនការប្រកបដោយអត្ថន័យបាននោះទេ”[143] និងបដិសេធមិនដោះស្រាយបញ្ហាត្រង់ចំណុច ថាតើការជំនុំជម្រះបន្តបន្ទាប់អាចនឹងធ្វើឡើង ដែរ ឬយ៉ាងណា និងជាពិសេសថាតើនៅពេលណា ដែលការជំនុំជម្រះលើកទីពីរ នៅក្នុងសំណុំរឿង០០២ (“សំណុំរឿង ០០២/០២”) អាចនឹងចាប់ផ្តើមនោះ[144]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំ“ឲ្យមានកិច្ចប្រជុំរៀបចំសវនាការមួយនៅចុងឆ្នាំនេះ នៅពេលបញ្ហានានាតម្រូវឲ្យមានការពិនិត្យមើលឡើងវិញ ដោយសារតែការកែប្រែស្ថានភាពនានា ដែលអាចកើតមាន”[145]។ អង្គជំនុំជម្រះបានប្រកាសបន្ថែមទៀតថា “មិនមានឧបសគ្គចំពោះការជំនុំជម្រះក្តីនាពេលខាងមុខលើជនជាប់ចោទសំណុំរឿង ០០២ ដែលនៅសល់ទាក់ទងនឹងការចោទប្រកាន់លើអង្គហេតុ ឬបទចោទនានាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០២ ទេ ដរាបណាជនជាប់ចោទនៅមានសម្បទាគ្រប់គ្រាន់ ហើយ អ.វ.ត.ក នៅបន្តទទួលបានថវិកាពីប្រទេសផ្តល់ជំនួយ ដើម្បីគាំទ្រដល់ការកាត់សេចក្តីនេះ នាពេលអនាគត”[146]។

56. សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានពិចារណាឲ្យបានត្រឹមត្រូវទៅលើតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានតម្រូវឡើយ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវបទដ្ឋានផ្នែកច្បាប់របស់ខ្លួនដែលមានកំហុសឆ្គង[147]។ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងបន្ថែមទៀត ដោយបាន“រក្សានូវទំរង់ដែលពុំមានភាពច្បាស់លាស់ថា ជនជាប់ចោទនឹងត្រូវដាក់ឲ្យទទួលនូវការជំនុំជម្រះក្តីជាបន្តបន្ទាប់នាពេលអនាគត”[148] និងដោយបាន“បដិសេធមិនយល់ស្របតាម

---

[142] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៩។

[143] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៣។

[144] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៤-១៥៥។

[145] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៥។

[146] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៥។

[147] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ២០-២៣។

[148] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ២៤។

និងមិនទទួលស្គាល់ថា សេចក្តីសម្រេចរបស់ខ្លួនបានច្រានច្រោលយ៉ាងមានប្រសិទ្ធភាពនូវការចោទប្រកាន់ (ភាគច្រើន) ប្រឆាំងនឹងជនជាប់ចោទនៅក្នុងសំណុំរឿងលេខ០០២"[149]។ បន្ថែមពីនេះទៀត សហព្រះរាជអាជ្ញាក៏បញ្ជាក់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលភាពជាប់ពាក់ព័ន្ធនៃបទដ្ឋានច្បាប់អន្តរជាតិ ដែលអាចប្រៀបធៀបបានស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ហើយមានកំហុសឆ្គងនៅក្នុងអង្គហេតុ និងអង្គច្បាប់ ដោយខកខានក្នុងការពិចារណាត្រឹមត្រូវទៅលើកាលៈទេសៈ និងកត្តាជាប់ពាក់ព័ន្ធដែលគួរតែយកមកថ្លឹងថ្លែងនៅក្នុងការវាយតម្លៃលើការបំបែកការចោទប្រកាន់[150]។ សហព្រះរាជអាជ្ញាបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង ក៏បានច្រានចោលសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងការអនុវត្តផ្ទាល់នូវទស្សនទានអំពីតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក[151] ហើយក៏មានកំហុសឆ្គងដោយបានសន្និដ្ឋានថា ការដាក់បញ្ចូលបន្ថែមមន្ទីរ ស-២១ នឹងធ្វើឲ្យការជំនុំជម្រះក្តី ត្រូវបានពន្យារពេលដោយមិនសមហេតុផល[152]។ សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា លទ្ធផលគឺថា ឧក្រិដ្ឋកម្មដែលត្រូវបានបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ គឺមិនតំណាងគ្រប់គ្រាន់ឲ្យដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ ប៉ុន្តែស្ថានភាពមួយនេះដែលអាចត្រូវកែតម្រូវបានគ្រប់គ្រាន់តាមរយៈការដាក់បន្ថែមមន្ទីរ ស-២១ ដោយសហព្រះរាជអាជ្ញាអះអាងថា មន្ទីរ ស-២១ គឺជាតំណាងទីកន្លែងឧក្រិដ្ឋកម្មសំខាន់ជាងគេនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[153]។ សហព្រះរាជអាជ្ញាអះអាងថា ការភ័ន្តច្រឡំអង្គច្បាប់ និងអង្គហេតុទាំងនេះតម្រូវឲ្យមានការដាក់បញ្ចូលមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីបញ្ចៀសនូវភាពអយុត្តិធម៌[154]។

57. នួន ជា យល់ស្រប ថា វិសាលភាពនៃសំណុំរឿង ០០២/០១ បង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង មានកង្វះខាតយ៉ាងច្រើនអំពីតំណាងសមហេតុផលនៃដីកាញ្ជូនរឿងទៅជំនុំជម្រះ ហើយក៏យល់ស្រប

---

[149] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ២៧។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ កថាខណ្ឌ ២៤។

[150] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ២៨-៣៤ *ដោយយោងទៅលើ* វិធាន ៧៣*ស្ទួន* (ឃ)នៃ វិធានផ្ទៃរបស់ ICTY ព្រមទាំងយុត្តិសាស្ត្ររបស់តុលាការនេះ។

[151] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ២៥។

[152] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ៥១-៧៥។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧ ដល់ ៣០។

[153] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ៣៥-៥០។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧-២៦ និងកថាខណ្ឌ ៣១។

[154] បណ្តឹងសាទុក្ខរបស់សហព្រះអាជ្ញា កថាខណ្ឌ ៥០។

ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយមិនបានពិចារណាទៅលើសេចក្តីណែនាំ និងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីឡើងវិញ[155]។ ទោះបីជាយ៉ាងណាក៏ដោយ គាត់ជំទាស់ទៅនឹងការយល់ឃើញរបស់សហព្រះរាជអាជ្ញា ដែលថា មន្ទីរ ស-២១ គឺជាតំណាងពិសេសនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូច្នេះហើយទើបគាត់គាំទ្រសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនបញ្ចូលមន្ទីរ ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[156]។ គាត់បញ្ជាក់ថា ជាអប្បបរមា អង្គជំនុំជម្រះសាលាដំបូង គួរតែបញ្ចូលការចោទប្រកាន់ផ្សេងៗទាក់ទងនឹងអំពើប្រល័យពូជសាសន៍ និងតំណាងការចោទប្រកាន់ដែល កើតចេញពីសហករណ៍ និងការដ្ឋាន ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/១ វិញ ដើម្បីឱ្យមានតំណាងសមហេតុផលនៃដីកាដំណោះស្រាយទាំងមូលនៅក្នុងសំណុំរឿង ០០២[157]។ សហព្រះរាជអាជ្ញា មិនយល់ស្របនោះទេ[158]។

58. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលសូមបញ្ជាក់ថា នៅពេលដែលខ្លួនប្រកាសអំពីមោឃភាពនៃការបំបែកដំណើរការនីតិវិធីលើកទីមួយក្នុងសំណុំរឿង ០០២ ដោយពុំមានការប៉ះពាល់ការវាយតម្លៃលើដីកាសម្រេចឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលសម្រេចបែបនេះ ជំនួសការអនុវត្តន៍នូវយុត្តាធិការកែតម្រូវរបស់ខ្លួន ដោយបានយល់ឃើញអំពីការគោរពដែលត្រូវតែផ្តល់ទៅឱ្យអង្គជំនុំជម្រះសាលាដំបូង ក្នុងឋានៈជាអ្នកចាត់ចែងបឋមលើសំណុំរឿង ០០២ ដើម្បីឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល។

59. សេចក្តីណែនាំមួយ ដែលបានចែងក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល គឺ“ការពិចារណាលើលទ្ធភាពក្នុងការបំបែករឿងក្តីព្រហ្មទណ្ឌមួយ ដែលក្រោយពេលសំណុំរឿងនេះត្រូវបានបំបែករួចហើយនោះ ត្រូវតែជាតំណាងនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះយ៉ាងសមស្រប ជាពិសេស នៅពេលដែលមានការព្រួយបារម្ភជាក់ស្តែងអំពីការ ដែលមានរឿងក្តីលើសពីមួយ ដែលត្រូវឈានដល់ការចេញសាលក្រមមួយលើអង្គសេចក្តី ការពិចារណានេះ ត្រូវបានតម្រូវដោយសុភវិនិច្ឆ័យរួម និងដោយអត្ថប្រយោជន៍យុត្តិធម៌ប្រកបដោយអត្ថន័យ ហើយស្របទៅតាមបទដ្ឋានគតិយុត្តអន្តរជាតិដែលប្រហាក់ប្រហែល”[159]។ ជា

[155]បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨-៣៧។

[156] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦-៨៣។

[157] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១ កថាខណ្ឌ ៣៨-៥៥ និងកថាខណ្ឌ ៨៤។ *សូមមើលផងដែរ* សារណាបន្ថែមចំពោះ បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១-៦។

[158] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១-៤០។

[159] សេចក្តីសម្រេចតុលាការកំពូល ICTY កថាខណ្ឌ ៤២ *យោងលើ* វិធាន ៧៣*ស្ទួន* (ឃ) នៃវិធានតុលាការ ICTY។

ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅលើវិធាន ៧៣*ស្ទួន* (ឃ) នៃវិធានតុលាការ ICTY[160] ដែលផ្នែកពាក់ព័ន្ធចែងថា "បន្ទាប់ពីបានស្តាប់អយ្យការ ដើម្បីធានាការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងអាចស្នើសុំឲ្យអយ្យការកាត់បន្ថយចំនួនបទចោទដែលខ្លួនបានចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយបន្ទាប់ពីបានពិចារណាលើកាលៈទេសៈពាក់ព័ន្ធទាំងអស់រួចមក អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចយកទីតាំងឧក្រិដ្ឋកម្មមួយចំនួន ឬឧប្បត្តិហេតុមួយចំនួននៅក្នុងបទចោទមួយ ឬច្រើន ដែលអយ្យការអាចបង្ហាញថាមានភស្តុតាងពាក់ព័ន្ធនឹងបទចោទនេះ ដោយរួមបញ្ចូលនូវបទឧក្រិដ្ឋដែលបានចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំណាត់ថ្នាក់និងចរិតលក្ខណៈរបស់បទឧក្រិដ្ឋនេះ ទីកន្លែងដែលគេចោទប្រកាន់ថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង វិសាលភាពនិងជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនោះ បទចោទនេះគឺជាតំណាងដ៏សមស្របនៃឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់"[161]។

60. ការច្រានចោលសញ្ញាណនៃ"*ភាពជាតំណាងក្នុងដីកាបញ្ជូនទៅជម្រះ*" ថា"*គ្មានអត្ថន័យ*"[162] អង្គជំនុំជម្រះសាលាដំបូងបានបដិសេធភាពអាចប្រៀបធៀបបាន និងភាពពាក់ព័ន្ធនៃវិធាន ៧៣*ស្ទួន*(ឃ) របស់វិធានតុលាការ ICTY ទៅនឹងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដូចខាងក្រោម៖

> តាមក្របខណ្ឌច្បាប់ អ.វ.ត.ក ដីកាបញ្ជូនរឿងទីជម្រះគឺជាលទ្ធផលនៃសេចក្តីសម្រេចតុលាការ ហើយវាជាសេចក្តីសម្រេចបិទផ្លូវតវ៉ានៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលដីកាបញ្ជូនរឿងទៅជម្រះនេះ។ សហព្រះរាជអាជ្ញាគ្មានអំណាចដកចេញផ្នែកណាមួយនៃដីកាបញ្ជូនរឿងទៅជម្រះ ហើយអង្គជំនុំជម្រះសាលាដំបូងក៏មិនអាចប្រើដីកាសម្រេចបំបែកដំណើរការនីតិវិធីដើម្បីបន្ថយ ឬពង្រីកបទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ឡើយ។ គោលបំណងតែមួយគត់នៃការបំបែកដំណើរការនីតិវិធី ក្នុងដំណាក់កាលជំនុំជម្រះ គឺដើម្បីកែតម្រូវវិធីនៃការជំនុំជម្រះការចោទប្រកាន់ទាំងអស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការចោទប្រកាន់ដែលតាមធម្មតាអាចត្រូវបានជំនុំជម្រះក្នុងការជំនុំជម្រះតែមួយលើក ត្រូវបានបំបែក សំរាប់ធ្វើសវនាការក្នុងការជំនុំជម្រះពីរ ឬច្រើន ប៉ុន្តែគ្មានការ

---

[160] *សូមមើល*សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ជើងទំព័រ ១០៧។ *សូមមើលផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ជើងទំព័រ ៩៥។

[161] *សូមមើលផងដែរ* វិធាន ៧៣*ស្ទួន*(ផ) នៃវិធានរបស់តុលាការ SCSL ("ដើម្បីធានាការជំនុំជម្រះប្រកបដោយយុត្តិធម៌និងឆាប់រហ័ស បន្ទាប់ពីបានស្តាប់ភាគីរួច អង្គជំនុំជម្រះសាលាដំបូងអាចណែនាំអយ្យការនៅពេលណាក៏បាន ឲ្យកាត់បន្ថយបទចោទដែលត្រូវបានចោទប្រកាន់។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងអាចកំណត់ចំនួនទីតាំងឧក្រិដ្ឋកម្ម ឬអង្គហេតុដែលស្ថិតនៅក្នុងការចោទប្រកាន់មួយ ឬច្រើនរបស់អយ្យការ ដែលអាចចាត់ទុកជាតំណាងនៃបទឧក្រិដ្ឋទាំងឡាយបានយ៉ាងសមស្រប។

[162] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៩៩។

កែប្រែការចោទប្រកាន់ដែលខុសពីនេះឡើយ។ តាមផ្លូវច្បាប់ ការបំបែកកិច្ចដំណើរការនីតិវិធីគឺជាវិធីរៀបចំសវនាការសុទ្ធសាធ និងដោយសារគ្មានយន្តការដកការចោទប្រកាន់ចេញដីកាបញ្ជូនរឿងទៅជម្រះ តុលាការត្រូវជំនុំជម្រះការចោទប្រកាន់ទាំងអស់ ទោះបីជាជនជាប់ចោទបាត់បង់សម្បទាក្នុងការទទួលការជំនុំជម្រះ ឬដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយមរណភាពរបស់ជនជាប់ចោទក៏ដោយ[163]។

61. អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា តាមពិត គ្មានវិធានណាមួយក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលអនុត្តចំពោះ អ.វ.ត.ក ចែងពីលទ្ធភាពឱ្យតុលាការដក ឬបញ្ចប់ការចោទប្រកាន់ណាមួយក្នុងដីកាបញ្ជូនរឿងទៅជម្រះទេ កាលណាតុលាការបានទទួលយករឿងក្តីទៅជំនុំជម្រះរួចហើយ។ ដូចបានកត់សំគាល់ខាងដើម នេះជាលទ្ធផលនៃនីតិវិធីកម្ពុជា ដែលឆ្លុះបញ្ចាំងពីគោលការណ៍នីត្យានុកូលភាពបារាំង (ការចោទប្រកាន់ជាលក្ខខណ្ឌចាំបាច់)[164]។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សំគាល់ខាងដើមផងដែរ ភាពអាចអនុវត្តបាននៃគោលការណ៍នីត្យានុកូលភាពចំពោះដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ អាចជំទាស់តវ៉ាបាន[165]។ នៅសាលាក្តីអន្តរជាតិ ឬសាលាក្តីចំរុះព្រហ្មទណ្ឌ

---

[163] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៩៨។

[164] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យដោះលែងដោយឥតលក្ខខណ្ឌលើជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E138/1/10/1/5/7, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល លើ អៀង ធីរិទ្ធ"), កថាខណ្ឌ ៣៧ ដល់ ៣៨។ ក្នុងការអនុវត្តតាមគោលការណ៍នីត្យានុកូលភាពបារាំង, *សូមមើល* MERLE និង VITU, *Traité de droit criminel*, T. II, 4th ed, Cujas, Paris 1989, កថាខណ្ឌ ២៧៨ ដល់ ២៧៩ និង ២៨៣ (សេចក្តីពន្យល់ថា នៅប្រទេសបារាំង អយ្យការពុំមានឆន្ទានុសិទ្ធិក្នុងការបញ្ឈប់ ឬស្នើសុំធ្វើការបញ្ឈប់នូវបណ្តឹងព្រហ្មទណ្ឌ នៅពេលណាដែលបណ្តឹងនេះ ត្រូវបានចាប់ផ្តើម ហើយមានតែតុលាការមួយប៉ុណ្ណោះដែលអាចបញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌបាន ដោយសារហេតុផលមួយក្នុងចំនោមហេតុជាច្រើន មានចែងយ៉ាងច្បាស់នៅក្នុងច្បាប់), ត្រូវបានដក់ស្រង់នៅក្នុងសេចក្តីសម្រេចទីពីររបស់ អ.ជ.ត.ក លើ អៀង ធីរិទ្ធ កថាខណ្ឌ ៣៧។ RIBEYRED, *Jurisclasseur,* Fasc. 20: Action publique et action civile, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ៥២ ដល់ ៥៣: តុលាឧទ្ធរណ៍ទីក្រុងប៉ារីស ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២ (នៅពេលដែលតុលាឧទ្ធរណ៍បានរកឃើញថា តុលាការជាន់ដំបូង បានសម្រេចលើបទចោទ ដោយពុំបានពិចារណាទៅលើសំណើសុំផ្ទាល់មាត់របស់អយ្យការ សុំបញ្ឈប់សំណុំរឿង ដោយសំអាងលើមាត្រា ៤៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលចែងថា នៅក្នុងផ្នែកដែលពាក់ព័ន្ធ នៅពេលដែលខ្លួនពិចារណាឃើញថា អង្គហេតុជាបទមជ្ឈឹម តុលាការសម្រេចដាក់ទោស) *ត្រូវបានអះអាងដោយ* សេចក្តីសម្រេចរបស់តុលាការកំពូល., សំណុំរឿងលេខ 12-80180, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣។ ការអនុវត្តនៃគោលការណ៍នេះនៅក្នុងច្បាប់កម្ពុជា អាចត្រូវបានធ្វើសេចក្តីសន្និដ្ឋានបានពីមាត្រា ៧, ៨, ២៤៧ នៃក្រម នីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CCPC") (ដែលបានរៀបរាប់យ៉ាងច្បាស់លាស់នូវហេតុសម្រាប់ការរំលត់នៃបណ្តឹងអាជ្ញា ហើយចែងអំពីកាតព្វកិច្ចរបស់ចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចរាល់អង្គហេតុដែលខ្លួនបានទទួល)។

[165] សេចក្តីសម្រេចលើកទីពីររបស់ អ.ជ.ត.ក លើ *រឿងក្តី* អៀង ធីរិទ្ធ កថាខណ្ឌ ៣៧។

ជាតិ និងអន្តរជាតិ ការចោទប្រកាន់ជាលក្ខខណ្ឌចាំបាច់ គឺកម្រិតត្រឹមតែផ្តល់ផលប្រយោជន៍ដល់ការចោទប្រកាន់ដែលមានលក្ខណៈជ្រើសរើសលើបុគ្គលមួយចំនួនក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត"[166] ដោយផ្តោតទៅលើ គោលនយោបាយ ដែលធ្វើឱ្យមានតុល្យភាពនូវគោលដៅនៃយុត្តិធម៌រឿង

[166] យុទ្ធសាស្ត្រនៃការជ្រើសរើសយកសំណុំរឿង គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាលំបាកបំផុតនៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌអន្តរជាតិ។ ការផ្តែកលើបទចោទដ៏ធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវបានចែងនៅក្នុងធម្មនុញ្ញនៃតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ មាត្រា ១ ("តុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ ត្រូវបានបង្កើតឡើង [...] ដើម្បីការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងឆាប់រហ័ស និងធ្វើការដាក់ទោសលើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃពួកអាក់ស៊ីសអឺរ៉ុប")។ ទោះបីជាលក្ខន្តិកៈរបស់តុលាការ ICTY និង ICTR ពុំបានចែងនូវកម្រិតអប្បបរមានៃការទទួលខុសត្រូវរបស់អ្នកដែលត្រូវទទួលការចោទប្រកាន់ក៏ដោយ ក៏ក្រុមប្រឹក្សាសន្តិសុខ បានអំពាវនាវដល់តុលាការទាំងពីរនេះ, "ធ្វើការពិនិត្យឡើងវិញ និងធ្វើការអះអាងការចោទប្រកាន់ថ្មី ដើម្បីធានាបានថាការចោទប្រកាន់នេះ ផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់ដែលត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ [...]"។ *សូមមើល*ក្រុមប្រឹក្សាសន្តិសុខ សេចក្តីសម្រេចលេខ ១៥០៣, Res/RES/1503 (2003), ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៣, បុព្វកថា, កថាខណ្ឌ 7, និងសេចក្តីសម្រេចលេខ ១៥៣៤, S/RES/1534 (2004), ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៣ និង៥ ("ក្រុមប្រឹក្សាសន្តិសុខ ... អំពាវនាវដល់តុលាការព្រហ្មទណ្ឌពិសេសនីមួយ ត្រូវពិនិត្យ និងបញ្ជាក់អះអាងនូវបទចោទថ្មី ដើម្បីធានាថា បទចោទទាំងនេះ ផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់ ដែលត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការនៃតុលាការព្រហ្មទណ្ឌពិសេសដែលពាក់ព័ន្ធ ដែលកំណត់នៅក្នុងសេចក្តីសម្រេច ១៥០៣ (២០០៣)")។ វិធានរបស់តុលាការ ICTY ត្រូវធ្វើវិសោធនកម្មជាថ្មីថា "ប្រធាន ត្រូវបញ្ជូនបញ្ហានេះទៅ Bureau ដែលនឹងត្រូវសម្រេចថា តើការចោទប្រកាន់ *តាមសេចក្តីបញ្ជាក់ដំបូង* ផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់បំផុតមួយ ឬច្រើនដែលត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតពីបទឧក្រិដ្ឋនៅក្នុងយុត្តិធិការរបស់តុលាការព្រហ្មទណ្ឌ"។ *សូមមើល* វិធាន ២៨(ក) នៃវិធានរបស់តុលាការ ICTY។ ទាក់ទងនឹងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន មាត្រា ១ នៃលក្ខន្តិកៈរបស់ខ្លួន ចែងថា "តុលាការពិសេស ត្រូវ [...] មានអំណាចចោទ្រកាន់ជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភធ្ងន់ធ្ងរលើច្បាប់អន្តរជាតិស្តីពីមនុស្សជាតិ [...], ដោយរួមបញ្ចូលនូវ មេដឹកនាំទាំងនោះ ដែល ពេលប្រព្រឹត្តបទល្មើស បានគំរាមកំហែងដល់ការបង្កើត និងអនុវត្តនូវដំណើរការសន្តិភាពក្នុងប្រទេសសេរ៉ាឡេអូន"។ ការកំណត់អំពីយុត្តាធិការរបស់តុលាការ គឺជាកម្មវត្ថុនៃការជជែកពិភាក្សា។ *សូមមើល* របាយការណ៍របស់អគ្គលេខាធិការស្តីពីការបង្កើតនូវតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនលេខ S/2000/915, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០, កថាខណ្ឌ ២៩ ("នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លេខ 1315 (ឆ្នាំ ២០០០), ក្រុមប្រឹក្សាសន្តិសុខផ្តល់អនុសាសន៍ថា យុត្តាធិការលើរូបបុគ្គលរបស់តុលាការពិសេសនេះ គប្បីពង្រីកទៅដល់ជន 'ដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការប្រព្រឹត្តនូវបទឧក្រិដ្ឋ', ដែលត្រូវគេយល់ថា ជាការបង្ហាញអំពីការកម្រិតលើចំនួនជនជាប់ចោទ ដោយសំអាងលើសិទ្ធិអំណាចជាមេដឹកនាំ និងភាពធ្ងន់ធ្ងរ និងវិសាលភាពនៃបទឧក្រិដ្ឋ។ ទោះជាយ៉ាងណាក្តី ខ្ញុំស្នើសុំថា ពាក្យពេចន៍ទូទៅដែលថា 'ជនដែលទទួលខុសត្រូវខ្ពស់បំផុត' គប្បីត្រូវបានប្រើប្រាស់")។ នៅក្នុងលិខិតចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ ផ្ញើពី អគ្គលេខាធិការ ទៅប្រធានក្រុមប្រឹក្សាសន្តិសុខ (S/2001/40), អគ្គលេខធិការ កត់សម្គាល់ឃើញថា ការកំណត់អំពីអត្ថន័យនៃពាក្យ"ជនដែលទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងរឿងក្តីណាមួយនោះ ដំបូង គឺស្ថិតលើអយ្យការ ហើយ ចុងក្រោយស្ថិតលើតុលាការពិសេសខ្លួនឯងផ្ទាល់ ហើយ "គឺជាគោលការណ៍ណែនាំដល់អយ្យការ ក្នុងការកំណត់នូវយុទ្ធសាស្ត្ររបស់អយ្យការ", (*សូមមើល* កថាខណ្ឌ ២-៣)។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ បុព្វកថានៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងថា តុលាការ គឺ

ព្រហ្មទណ្ឌ ជាមួយនឹងធនធានដែលមានកម្រិត[167]។ សេចក្ដីសម្រេចដកបទចោទចេញ តាមទម្លាប់ជាវិធាន គឺតាមឆន្ទានុសិទ្ធិ និងគំនិតផ្ដួចផ្ដើមរបស់អយ្យការ ប៉ុន្តែ ពាក់ព័ន្ធទៅនឹងបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយដែលត្រូវបានដំកល់ អាចធ្វើបានតែក្នុងករណីដែលអយ្យការបានស្នើសុំ និងបានទទួលការយល់ព្រមជាមុន[168]ពីអង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក គោលបំណងនៃក្របខណ្ឌនេះ គឺជា"ក្ដីកង្វល់ដល់សហគមន៍អន្តរជាតិទាំងមូល" ហើយជា"ការស្វែងរកយុត្តិធម៌ និងការផ្សះផ្សា ស្ថេរភាព សន្តិភាព និងសន្តិសុខជាតិ"[169]។ អាស្រ័យហេតុនេះ ការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ត្រូវបានកម្រិតយ៉ាងច្បាស់ត្រឹមតែ"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត"[170] ហេតុដូច្នេះវិធាននេះ គឺធ្វើឡើងតាមគោលនយោបាយ និងតម្រូវឲ្យអនុវត្តនូវឆន្ទានុសិទ្ធិរបស់អយ្យការ និងតុលាការជាចាំបាច់[171]។

---

សម្រាប់កាត់ក្ដីឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរបំផុតទាក់ទងនឹងសហគមន៍អន្តរជាតិទាំងមូល និងមាត្រា ១៧(១)(ឃ) នៃលក្ខន្តិកៈដែលបានចែងពីភាពមិនអាចទទួលយកបាននៃសំណុំរឿង នៅពេលដែលសំណុំរឿងនេះពុំមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ក្នុងការធ្វើយុត្តិកម្មលើសកម្មភាពរបស់តុលាការ។

[167] *សូមមើល* Robert Cryer, ចោទប្រកាន់មេដឹកនាំ: ការសន្យា នយោបាយ និងការអនុវត្តជាក់ស្ដែ, ព្រឹត្តិប័ត្រ Göttingen ស្ដីពីច្បាប់អន្តរជាតិ ១ (ឆ្នាំ ២០០៩) ១ ទំព័រ ៤៩, ៦៥; ; Margaret M. deGuzman and William A. Schabas in Sluiter et al. ICP Book, 137-139, ទំព័រ ១៣៧ ដល់ ១៣៩, *សេចក្ដីយោងដែលបានដកស្រង់នៅទីនោះ*។ ទាក់ទងទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ គណៈកម្មាធិការធ្វើសេចក្ដីព្រាងសម្រាប់ការបង្កើតតុលាការ បានសង្កេតឃើញថា ធនធានមានកម្រិតរបស់តុលាការ ពុំគប្បីត្រូវបានប្រើប្រាស់ឱ្យអស់ ទៅលើការចោទប្រកាន់នៃសំណុំរឿង ដែលអាចនឹងត្រូវបានដោះស្រាយយ៉ាងងាយស្រួល នឹងដោយប្រសិទ្ធភាព ដោយតុលាការជាតិនោះទេ។ *សូមមើល* កិច្ចដំណើរការនីតិវិធី នៃគណៈកម្មាធិការធ្វើសេចក្ដីព្រាង ក្នុងអំឡុងថ្ងៃទី ២៥ ខែ មីនា ដល់ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៦, A/AC.249/CRP.4, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣។ នៅក្នុង*ឯកសារស្ដីពី បញ្ហាគោលនយោបាយខ្លះ នៅចំពោះមុខការិយាល័យរដ្ឋអាជ្ញា* របស់តុលាការ ICC, ICC-OTP ឆ្នាំ ២០០៣, រដ្ឋអាជ្ញា បានឱ្យដឹងថា "តុលាការ គឺជាស្ថាប័នដែលមានធនធានមានកម្រិត" (*សូមមើល*ទំព័រ ៣), និងថា តាមវិធាន, "ការិយាល័យរបស់រដ្ឋអាជ្ញា គប្បីផ្ដោតកិច្ចខិតខំការស៊ើបអង្កេត និងធនធានរបស់ខ្លួនទៅលើជនដែលទទួលខុសត្រូវខ្ពស់បំផុត ដូចជាមេដឹកនាំរដ្ឋ ឬអង្គការ ដែលត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះ" (*សូមមើល*ទំព័រ ៧) ។

[168] *សូមមើល*មាត្រា ៦១(៩) នៃលក្ខន្តិកៈក្រុងរ៉ូម និងវិធាន ៥០-៥១ នៃវិធានរបស់តុលាការ ICTY, ICTR និងតុលាការ SCSL។

[169] បុព្វកថានៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក។

[170] *សូមមើល*មាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ១ នៃច្បាប់របស់ អ.វ.ត.ក និង វិធាន ៧២ នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។

[171] សូមមើល សាលដីកាក្នុងសំណុំរឿង *កាំង ហ្គេចអ៊ាវ ហៅឌុច* ឯកសារលេខ F28, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦១ ដល់ ៨០។

62. ការអនុម័តយកនូវគោលបំណងទាំងនេះ ដែលជាសញ្ញាណសំគាល់សំខាន់ នាំឱ្យមានសំណួរសួរឡើងថាតើ ផលវិបាកអាចិកំបាំងសម្រាប់ទម្រង់នៃនីតិវិធីជាធរមាន ពុំបានអនុញ្ញាតឱ្យដកចេញនូវបទចោទទាំងមូល ឬផ្នែកខ្លះ ដែរ ឬយ៉ាងណា នៅពេលដែលតម្រូវឱ្យមានប្រយោជន៍នៃយុត្តិធម៌ ដូចដែលបានកំណត់ដោយគោលបំណងនេះ។ ការពិចារណាដែលថា គោលការណ៍និត្យានុកូលភាពចោទប្រកាន់ ពុំកើតចេញដោយផ្ទាល់ពីសិទ្ធិនោះ[172] ពុំមែនជាយុត្តិធម៌នៃបទដ្ឋានអន្តរជាតិ[173] ហើយ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

[172] ជាការឆ្លើយតបទៅការទិទៀន ក្នុងការជ្រើសរើសធ្វើការចោទប្រកាន់ដែលសំអាងលើគោលការណ៍នៃសមភាពនៅចំពោះមុខច្បាប់ យុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចថា គោលការណ៍នៃសមភាពនឹងត្រូវទទួលការរំលោភបំពានដោយឆន្ទានុសិទ្ធិរបស់អយ្យការ តែមួយគត់នៅពេលដែល មានភស្តុតាងស្ដីបង្ហាញអំពីហេតុផលដែលពុំសមស្រប, ដូចជាការរើសអើង និងថា បុគ្គលដទៃទៀតដែលមានស្ថានភាពប្រហាក់ប្រហែល ពុំត្រូវបានទទួលការចោទប្រកាន់។ *សូមមើល ឧ.*.តុលាការ ICTY, *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Zejnil DELALIĆ ជនដទៃទៀត.*, សំណុំរឿងលេខ IT-96-21-A, សាលក្រម ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៦០៤ ដល់ ៦០៧; *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Vojislav ŠEŠELJ*, សំណុំរឿងលេខ IT-03-67-PT, សេចក្តីសម្រេចលើសំណើរបស់ Vojislav Šešelj ជំទាស់លើយុត្តាធិការ និងទំរង់នៃការចោទប្រកាន់ ចុះថ្ងៃទី ២៦ ខែ ឧសភាព ឆ្នាំ ២០០៤ កថាខណ្ឌ ២១; តុលាការ ICTR, *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Jean-Paul AKAYESU*, សំណុំរឿងលេខ ICTR-96-4-A, សាលក្រម ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៩៦ ។

[173] ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ជាគោលការណ៍ ចែងអំពីឆន្ទានុសិទ្ធិរបស់អយ្យការ ប៉ុន្តែ នៅក្នុងទ្វីបអឺរ៉ុប គោលការណ៍នីត្យានុកូលភាព គឺត្រូវទទួលរងនូវការលែងពេញនិយមជាបណ្តើរៗ។ បន្ថែមលើការចាប់ផ្តើមនៃទំរង់ផ្សេងៗគ្នានៃការព្រមព្រៀងចំពោះការឆ្លើយតបនៅចំពោះមុខតុលាការ ប្រព័ន្ធដែលជាទំលាប់ តម្រូវឱ្យមានការចោទប្រកាន់ បច្ចុប្បន្ននេះ បានបោះបង់ចោលនូវតម្រូវការឱ្យ ធ្វើការចោទប្រកាន់បន្ថែមលើបទចោទទាំងមូល ដែលពុំមានលក្ខណៈចាំបាច់ចំពោះផលប្រយោជន៍យុត្តិធម៌។ *សូមមើល ឧ.* ក្រមនីតិវិធីព្រហ្មទណ្ឌអាឡឺម៉ង់ ផ្នែក ១៥៣។ *សូមមើលផងដែរ* ផ្នែក ១៥៤ ក ដែលចែងថា "[ការបកប្រែផ្លូវការ] ប្រសិនបើ ផ្នែកនីមួយៗនៃបទចោទមួយ ឬការរំលោភបំពានមួយចំនួនលើច្បាប់ ដែលត្រូវបានប្រព្រឹត្តឡើងដោយសារតែបទល្មើសដូចគ្នានោះ ផ្នែកនេះពុំមានភាពសំខាន់ជាពិសេស ១) សម្រាប់ការដាក់ទោស ឬវិធានការនៃការកែទម្រង់ និងការ រារាំងដែលរំពឹងទុកនោះ ឬ ២) បន្ថែមលើការដាក់ទោស ឬវិធានការនៃការកែទំរង់ និងការរារាំង ដែលត្រូវតែធ្វើឡើង ដោយប្រសិទ្ធភាពចងកាតព្វកិច្ចលើជនជាប់ចោទ សម្រាប់បទល្មើលសដទៃទៀត ឬដែលជនជាប់ចោទអាចរំពឹងថានឹងទទួលទណ្ឌកម្មពីបទល្មើសមួយផ្សេងទៀតនោះ អយ្យការអាចកម្រិតត្រឹមតែផ្នែកដទៃទៀតនៃបទល្មើសនោះ ឬការរំលោភបំពាននៃច្បាប់នោះតែប៉ុណ្ណោះ បន្ទាប់ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះបានដាក់ក្នុងសំណុំរឿង តុលាការ ដោយមានការយល់ព្រមពីការិយាល័យអយ្យការសាធារណៈ អាចផ្តើមនូវការកម្រិតនេះ នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី។ (...) នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធី តុលាការអាចចាប់ផ្តើមឡើងវិញចូលក្នុងកិច្ចដំណើរការនីតិវិធីនូវផ្នែកនៃបទល្មើស ឬការរំលោភច្បាប់ទាំងនោះ ដែលពុំត្រូវបានធ្វើការពិចារណា [...]។ "*សូមមើលផងដែរ* មាត្រា ១៤(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ូឡូញ ដូចដែលបានធ្វើវិសោធនកម្ម នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៣ ដែលអនុញ្ញាតឱ្យមានការដកចេញនូវបទចោទព្រហ្មទណ្ឌ ដែលមានក្នុងការជំនុំជម្រះ បើទោះត្រឹមតែមានការយល់ព្រមពីជនជាប់ចោទក៏ដោយ។

ពុំទទួលបានឋានានុក្រមច្បាប់ខ្ពស់អ្វីទេ[174] ពីចម្លើយវិជ្ជមានទៅនឹងសំណួរនេះ ពុំអាចជៀសផុតបានទេ ដរាបណា បញ្ហាទាំងនេះ ត្រូវបានដោះស្រាយប្រកបដោយតម្លាភាព ដោយធ្វើការពិចារណាទៅលើផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិដែលពាក់ព័ន្ធក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយមានការព្រមព្រៀងពីសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូង។ ដោយដឹងថា ក្រមនីតិវិធីកម្ពុជា ពុំបានដោះស្រាយលើបញ្ហាពិសេសនេះ ទើបគប្បីស្វែងរកនូវគោលការណ៍ណែនាំទាក់ទងនឹងការថ្លឹងថ្លែងផលប្រយោជន៍ ដែលពាក់ព័ន្ធជាមួយនឹងនីតិវិធី ដើម្បីធានាភាពត្រឹមត្រូវ និងតម្លាភាព នៅក្នុងវិធានស្តីពីនីតិវិធីដែលត្រូវបានបង្កើតនៅក្នុងកម្រិតអន្តរជាតិ[175]។ គ្រប់ស្ថានការណ៍ទាំងអស់ អង្គជំនុំជម្រះសាលាដំបូងមានមានកាតព្វកិច្ច សម្រេចលើបញ្ហាដែលពុំទាន់បានជំនុំជម្រះរួចនៅចំពោះមុខខ្លួន ដូច្នេះកិច្ចដំណើរការនីតិវិធីលើបទចោទព្រហ្មទណ្ឌ ត្រូវបានសម្រេចលើអង្គសេចក្តី ឬត្រូវបដិសេធចោល[176]។

63. ត្រឡប់មកពិចារណាអំពីវិវាទជុំវិញលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាង អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា ពាក់ពន្ធ័នឹងភាពចាំបាច់ដើម្បីធានានូវយុត្តិធម៌បានតាមពេលសមស្រប ក្នុងសំណុំរឿងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានលក្ខណៈធំធេង[177] តុលាការ ICTY និង SCSL បានវិសោធនកម្មលើវិធាន ដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ស្នើសុំអយ្យការកាត់បន្ថយ ឬបង្គាប់ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ការកាត់បន្ថយនូវ ចំនួននៃបទចោទ ដែលបានចោទនៅក្នុងដីកាបញ្ជូនរឿង

---

[174] គោលការណ៍នីត្យានុកូលភាពនៅកម្ពុជា ពុំបានបញ្ជាក់ច្បាស់លាស់ ប៉ុន្តែត្រូវសន្និដ្ឋានចេញពីមាត្រា ៧ និង ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលរៀបរាប់យ៉ាងលំអិតអំពីហេតុផលនៃការបញ្ចប់បណ្តឹងអាជ្ញា។ ប្រៀបធៀប*ឧ.* ក្នុងប្រទេសអ៊ីតាលី គោលការណ៍នេះ ត្រូវបានបង្កើតឡើងស្របតាមមាត្រា ១១២ នៃរដ្ឋធម្មនុញ្ញរបស់អ៊ីតាលី ដែលចែងថា: "[ការបកប្រែផ្លូវការ] រដ្ឋអាជ្ញា មានកាតព្វកិច្ចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ"។

[175] *សូមមើល*មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ៣៣*ថ្មី* នៃកិច្ចព្រមព្រៀង អ.វ.ត.ក។ *សូមមើលផងដែរ* វិធាន ២ នៃវិធានផ្ទៃក្នុង។

[176] ម្យ៉ាងវិញទៀត តុលាការត្រូវ"ដោះស្រាយបណ្តឹងឱ្យអស់" (*សូមមើល*តុលាការឧទ្ធរណ៍ទីក្រុងប៉ារីស ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១២ *យោងខាងលើ*ជើងទំព័រ ១៦៤) ប៉ុន្តែ ការយោងនេះ រួមបញ្ចូលនូវសេចក្តីសម្រេចមួយស្តីពីការបិទ ដែលពុំបានប្រកាសអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

[177] *សូមមើលឧ.*, Dominique Raab,"ការវាយតម្លៃលើតុលាការ ICTY និងយុទ្ធសាស្ត្រពេញលេញរបស់តុលាការនេះ: កិច្ចខិតខំប្រឹងប្រែងទទួលបាននូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងតុលាការព្រហ្មទណ្ឌរបស់ខ្លួន", ព្រឹត្តិប័ត្រទី ៣ នៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៨២ (២០០៥), ទំព័រ ៨២ ដល់ ៨៤។ *សូមមើលផងដែរ* តុលាការ SCSL, របាយការប្រចាំឆ្នាំលើកទី៨ របស់ប្រធាននៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ខែ ឧសភា ឆ្នាំ ២០១១; របាយការណ៍ស្តីពីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលបានដាក់ជូនដោយ អ្នកជំនាញឯករាជ្យ ឈ្មោះ Antonio Cassese,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦។

ទៅជំនុំជម្រះ ឬត្រូវកំណត់យកទីកន្លែងឧក្រិដ្ឋកម្មមួយចំនួន ឬឧប្បត្តិហេតុទាក់ទងនឹងភស្តុតាងដែលត្រូវបានបង្ហាញ[178]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការតវ៉ាពីភាពមិនស៊ីគ្នានៃលក្ខណៈវិនិច្ឆ័យសម្រាប់កាត់បន្ថយបទចោទរបស់តុលាការ ICTY និងស្ថានភាពបច្ចុប្បន្នចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពុំមានមូលដ្ឋានត្រឹមត្រូវ។ ការកាត់បន្ថយនូវបទចោទបែបនេះ ពុំនាំឲ្យបញ្ចប់បទចោទនោះទេ។ ដូច្នេះ បើទោះបីជាផលប៉ះពាល់ជាក់ស្តែង នឹងត្រូវបណ្តាលឲ្យមានការដកនូវអង្គហេតុដែលបានចោទប្រកាន់មួយចំនួន ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ[179] ក៏អន្តរាគមន៍នេះ ជាផ្លូវការនៅតែជាវិធីសាស្ត្រសម្រាប់កិច្ចរៀបចំសវនាការ[180]។ ការប្រើប្រាស់វិធីសាស្ត្រសម្រាប់កិច្ចរៀបចំសវនាការនេះ នឹង

---

[178] សូមមើល វិធាន ៧៣ *ស្ទួន* (ឃ) របស់តុលាការ ICTY និង វិធាន ៧៣ *ស្ទួន* (ឆ) នៃតុលាការ SCSL។

[179] *សូមមើល ឧ.*, ICTY, *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milan MILUTINOVIĆ និងជនទៃទៀត.*, សំណុំរឿងលេខ IT-05-87-T, ដីកាទាក់ទងនឹងសារណារបស់អយ្យការទាក់ទងនឹងវិធាន ៧៣ ស្ទួន (ឃ) ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩ កថាខណ្ឌ ៤ និង ៧ ដល់៨។ សូមមើល ផងដែរ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milan MILUTINOVIĆ និងជនទៃទៀត.*, សំណុំរឿងលេខ IT-05-87-T, សារណារបស់អយ្យការទាក់ទងនឹងវិធាន ៧៣ ស្ទួន (ឃ) សេចក្តីសម្រេចចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៦, ថ្ងៃ ១២ ខែ មីនា ឆ្នាំ ២០០៩។

[180] *សូមមើល ឧ.* តុលាការ., ICTY, *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Ratko MLADIĆ*, សំណុំរឿងលេខ IT-09-92-PT, សេចក្តីសម្រេចអនុលោមតាម វិធាន ៧៣ ស្ទួន (ឃ) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ១៥; *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milan MILUTINOVIĆ និងជនដទៃទៀត.*, សំណុំរឿងលេខ IT-05-87-T, សាលក្រម, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ ១៦ នៃវ៉ុល I និងកថាខណ្ឌ ១២១៣ នៃវ៉ុល IV; *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Radovan KARADŽIĆ*, សំណុំរឿងលេខ IT-95-5/18-T, សេចក្តីសម្រេចលើសំណើសុំរបស់ជនជាប់ចោទសុំការសម្រេចលើ *គោលការណ៍គ្មានការកាត់ទោសពីរដង* ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ១៤ ("អង្គជំនុំជម្រះសាលាដំបូង យល់ស្របជាមួយជនជាប់ចោទ ថា បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងភស្តុតាងដែលពុំត្រូវបានបង្ហាញនៅពេលជំនុំជម្រះដោយអនុលោមតាម វិធាន ៧៣ *ស្ទួន* (ឃ) ពុំត្រូវបានរលត់ទៅនោះទេ និងបានកត់សម្គាល់ឃើញថា បញ្ហានេះជាសិទ្ធិរបស់អយ្យការក្នុងការដកបទចោទចេញ ឬបង្ហាញនូវវិធីសាស្ត្រដែល ខ្លួនមានបំណងបន្តការចោទប្រកាន់ប្រឆាំងនឹង ជនជាប់ចោទទាក់ទងនឹងបទចោទទាំងនោះ នៅពេលចុងបញ្ចប់នៃការជំនុំជម្រះនេះ")។ *សូមមើលផងដែរ* របាយការណ៍ប្រចាំឆ្នាំលើកទី ១៣ របស់តុលាការ ICTY, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦, ឯកសាររបស់អង្គការសហប្រជាជាតិលេខ A/61/271-S/2006/666, កថាខណ្ឌ ១០ ("អង្គជំនុំជម្រះសាលាដំបូង កំពុងនឹងពន្លឿននូវការជំនុំជម្រះផងដែរ។ គួរកត់សម្គាល់ផងដែរ អង្គជំនុំជម្រះសាលាដំបូង កំពុងប្រើប្រាស់វិធាន ៧៣*ស្ទួន* ក្នុងការតម្រូវអយ្យការផ្តោតសំណុំរឿងរបស់ខ្លួន [...] ចៅក្រមបានធ្វើវិសោធនកម្មលើវិធាន ៧៣ *ស្ទួន* ដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង អញ្ជើញ និង/ឬ ផ្តល់សេចក្តីណែនាំដល់អយ្យការក្នុងការជ្រើសរើសបទចោទទាំងនោះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបន្ត។ វិសោធនកម្មនេះ ចាំបាច់ក្នុងការធានានូវការគោរពដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ហើយរារាំងដល់ការឃុំខ្លួនយូរដោយឥតសមស្រប។ ព្រះរាជអាជ្ញា បានជំទាស់យ៉ាងខ្លាំងទៅលើវិសោធនកម្មនេះ បើទោះបីជាដីកាចោទប្រកាន់នេះ គឺជាផ្នែកមួយនៃកិច្ចរៀបចំសវនាការដែលជារួមត្រូវបានប្រើប្រាស់នៅក្នុងយុត្តាធិការជាតិ ហើយពុំបានប៉ះពាល់ដល់បុព្វសិទ្ធិរបស់អយ្យការឡើយ")។

ត្រូវក្លាយជាកម្មវត្ថុនៃការពិចារណានៅចំពោះមុខ អ.វ.ត.ក ថាជា "វិធាននីតិវិធីដែលបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ"។ ប៉ុន្តែ បើទោះជាអង្គជំនុំជម្រះសាលាដំបូងការអះអាងយ៉ាងត្រឹមត្រូវថា វិធាន ៧៣*ស្ទួន*(ឃ) នៃវិធានតុលាការ ICTY ពុំអាចអនុវត្តបាននៅចំពោះមុខតុលាការនេះ ក្នុងរឿងក្តីបច្ចុប្បន្ននេះក្តី ក៏លទ្ធភាពដែលថា ផ្នែកខ្លះនៃបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ នឹងពុំត្រូវបានទទួលការជំនុំជម្រះដោយសារតែហេតុផល ដែលហួសពីការគ្រប់គ្រងរបស់តុលាការ និងរបស់ភាគីនោះ គឺតម្រូវឱ្យមានការកំណត់នូវអាទិភាពនៃបទចោទដើម្បីជំនុំជម្រះ ដែលផលប៉ះពាល់ទៅលើករណីរនៃការចោទប្រកាន់ដែលប្រហាក់ប្រហែលគ្នាទៅនឹងរឿងក្តី ដែលបទចោទនានា ត្រូវបានកាត់បន្ថយអនុលោមទៅតាមវិធាន ៧៣*ស្ទួន*(ឃ) នៃវិធានតុលាការ ICTY។ អាស្រ័យហេតុនេះ នៅពេលដែលការបំបែកដំណើរការនីតិវិធីនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ ដូចដែលមានចែងក្នុងវិធាន *៨៩ស្ទួន* នៃវិធានផ្ទៃក្នុង ត្រូវធ្វើឡើងដោយសារការជំរុញនូវហានិភ័យដែលថាតុលាការនឹងមិនអាចជំនុំជម្រះការចោទប្រកាន់ទាំងមូល ក្នុងដីកានេះ គោលការណ៍ដែលគ្រប់គ្រងការកាត់បន្ថយបទចោទ ដូចជាបទដ្ឋានស្តីអំពីភាពជាតំណាង ដូចមានចែងក្នុងវិធាន ៧៣*ស្ទួន*(ឃ) នៃវិធានតុលាការ ICTY ក្លាយជាវិធានពាក់ព័ន្ធ ហើយ អាចយកមកអនុវត្តបាន[181]។

64. ដោយសារតែសេចក្តីសម្រេចស្តីពីការកាត់បន្ថយបទចោទ គឺជាប់ពាក់ព័ន្ធនឹងការកម្រិតវិសាលភាពនៃការជំនុំជម្រះ ដែលត្រូវបានកំណត់ និងអះអាងបញ្ជាក់ពីមុនរួចហើយនោះ វិធានជាធរមាន តម្រូវយ៉ាងជាក់លាក់ឲ្យមានការថ្លឹងថ្លែងរវាង"ផលប្រយោជន៍នៃការជំនុំជម្រះ ឲ្យបានឆាប់រហ័ស និងប្រកបដោយយុត្តិធម៌" និងតម្រូវការឲ្យមានសវនាការមួយ ដែល"ធ្វើជាតំណាងសមហេតុផល"នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល[182]។ យុត្តិសាស្ត្ររបស់តុលាការ ICTY ដែលយក វិធាន ៧៣*ស្ទួន*(ឃ) នៃវិធានផ្ទៃក្នុងរបស់តុលាការ ICTY មកអនុវត្តនៅក្នុងរឿងក្តីមួយចំនួននោះ គឺមាន លក្ខណៈជាការណែនាំជាពិសេសដើម្បីជួយបកស្រាយ ថាតើ មានការបម្រើឲ្យផលប្រយោជន៍យុត្តិធម៌បែបណាខ្លះ ដោយធ្វើការកម្រិតបទចោទ ដើម្បីយកមកធ្វើការវិនិច្ឆ័យ និងទៅតាមលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសយកបទចោទទាំង

---

[181] *សូមមើល*សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤២។

[182] *សូមមើល* វិធាន ៧៣*ស្ទួន*(ឃ) នៃវិធានរបស់តុលាការ ICTY និងវិធាន ៧៣ស្ទួន(ឆ) នៃវិធានរបស់តុលាការ។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milan MILUTINOVIĆ* និង*អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-T សេចក្តី សម្រេចលើការអនុវត្តវិធាន ៧៣*ស្ទួន* ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចលើរឿងក្តី *Milutinović* កថាខណ្ឌ ៦។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Vojislav ŠEŠELJ* សំណុំរឿងលេខ IT-03-67-PT សេចក្តីសម្រេចលើការអនុវត្តវិធាន ៧៣*ស្ទួន* ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចលើ*រឿងក្តី Šešelj*") កថាខណ្ឌ ១០ ("*ភាពត្រឹមត្រូវ និងភាពឆាប់រហ័សនៃការជំនុំជម្រះ និងលក្ខខណ្ឌនៃភាពជាតំណាងដ៏សមស្រប គឺជាគោលការណ៍ដ៏សំខាន់បំផុត ដែលត្រូវណែនាំដល់ការអនុវត្តធន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ*")។

នេះ។ ជាពិសេស កត្តាខាងក្រោមនេះ អាចតម្រូវឱ្យមានការគិតពិចារណា ៖ (i) ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[183] (ii) ចំណាត់ថ្នាក់ និងចរិតលក្ខណៈនៃឧក្រិដ្ឋកម្ម[184] (iii) ទីកន្លែងដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្ម[185] (iv) វិសាលភាពនៃឧក្រិដ្ឋកម្ម[186] (v)

---

[183] ទោះបីជាកត្តានេះមានចែងនៅក្នុងវិធាន ៧៣*ស្ទួន*(ឃ) នៃវិធានរបស់តុលាការ ICTY ក៏ដោយ ក៏ចំណុចនេះមិនត្រូវបានលើកយកមកពិភាក្សាឱ្យបានច្បាស់លាស់នៅក្នុងយុត្តិសាស្ត្រស្តីពីការកាត់បន្ថយបទចោទនោះឡើយ។

[184] ការអានធម្មតានៃឃ្លាដែលមានសរសេរនៅក្នុងវិធាន ៧៣*ស្ទួន*(ឃ) នៃវិធានរបស់តុលាការ ICTY ចង្អុលបង្ហាញថា ការកំណត់បទចោទនៃឧក្រិដ្ឋកម្ម ត្រូវយកមកធ្វើការពិចារណា ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីធានាថា ឧក្រិដ្ឋកម្ម ដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែក ឆ្លុះបញ្ចាំងនូវប្រភេទនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់កាលពីដើមដំបូង។ ដូច្នេះ ការចោទប្រកាន់នៅចំពោះមុខតុលាការ ICTY ជាទូទៅត្រូវបានកាត់បន្ថយត្រឹមចំនួនតិចតួចនៃទីកន្លែងឧក្រិដ្ឋកម្ម ដោយមិនប៉ះពាល់ដល់បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ឬដោយការច្របាច់បញ្ចូលគ្នានូវបទចោទ ដើម្បីរក្សានូវ "បទចោទគ្របដណ្តប់រួម" ដូចជា ការធ្វើទុក្ខបុកម្នេញ និងអំពើមនុស្សធម៌ ដើម្បីគ្របដណ្តប់ទៅលើអំពើឧក្រិដ្ឋជាច្រើនប្រភេទដែលត្រូវបានរាប់បញ្ចូលនៅក្នុងបទចោទនានាក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម។ *សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Dragan NIKOLIĆ*, សំណុំរឿងលេខ IT-94-2 សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំឱ្យធ្វើវិសោធនកម្ម ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានធ្វើវិសោធនកម្មលើកទីមួយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២។

[185] ត្រូវតែមានការខិតខំប្រឹងប្រែងដើម្បីធានាថា ការចោទប្រកាន់ដែលត្រូវបានបំបែក ឆ្លុះបញ្ចាំងជាលក្ខណៈភូមិសាស្ត្រអំពីឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់កាលពីដើមដំបូង។ ប្រការនេះអាចធ្វើទៅបានដោយ *ក្នុងចំណោមប្រការផ្សេងទៀត* ធានាថា ទីកន្លែងឧក្រិដ្ឋកម្មដែលត្រូវបានដកចេញ "ត្រូវបានចែករំលែកយ៉ាងស្មើគ្នា និងមានសមាមាត្រ" ក្នុងចំណោមតំបន់នានា ដែលបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ថាបានកើតឡើង។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Jovica STANIŠIĆ* និង *Franko SIMATOVIĆ* សំណុំរឿង IT-03-69-PT សេចក្តីសម្រេច អនុលោមតាមវិធាន ៧៣*ស្ទួន*(ឃ) ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ("សេចក្តីសម្រេចលើ*រឿងក្តី Stanišič*") កថាខណ្ឌ ២៣។ ប្រសិនបើតំបន់មួយអាចត្រូវបានកំណត់អត្តសញ្ញាណថាជាទីកន្លែងនៃរឿងក្តីនោះ ហើយអង្គហេតុដែលថា ឧក្រិដ្ឋកម្មមួយចំនួនត្រូវបានប្រព្រឹត្តឡើងនៅក្រៅតំបន់នោះ អាចជាហេតុផលមួយក្នុងការដកឧក្រិដ្ឋកម្មនោះចេញ។ *សូមមើល សេចក្តីសម្រេចលើរឿងក្តី Milutinović* Decision កថាខណ្ឌ ១១។ ទោះបីជាយ៉ាងណាក៏ដោយ ការលុបចោលទីកន្លែងឧក្រិដ្ឋកម្មមួយទាំងស្រុងនៅក្នុងប្រទេសមួយ ដែលផ្សេងពីនេះមិនត្រូវបានតំណាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានធ្វើវិសោធនកម្មដែលបានស្នើឡើង ត្រូវបានរកឃើញថាមិនបាន បំពេញនូវលក្ខខណ្ឌនៃភាពជាតំណាង ដូច្នេះ ការដកចេញបែបនេះនឹងនាំឱ្យមានជនរងគ្រោះដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់មួយចំនួនដែលមិនត្រូវបានតំណាងនៅក្នុងរឿងក្តីទៀតឡើយ។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Momčilo PERIŠIĆ*, សំណុំរឿងលេខ IT-04-81-PT សេចក្តីសម្រេចលើការអនុវត្តវិធាន ៧៣ស្ទួន និងវិសោធនកម្មដីកា បញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ១២។ ចុងក្រោយ ក៏មានការរកឃើញផងដែរថា ការបង្ហាញភស្តុតាងដែលពុំផ្អែកលើទីតាំងបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទីកន្លែងយ៉ាងច្រើនទូលំទូលាយ ទាក់ទិននឹងការបង្ហាញភស្តុតាង *ក្នុងចំណោមប្រការផ្សេងទៀត* អំពីការវាយប្រហារជាលក្ខណៈប្រព័ន្ធ និងទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជន អាចរួមចំណែកបន្ថែមទៀតដល់ការធានាថា វិសាលភាពទីតាំងភូមិសាស្ត្រដ៏ទូលំទូលាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានរក្សាទុក ទោះបីជាទីកន្លែងឧក្រិដ្ឋកម្មមួយចំនួនត្រូវបានដកចេញក៏ដោយ។ *សូមមើល សេចក្តីសម្រេចលើរឿងក្តី Šešelj* កថាខណ្ឌ ៣០ ("វិសាលភាព

ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[187] (vi) អំឡុងរយៈពេលនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[188] និង (vii) លក្ខណៈជាមូលដ្ឋាននៃរឿងក្តី[189]។ ដូច្នេះ គោលបំណងដ៏សំខាន់បំផុតនៃលក្ខខណ្ឌនៃភាពជាតំណាង គឺដើម្បីជ្រើសរើសបទចោទក្នុងចំនួនអប្បបរមា ដែលនឹងឆ្លុះបញ្ចាំងដ៏សមហេតុផលនូវវិសាលភាព និងចរិតលក្ខណៈនៃការដាក់បន្ទុកជាលក្ខណៈបុគ្គល និងអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទាំងមូល។ ដូច្នេះ លក្ខខណ្ឌជាមូលដ្ឋាននៃភាពជាតំណាង គឺជាការសន្មតដែលថា កិច្ចដំណើរការនីតិវិធីទៅលើបទចោទដែលនៅសេសសល់ គឺអាចនាំឲ្យមាននូវការឆ្លើយតបមួយដែលមានរចនាសម្ព័ន្ធ ដែល

---

នៃទីតាំងភូមិសាស្ត្រដ៏ទូលំទូលាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងត្រូវបានរក្សាទុក ដោយពិចារណាលើ វិសាលភាពនៃទីកន្លែងឧក្រិដ្ឋកម្ម ពាក់ព័ន្ធនឹងថាតើភ័ស្តុតាងមួយណានឹងត្រូវយកមកបង្ហាញ")។

[186] កត្តានេះស្នើឡើងថា ត្រូវតែមានការគិតពិចារណាទៅលើទំហំ និងនិយ័តភាពនៃឧក្រិដ្ឋកម្ម ដើម្បីធានាថា ការកើតឡើងជាថ្មីទៀតនៃអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ក្នុងកម្រិតខ្លះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកាត់បន្ថយ។ ការដកចេញនូវទីកន្លែងឧក្រិដ្ឋកម្ម ឬបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដ៏ធំបំផុតមួយ នឹងមានផលប៉ះពាល់តិចទៅលើសមត្ថភាពរបស់រដ្ឋអាជ្ញាក្នុងការបង្ហាញឲ្យឃើញអំពីការកើតឡើងជាថ្មីទៀតនៃឧក្រិដ្ឋកម្ម ជាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានលក្ខណៈតូច។

[187] ចំនួនជនរងគ្រោះ សមាជិកភាពនៃក្រុមជាក់លាក់ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលបានកើតមាន ត្រូវបានចាត់ទុកថា មានភាពពាក់ព័ន្ធ នៅពេលកាត់បន្ថយបទចោទ។ *សូមមើល*សេចក្តីសម្រេចលើរឿងក្តី *Šešelj* កថាខណ្ឌ ២៥, ៣១។ រឿងក្តី រដ្ឋអាជ្ញាទល់នឹង *Ramush HARADINAJ* និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-04-84-PT សេចក្តីសម្រេច អនុលោមតាម វិធាន ៧៣ស្ទួន(ឃ) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ១១។ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានខិតខំរក្សាទុកក្រុមសាសនា និងជាតិពន្ធុទាំងអស់ និង"មិនធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់រដ្ឋអាជ្ញាក្នុងការបង្ហាញភស្តុតាងអំពីភាពជាជនរងគ្រោះ" នៃក្រុមជាតិពន្ធុទាំងអស់ដែលត្រូវបានគេកំណត់មុខសញ្ញា។

[188] អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានខិតខំបង្ហាញនូវ "ដំណាក់កាលសំខាន់ៗ" នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម និងអំឡុងរយៈពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង។ *សូមមើល សេចក្តីសម្រេចលើរឿងក្តី Stanišić* កថាខណ្ឌ ២៨។ *សូមមើលផងដែរ* ជាទូទៅ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ante GOTOVINA, Ivan ČERMAK* និង *Mladen MARKAČ*, សំណុំរឿងលេខ IT-06-90-PT ដីកាបង្គាប់ អនុលោមតាមវិធាន ៧៣ស្ទួន(ឃ) ឲ្យកាត់បន្ថយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៧។

[189] នៅក្នុង *រឿងក្តី Milutinović* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ពិចារណាថា អង្គជំនុំជម្រះមិនអាចលុបចោលបទចោទឡើយ ដោយពិចារណាទៅលើវិធីដែលរឿងក្តីរបស់រដ្ឋអាជ្ញាត្រូវបានរៀបចំឡើង ប៉ុន្តែផ្តោតទៅលើការលុបចោល "ទីកន្លែងឧក្រិដ្ឋកម្ម ឬព្រឹត្តការណ៍ទាំងនោះ ដែលខុសគ្នាយ៉ាងច្បាស់ក្រឡែតពីចរិតលក្ខណៈជាមូលដ្ឋាន ឬខ្លឹមសារនៃរឿងក្តី និងបង្គាប់ឲ្យរដ្ឋអាជ្ញាបង្ហាញភ័ស្តុតាង ទាក់ទិននឹងព្រឹត្តការណ៍ និងទីកន្លែងផ្សេងៗទៀត ដែលស្ថិតនៅក្នុងចរិតលក្ខណៈ ឬខ្លឹមសារនោះដោយផ្ទាល់"។ *សូមមើល* សេចក្តីសម្រេចលើ *រឿងក្តី Milutinović* កថាខណ្ឌ ៧, ១០។ អង្គជំនុំជម្រះសាលាដំបូង នៅក្នុង *រឿងក្តី Šešelj* សម្រេចមិនយកកត្តានេះមកអនុវត្ត ប៉ុន្តែបានសម្រេចសង្កត់ធ្ងន់ទៅលើ "ភាពជាតំណាងសមស្របនៃ បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់"។ *សូមមើល* សេចក្តីសម្រេចលើ *រឿងក្តី Šešelj* កថាខណ្ឌ ១២។

ពាក់ព័ន្ធទៅនឹងគោលបំណងដ៏ទូលំទូលាយនៃភាពយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលដូចគ្នាទៅនឹងកិច្ចដំណើរការនីតិវិធីទៅលើបទចោទដើមដំបូងដែរ[190]។

65. ដោយពិចារណាទៅលើហេតុផលខាងលើ អង្គជំនុំជម្រះសាលាដំបូងមិនអាច ម៉្យាងអះអាងដោយត្រង់ៗថា សុខភាពទ្រុឌទ្រោម និងការចុះខ្សោយផ្នែករាងកាយរបស់ជនជាប់ចោទ តម្រូវឱ្យមានការបំបែកសំណុំរឿង ០០២ ដើម្បីឱ្យ យ៉ាងហោចណាស់ អាចឈានទៅដល់ការចេញសាលក្រមមួយក្នុងអំឡុងពេលដែលជនជាប់ចោទនៅមានជីវិតរស់នៅនោះឡើយ ម្យ៉ាងវិញទៀត នៅពេលដែលការសម្រេចរបស់ខ្លួនដែលថា គ្មានបទចោទ ឬការជំនុំជម្រះនៅពេលអនាគតណាត្រូវបានបញ្ចប់តាមផ្លូវច្បាប់បាននោះ បានធ្វើឱ្យមានភាពពុំចាំបាច់ និងកាន់តែគ្មានន័យ ក្នុងការធានាថា វិសាលភាពនៃបទចោទដែលកំពុងត្រូវបានជ្រើសយកមកធ្វើការជំនុំជម្រះ និងវិនិច្ឆ័យនេះ គឺជាតំណាងដ៏សមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ អង្គជំនុំជម្រះ សាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ និងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបដិសេធនូវលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះថា មិនអាចយកមកអនុវត្តបានចំពោះស្ថានភាពបច្ចុប្បន្ននេះ។

66. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាបានពិចារណាទៅលើកត្តានានាដែលចង្អុលបង្ហាញអំពីភាពជាតំណាង ទោះបីគ្រាន់តែដើម្បី ជាផលប្រយោជន៍នៃការលើក

---

[190] អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ពាក្យពេចន៍ដែលមានចែងនៅក្នុងវិធាន ៧៣*ស្ទួន*(ឃ) នៃវិធានរបស់តុលាការ ICTY ស្នើឡើងថា វាពាក់ព័ន្ធនឹងការពិនិត្យមើលថាតើ "បទឧក្រិដ្ឋដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានបំបែកត្រូវតែមានភាពធ្ងន់ធ្ងរ និងច្រើនប្រភេទ ស្រដៀងគ្នាទៅនឹងបទឧក្រិដ្ឋដែលមាននៅក្នុងដីកាដំណោះស្រាយទាំងមូល"។ *សូមមើល* បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០។ ប្រការនេះអនុលោមទៅនឹងគោលការណ៍នៃវិធីសាស្ត្រក្នុងការចោទប្រកាន់ដែលត្រូវបានគេទទួលស្គាល់ ដែលពាក់ព័ន្ធនឹងការពិចារណាទៅលើពិរុទ្ធភាពជាទូទៅរបស់ជនជាប់ចោទ ដើម្បីទទួលបាននូវទោសទណ្ឌដ៏សមស្រប និងផ្តោតទៅលើបទល្មើសធ្ងន់ធ្ងរបំផុត។ *សូមមើល* តុលាការ SCSL *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Samuel Hinga NORMAN, Moinina FOFANA* និង *Allieu KONDEWA* សំណុំរឿងលេខ SCSL-04-14-AR73, សេចក្តីសម្រេចលើការកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានច្របាច់បញ្ចូលគ្នា ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៨២។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គោលដៅនៃយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ មិនកំណត់ត្រឹមការដាក់ទណ្ឌកម្ម និងលើសពីនេះទៀតបម្រើឱ្យគោលបំណងក្នុងការបញ្ជាក់អះអាងនូវការទទួលខុសត្រូវ ការបញ្ជាក់អំពីការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលជាមធ្យោបាយនៃបញ្ហានេះ ការបង្កើតនូវកំណត់ហេតុត្រឹមត្រូវនៃអង្គហេតុជាប់ពាក់ព័ន្ធ និងការផ្តល់សំណងដល់ជនរងគ្រោះ។

ជាទឡ្ហីករណ៍ក៏ដោយ[191]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទោះបីជាវិសាលភាពចរិតលក្ខណៈ ការពិពណ៌នាអង្គច្បាប់ អំឡុងពេលវេលា និង ការបែងចែកតំបន់ភូមិសាស្ត្រនៃបទឧក្រិដ្ឋដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំត្រូវបានតំណាងដោយវិសាលភាពនៃសំណុំរឿង ០០២/០១ ក្រោយពីបំបែកក៏ដោយ[192] ក៏ទម្រង់នៃការបំបែកកិច្ចដំណើរការនីតិវិធីនេះ នឹង"បំពេញ*នៅក្នុងគ្រប់កាលៈទេសៈទាំងអស់* តាមលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមស្របនៃដីកាដំណោះស្រាយនៃសំណុំរឿង ០០២"[193] ដោយដឹងថា "ការជម្រើសដោយបង្ខំ ប្រហែលជាចំណុចទូទៅតែមួយគត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលពាក់ព័ន្ធ ឬប៉ះពាល់ដោយផ្ទាល់ដល់ប្រជាជនកម្ពុជាទាំងមូល"[194] ហើយថា "ការចូលរួមជាបន្តទៀតរបស់បុគ្គលទាំងអស់ ដែលត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីរួចមកហើយ នៅក្នុងសំណុំរឿង ០០២ នឹងពុំមានផលប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ...ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ"[195]។

67. ពុំមានមូលដ្ឋាននៅក្នុងច្បាប់ដែលត្រូវបានអនុវត្តជាធរមាននៅចំពោះមុខ អ.វ.ត.ក និង ជាពិសេសនៅក្នុងវិធាននានាដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ សម្រាប់ការកំណត់ឡើងវិញលើលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងនោះទេ។ ហានិភ័យនៃការរកយុត្តិធម៌ឱ្យបានទាន់ពេលវេលា គឺជាលក្ខខណ្ឌសំអាងសម្រាប់ការបន្ថយបទចោទ និងសម្រាប់ការអនុវត្តលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងតាំងពីដំបូងមក។ នៅពេលលក្ខខណ្ឌនេះត្រូវបានកំណត់រួចហើយ បទដ្ឋានជាធរមាន គឺជាបទដ្ឋានមួយដូចបានពិពណ៌នាខាងលើ និងជាប់ពាក់ព័ន្ធនឹងការពន្លឿនកិច្ចដំណើរការនីតិវិធី ហើយកិច្ចប្រជុំរៀបចំសវនាការលែងដើរតួជាកត្តាសម្រាប់ការផ្ដល់យុត្តិកម្មលើការកាត់បន្ថយបទចោទទៀតហើយ។ ជាការពិតណាស់ ការអនុញ្ញាតឱ្យមានកំណត់ជាលើកទីពីរបែបនេះ នឹងធ្វើឱ្យលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងគ្មានអត្ថន័យអ្វីសោះ។ យោងតាមសំអាងហេតុទាំងនេះ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចមានសុពល

[191] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១០០ ("ទោះបីជាមានការលំបាកទាំងនេះក្នុងការអនុវត្តដោយផ្ទាល់ចំពោះបទបញ្ញត្តិមួយដែល ចេញពីបរិបទស្ថាប័ន និងក្របខណ្ឌច្បាប់ ដែលមានលក្ខណៈខុសគ្នាខ្លាំងពី អ.វ.ត.ក ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង បានខិតខំប្រឹងប្រែងក្នុងការកំណត់ និងអនុវត្តលក្ខខណ្ឌនៃភាពជាតំណាង ដែលត្រូវបានបង្កើតឡើងដោយវិធាន ៧៣*ស្ទួន*(ឃ) របស់តុលាការ ICTY និងខិតខំប្រឹងប្រែងក្នុងការពិចារណាថាតើ លក្ខខណ្ឌនៃភាពជាតំណាងនេះអាចជួយឱ្យខ្លួនសម្រេចអំពី ភាពជាតំណាងនៃវិសាលភាពក្នុងសំណុំរឿង ០០២/០១ ដោយរបៀបណា")។

[192] *សូមមើល* សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១០១-១២៣។

[193] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៨ (សេចក្ដីបញ្ជាក់បន្ថែម)។

[194] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១២។

[195] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១១៤។

ដរាបណា ដោយអនុលោមតាមការបកស្រាយប្រកបដោយភាពសមហេតុបំផុត ឃ្លាដែលថា"នៅគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់" ត្រូវបានបកស្រាយក្នុងន័យថា ហានិភ័យក្នុងការចេញ"សាលក្រមឲ្យបានទាន់ពេលវេលា" មានអនុភាពលើការអនុវត្តភ្លាមៗលើលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាង។

68. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការព្រួយបារម្ភលើការគ្រប់គ្រងឲ្យមានប្រសិទ្ធភាពដូចដែលពន្យល់ប្រាប់ អាចមានអានុភាពលើការសន្និដ្ឋថា វិសាលភាពនៃសំណុំរឿង ០០២/០១ គឺជាតំណាងនៃដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះ។ ទោះបីជាបានចំណាយរយៈពេល ១៤ ខែ រៀបចំការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ក៏ដោយ[196] និងក្រោយពីរក្សាទុកវិសាលភាពនៃសំណុំរឿង ០០២/០១ ឲ្យនៅចំហរយៈពេលមួយឆ្នាំសម្រាប់ការកែប្រែ[197] អង្គជំនុំជម្រះសាលាដំបូងបានបដិសេធយ៉ាងតឹងរ៉ឹងក្នុងការកែសម្រួលជំហរដំបូងរបស់ខ្លួន ដើម្បីសម្របទៅតាមជំហររបស់ភាគី ហើយមិនព្រមដោះស្រាយកង្វល់របស់ភាគីពាក់ព័ន្ធនឹងផលវិបាកកើតចេញពីដីកាបំបែកកិច្ចដំណើរការនីតិវិធី ដែលបានកែសម្រួលសាជាថ្មីសម្រាប់ការជំនុំជម្រះនាពេលខាងមុខ។ ករណីនេះមានន័យថា អង្គជំនុំជម្រះសាលាដំបូង ពុំទាន់បានត្រៀមខ្លួនរួចរាល់ក្នុងការវិនិច្ឆ័យនៅក្នុងសំណុំរឿង ០០២/០១ លើបទចោទនានា ដែលនៅសល់នៅក្នុងដីកាដំណោះស្រាយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងកាលៈទេសៈបច្ចុប្បន្ន ការបង្គាប់ឲ្យពង្រីកសំណុំរឿង ០០២/០១ និងការតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងរៀបចំកាលវិភាគរបស់ខ្លួនឡើងវិញជៀសមិនផុតនឹងនាំឲ្យមានការពន្យារពេលដោយឥតចាំបាច់។ អាស្រ័យហេតុនេះ សំណើសុំរបស់សហព្រះរាជអាជ្ញាស្នើសុំបន្ថែម ស-២១ និងសំណើសុំរបស់ នួន ជា ស្នើសុំបន្ថែមបទប្រល័យពូជសាសន៍ រួមទាំង សហករណ៍ និងការដ្ឋានការងារ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានបដិសេធចោល។

69. ទោះបីជាយ៉ាងនេះក្តី គោលបំណងនៃការចេញ "*សាលក្រមឲ្យបានទាន់ពេលវេលា*" នៅក្នុងពេលសហជនជាប់ចោទនៅមានជីវិត ពុំបានបន្ថយកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងលើការថ្លឹងថ្លែងរវាងអត្ថប្រយោជន៍នៃការជំនុំជម្រះដោយយុត្តិធម៌និងឆាប់រហ័ស ជាមួយនិងភាពចាំបាច់សម្រាប់ការជំនុំជម្រះមួយដែលត្រូវមានភាពជាតំណាងឲ្យបានសមហេតុផលលើដីកាដំណោះស្រាយទាំងមូលនៅក្នុងសំណុំរឿង

[196] ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ បានដាក់នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ជាកាលបរិច្ឆេទដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសិទ្ធិពិនិត្យសំណុំរឿង ០០២ អនុលោមតាមវិធាន ៦៩(៣)នៃវិធានផ្ទៃក្នុង។ ការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ បានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ *សូមមើល* ប្រតិចារឹក ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/13/1។

[197] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ១៧, ៣៧, ៤៦។

០០២[198]។ ការខកខានក្នុងការធ្វើឲ្យមានភាពជាតំណាងឲ្យបានពេញលេញលើរឿងក្តីទាំងមូលប្រឆាំងនឹងសហជនជាប់ចោទ នៅក្នុងពេលពួកគេនៅមានជីវិត ជៀសពុំរួចឡើយ នឹងបណ្តាលឱ្យមានការបរាជ័យ ក្នុងការចេញសាលក្រមដ៏មានអត្ថន័យគ្រប់គ្រាន់នោះ[199]។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា គោលការណ៍ណែនាំមួយដូចមានចែងនៅក្នុងសេចក្តីសម្រេចរបស់ អ.ជ.ត.ក គឺជាគោលការណ៍ណែនាំចាំបាច់សម្រាប់ផែនការជាក់លាក់មួយលើការវិនិច្ឆ័យបទចោទទាំងអស់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយមិនមែនត្រឹមតែសម្រាប់ការវិនិច្ឆ័យលើបទចោទមួយផ្នែកនៅក្នុងដីកានេះទេ[200]។ នៅពេលមិនបានដោះស្រាយលើបញ្ហាចោទ ថាតើ សំណុំរឿង ០០២/០២ នឹងចាប់ផ្តើមនៅពេលណា ហើយកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ អាចបញ្ចប់ដោយរបៀបណានោះ[201] សេចក្តីសម្រេចដែលរងការជំទាស់នេះ ទំនងជាមិនផ្តល់ដំណោះស្រាយដែលជាបញ្ហារបស់តុលាការ ដោយសារកត្តាខាងក្រៅ ដូចជាលក្ខខណ្ឌរូបរាងកាយរបស់ជនជាប់ចោទ ឬ កត្តាហិរញ្ញវត្ថុនៃ អ.វ.ត.ក ដែលបង្ហាញនូវភាពមិនច្បាស់លាស់សម្រាប់ភាគី ហើយបានលើកឡើងដ៏មានប្រសិទ្ធភាពនូវការលើកលែងទោស *តាមព្រឹត្តហេតុ*លើបទចោទដែលពុំទាន់បានវិនិច្ឆ័យ។

70. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវតែអនុវត្តសមត្ថកិច្ចរបស់ខ្លួនក្នុងការកែតម្រូវ ដើម្បីធានាថាយ៉ាងហោចណាស់ បទចោទដែលនៅសេសសល់ក្នុងដីកាដំណោះស្រាយអប្បបរមាដែលមិនអាចកាត់បន្ថយតទៅទៀតបាននោះ ទទួលបានការជំនុំជម្រះយ៉ាងសមស្រប។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធានការដែលសមស្របបំផុត គឺត្រូវធ្វើការផ្តល់សេចក្តីណែនាំថា បទចោទទាំងនោះដែលគួរតែត្រូវបានបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងត្រូវបញ្ចូលទៅក្នុងវិសាលភាពដែលមានកម្រិតនៃសំណុំរឿង ០០២/០២ ដើម្បីឱ្យការបញ្ចូលគ្នានៃសំណុំរឿង ០០២/០១ និង ០០២/០២ នឹងក្លាយ ជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ទោះបីសហព្រះរាជអាជ្ញា និង នួន ជា មិនយល់ស្របគ្នាថាតើ បទចោទអ្វីខ្លះ ដែលគួរដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីឲ្យមានភាពជាតំណាងគ្រប់គ្រាន់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏ការស្នើសុំឲ្យបញ្ចូលបទចោទបន្ថែម

---

[198] *សូមមើលខាងលើ* កថាខណ្ឌ ៤៣។

[199] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៣។

[200] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៧-៥០។

[201] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៣ (បង្ហាញថា "មន្ទិលសង្ស័យថា ការព្យាករណ៍សម្រាប់ការជំនុំជម្រះនាពេលអនាគត នឹងអាចក្លាយជាគំរោងយ៉ាងមានន័យដែរ ឬយ៉ាងណា")។ *សូមមើលផងដែរ* សេចក្តីសម្រេចរងការជំទាស់, កថាខណ្ឌ ១៥៤ ដល់ ១៥៥។

ទាំងនោះ ពុំបានលើកឡើងអំពីការពង្រីកយ៉ាងធំធេងទេ។ ដូច្នេះ ការខ្វែងយោបល់គ្នា មិនមែនជាមូលដ្ឋានសម្រាប់ច្រានចោលជំហររបស់ភាគីលើបញ្ហានេះទេ ប៉ុន្តែផ្ទុយមកវិញ វាជាហេតុផលមួយដែលត្រូវយកជំហររបស់ភាគីទាំងពីរនេះមកអនុវត្តរួមគ្នា។ សំណួរដែលសួរថាតើ ធ្វើយ៉ាងណាឲ្យវិសាលភាពនៃសំណុំរឿង ០០២/០១ មានភាពជាតំណាងសមស្របតាមដីការបញ្ជូនរឿងទៅជំនុំជម្រះ គឺជាសំណួរមួយដែលអង្គជំនុំជម្រះសាលាដំបូងទេ ដែលមានលទ្ធភាព និងមធ្យោបាយ ដើម្បីឆ្លើយតបឲ្យបានជាទីពេញចិត្តដល់គ្រប់ភាគីទាំងអស់ ដែលបានបញ្ចេញនូវទស្សនៈលើបញ្ហានេះ ពោលគឺរួមបញ្ចូលយ៉ាងហោចណាស់អង្គហេតុមន្ទីរ ស-២១ តាមការចង់បានរបស់សហព្រះរាជអាជ្ញា ក៏ដូចជាអង្គហេតុប្រល័យពូជសាសន៍ សហករណ៍ និងការដ្ឋានការងារ ដែលជាការចង់បានរបស់ នួន ជា[202]។ ការបញ្ចូលអង្គហេតុ និងបទចោទទាំងនេះមិនត្រឹមតែឆ្លើយតបទៅនឹងជំហររបស់ភាគីនីមួយៗ ចំពោះចំណោទបញ្ហា ថាតើធ្វើយ៉ាងណាឲ្យវិសាលភាពនៃសំណុំរឿង ០០២/០១ មានភាពជាតំណាងសមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះទេ ប៉ុន្តែជាសត្យានុម័ត បំពេញបានលក្ខខណ្ឌនានាខាងលើ ដែលចាំបាច់ត្រូវយកមកពិចារណានៅពេលសម្រេច ថាតើ ត្រូវកាត់បន្ថយបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ យ៉ាងដូចម្ដេចខណៈពេលដែលត្រូវរក្សានូវលក្ខណៈវិនិច្ឆ័យសមហេតុផលនៃភាពជាតំណាងនេះ[203]។ ជាពិសេស ដីកាដំណោះស្រាយ បានចោទប្រកាន់ជនជាប់ចោទនូវបទចោទដូចខាងក្រោម:

ក. បទប្រល័យពូជសាសន៍ (ការសម្លាប់ប្រជាជន ដែលជាក្រុមជនជាតិចាម និងជនជាតិវៀតណាម)[204],

ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុកបុកម្នេញ (ខាងផ្នែកនយោបាយ សាសនា ឬពូជសាសន៍) អំពើរំលោភផ្លូវភេទ(នៅក្នុងមន្ទីរសន្តិសុខ និងសហករណ៍ និងនៅក្នុង

---

[202] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដោយហេតុថា សេចក្ដីសម្រេចបច្ចុប្បន្ន ចងកាតព្វកិច្ច និងប៉ះពាល់ដល់សិទ្ធិរបស់ ខៀវ សំផន ដូចនេះ គាត់មានឱកាសធ្វើបណ្ដឹងសាទុក្ខលើសេចក្ដីសម្រេចដែលរងការជំទាស់ និងដាក់សារណាទាក់ទងនឹងបញ្ហានេះ ប៉ុន្តែពុំបានជ្រើសរើសធ្វើដូច្នោះ។

[203] *សូមមើល* កថាខណ្ឌ ៦២ *យោងលើ* (i) បទឧក្រិដ្ឋដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ii) ការកំណត់ និងប្រភេទនៃបទឧក្រិដ្ឋ; (iii) ទីកន្លែង ដែលបទឧក្រិដ្ឋត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត (iv) ទំហំនៃឧក្រិដ្ឋកម្ម; (v) ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់; (vi) អំឡុងពេលនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់; និង, (vii) ប្រភេទជាមូលដ្ឋាននៃសំណុំរឿង។

[204] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៣៦ ដល់ ១៣៤៩។

បរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) អំពើអមនុស្សធម៌ដទៃទៀត(តាមរយៈ"ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស" អាពាហ៍ពិពាហ៍ដោយបង្ខំ ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ)[205] និង

គ. ការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិសញ្ញាទីក្រុងហ្សឺណែវ(ការរំលោភយ៉ាងធ្ងន់ធ្ងរ) (មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម កាប្រព្រឹត្តដោយអមនុស្សធម៌ ការបង្ករដោយចេតនានូវការឈឺចាប់យ៉ាងខ្លាំង ឬការរបួសយ៉ាងធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិលក្នុងការទទួលបានការជំនុំជម្រះប្រកបដោយ យុត្តិធម៌ និងទៀតទាត់ ការនិរទេសដោយខុសច្បាប់នូវជនស៊ីវិល ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់)[206]។

71. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បទចោទដែលមាននៅក្នុងវិសាលភាពនៃ សំណុំរឿង ០០២/០១ ដែលរួមមាន ដំណាក់កាលទី ១ ដំណាក់កាលទី ២ និងទួលពោធិ៍ជ្រៃ ជារួមទាក់ទងតែទៅលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិមួយចំនួន ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដូចតទៅ: អំពើមនុស្សឃាត[207] ការសម្លាប់រង្គាល[208] ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ[209] ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា[210] អំពើអមនុស្សធម៌ដទៃទៀត តាមរយៈ"ការវាយប្រហារលើសេចក្តីថ្លៃថ្នូរ"[211] និងអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ[212]។ អំពើប្រល័យពូជសាសន៍(ការសម្លាប់ប្រជាជនដែលជាក្រុមជនជាតិចាម និងជនជាតិវៀតណាម) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(ការធ្វើឱ្យទៅជាទាសករ ការនិរទេសខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងពូជសាសន៍ ការរំលោភផ្លូវភេទ អំពើអមនុស្សធម៌ដទៃទៀត តាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើអមនុស្សធម៌ដទៃទៀត តាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ) និងការរំលោភដ៏ធ្ងន់ធ្ងរ(មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តដោយអមនុស្សធម៌ ការបង្ករឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការធ្វើឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរលើ

[205] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៥០ ដល់ ១៤៧៨។

[206] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧៩ ដល់ ១៥២០។

[207] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៧៥, ១៣៧៧(ទួលពោធិ៍ជ្រៃ និងដំណាក់កាលទី ១)។

[208] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១, ១៣៨៧, ១៣៨៩ (ទួលពោធិ៍ជ្រៃ, ដំណាក់កាលទី ១ និងដំណាក់កាលទី ២)។

[209] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦-១៤១៨ (ទួលពោធិ៍ជ្រៃ, ដំណាក់កាលទី ១, និងដំណាក់កាលទី ២)។

[210] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២០ (ដំណាក់កាលទី ២)។

[211] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣៦ (ដំណាក់កាលទី ១ និងដំណាក់កាលទី ២)។

[212] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៤៨ (ដំណាក់កាលទី ១ និងដំណាក់កាលទី ២)។

រូបកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិល ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងទៀតទាត់ ការនិរទេសដោយខុសច្បាប់នូវជនស៊ីវិល ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់) បទចោទទាំងនេះ ត្រូវបានដកចេញទាំងស្រុងពីវិសាលភាពនៃសំណុំរឿង ០០២/០១ ។ ការពិនិត្យឡើងវិញលើដីកាដំណោះស្រាយបង្ហាញថា វិសាលភាពពេញលេញនៃបទចោទដែលបានចោទប្រកាន់នៅក្នុងដីកានេះ នឹងអាចធ្វើជាតំណាងយ៉ាងសមហេតុផល នៅពេលរួមបញ្ចូលបន្ថែមពីលើដំណាក់កាលទី ១, ដំណាក់កាលទី ២ និងទួលពោធិ៍ជ្រៃ បទប្រល័យពូជសាសន៍[213] ស-២១[214] ការដ្ឋានធ្វើការព្រៃ ស[215] និងសហករណ៍ត្រាំកក់[216] ទៅក្នុងវិសាល ភាពនៃសំណុំរឿង ០០២/០១ នោះ។

---

[213] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៦-១៣៤៩ (បទប្រល័យពូជសាសន៍ (ការសម្លាប់ប្រជាជនដែលជាជនជាតិចាម និងជនជាតិវៀតណាម)។

[214] ការបញ្ចូល ស-២១ នឹងអាចបញ្ចូលបទចោទនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(ការធ្វើឱ្យទៅជាទាសករ(*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩១); ការដាក់ក្នុងមន្ទីរឃុំឃាំង (*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០២); ការធ្វើទារុណកម្ម (*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៨); ការធ្វើទុក្ខបុកម្នេញខាងពូជសាសន៍ (*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២២ និង ១៤២៤); ការរំលោភផ្លូវភេទ (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៦)), និង ការរំលោភយ៉ាងធ្ងន់ធ្ងរ (មនុស្សឃាតដោយចេតនា (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៩១-១៤៩៣); ការធ្វើទារុណកម្ម (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៩៨-១៥០០); ការប្រព្រឹត្តដាក់ដោយអំពើអមនុស្សធម៌(*សូមមើល* ដីកាដំណោះស្រាយកថាខណ្ឌ ១៥០១-១៥០៣); ការបង្ករឱ្យមានការឈឺចាប់យ៉ាងខ្លាំងដោយចេតនា ឬការរងរបួសយ៉ាងធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៥០៤-១៥០៦); ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងទៀតទាត់ (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៥០៧-១៥១០); ការនិរទេសដោយខុសច្បាប់នូវជនស៊ីវិល(សូមមើលដីកាដំណោះស្រាយកថាខណ្ឌ ១៥១៥-១៥១៧); ការឃុំឃាំងលើជនស៊ីវិលដោយខុសច្បាប់ (*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ ១៥១៨-១៥១៩))។

[215] ការពណ៌នាអំពីទីតាំង ការបង្កើត មុខងារ ការសួរចម្លើយ និងសន្តិសុខនៅការដ្ឋានធ្វើការព្រៃ ស – ការដ្ឋានធ្វើការ ស ២១ – ត្រូវបានលើកឡើងក្នុងកថាខណ្ឌ ៤០០ ដល់ ៤១៤ នៃដីកាដំណោះស្រាយ។ ការបញ្ចូលការដ្ឋានធ្វើការព្រៃ ស នឹងរួមបញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: ការធ្វើឱទៅជាទាសករ (*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩១); ការដាក់ក្នុងមន្ទីរឃុំឃាំង (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០២, ១៤០៥); និងទារុណកម្ម (*សូមមើល* ដីកាដំណោះស្រាយកថាខណ្ឌ ១៤០៨)។

[216] ការពណ៌នាអំពីទីតាំង ការបង្កើត មុខងារ សន្តិសុខ និងការប្រព្រឹត្តដាក់ក្រុមជាក់លាក់នៅសហករណ៍ត្រាំកក់ មានលើកឡើងក្នុងកថាខណ្ឌ ៣០២ ដល់ ៣២២ នៃដីកាដំណោះស្រាយ។ ការបញ្ចូលនូវសហករណ៍ត្រាំកក់ នឹងរួមបញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ: ការធ្វើឱ្យទៅជាទាសករ (*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩១, ១៣៩៣); ការនិរទេស (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧); ការដាក់ក្នុងមន្ទីរឃុំឃាំង (*សូមមើល* ដីកាដំណោះស្រាយកថាខណ្ឌ ១៤០២ និង ១៤០៥); ការធ្វើទារុណកម្ម(*សូមមើល*ដីកាដំណោះស្រាយ កថាខណ្ឌ១៤០៨); ការធ្វើទុកបុកម្នេញខាងផ្នែកសាសនា (*សូមមើល*

72. សំណុំរឿង ០០២/០២ ត្រូវតែចាប់ផ្តើមឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន បន្ទាប់ពីបញ្ចប់សារណាបិទការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលសូមរំលឹកឡើងវិញថា អ.វ.ត.ក. ស្ថិតនៅក្រោមកាតព្វកិច្ចយ៉ាងម៉ឺងម៉ាត់ ក្នុងការធានាថាកិច្ចដំណើរការនីតិវិធីរបស់ខ្លួនប្រព្រឹត្តទៅក្នុងពេលវេលាសមរម្យ[217] និងធានាថា អ.វ.ត.ក. ចាំបាច់ត្រូវតែប្រើប្រាស់ថ្ងៃធ្វើការដែលមានឲ្យបានហ្មត់ចត់ ដើម្បីធានាសម្រេចឲ្យអស់នូវបទចោទទាំងឡាយ ដែលនៅសេសសល់ឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន[218]។ លើសពីនេះទៀត បន្ទាប់ពីបានរកឃើញថា សេចក្តីសម្រេចដែលរងការជំទាស់នេះ បណ្តាលឱ្យមាន *តាមព្រឹត្តហេតុ* ការផ្អាកនូវកិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទចោទទាំងអស់ដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នោះ[219] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ស្ថានភាពបែបនេះ អាចតម្រូវឱ្យមានការបន្តឃុំខ្លួនជនជាប់ចោទទាក់ទងនឹងបទចោទទាំងនោះដែលពុំអាចធ្វើយុត្តិកម្មបាន[220]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវគំរោងសម្រាប់ធ្វើកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ដោយកំណត់ថានឹងស្នើសុំយោបល់ភាគីលើកិច្ចដំណើរការនីតិវិធី ទាក់ទងទៅនឹងបទចោទនានាដែលនៅសេសសល់នៅក្នុងសំណុំរឿង ០០២[221]។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការនេះបានបញ្ចប់ ការជំនុំជម្រះជាក់ស្តែងលើបទចោទដែលនៅសេសសល់ នឹងត្រូវចាប់ផ្តើមឱ្យបានឆាប់រហ័ស ដែលនឹងអាចធ្វើឱ្យវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០០២ ដែលបានបញ្ចូលគ្នានេះ ក្លាយជាតំណាងដ៏សមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

73. អង្គជំនុំជម្រះតុលាការកំពូលរំលឹកនូវក្តីបារម្ភរបស់ខ្លួនពីដំបូងថា "ក្រុមប្រឹក្សាជំនុំជម្រះតែឯកឯងពុំអាចបំពេញនូវកាតព្វកិច្ចរបស់ អ.វ.ត.ក ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបទចោទទាំងមូលនៅក្នុង

---

ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២២); ការរំលោភផ្លូវភេទ (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៦ និង ១៤២៨); អំពើអមនុស្សធម៌ដទៃទៀតតាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំ (*សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៤២); អំពើអមនុស្សធម៌ដទៃទៀត តាមរយៈការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ (*សូមមើល*ដីកាដំណោះស្រាយកថាខណ្ឌ ១៤៧០)។

[217] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៤៧ *យោងទៅលើ*វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[218] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៥១។

[219] *សូមមើលខាងលើ* កថាខណ្ឌ ២៦។

[220] *សូមមើល* សេចក្តីសម្រេចស្តីពីការឃុំខ្លួនរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៩។

[221] អនុស្សរណៈរបស់ចៅក្រម និល នុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ក្នុងសំណុំរឿង ០០២/០២",ឯកសារលេខ E301, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងពេលវេលាសមហេតុផលបាននោះទេ”[222] ហើយថា “នៅក្នុងស្ថានភាពនៃការបន្តបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ... អ.វ.ត.ក គប្បីស្វែងរកការបង្កើតនូវក្រុមប្រឹក្សាជំនុំជម្រះមួយផ្សេងទៀតក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីគាំទ្រដល់ការជំនុំជម្រះទាន់ពេលទៅលើបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២”[223]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងបន្ថែមថា “ក្រុមប្រឹក្សាជំនុំជម្រះទីពីរនេះ អាចនឹងចាប់ផ្តើមភ្លាមៗផងដែរ ក្នុងការជំនុំជម្រះលើកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ទៀត ក្នុងខណៈដែលអង្គជំនុំជម្រះសាលាដំបូង កំពុងជាប់រវល់ជាមួយនឹងការព្រៀងនៃសាលក្រមនៃការជំនុំជម្រះលើកទីមួយ និងធានាបានថា ភាគីពុំត្រូវបានទុកឱ្យនៅទំនេរ ក្នុងអំឡុងពេលនេះ”[224]។

74. ដោយមានការព្យាករណ៍យ៉ាងជាក់ច្បាស់របស់អង្គជំនុំជម្រះសាលាដំបូងអំពីពេលវេលា ដែលមានរយៈពេលយ៉ាងតិចប្រាំបីខែក្នុងការចេញនូវសាលក្រមក្នុងសំណុំរឿង ០០២/០១[225] និងដោយបានធ្វើការពិចារណាយ៉ាងច្បាស់លាស់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបង្កើតនូវក្រុមប្រឹក្សាជំនុំជម្រះទីពីរ មកដល់ពេលនេះ នៅតែចាំបាច់។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ពុំមានឧបសគ្គរាំង ក្នុងការកោះអញ្ជើញចៅក្រមសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទីពីរ នៅក្នុងអង្គជំនុំជម្រះសាលាដំបូងឡើយ នៅពេលដែលភាពចាំបាច់នៃអត្ថប្រយោជន៍យុត្តិធម៌ តម្រូវនោះ។ ស្របតាមកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក, “ប្រធានអង្គជំនុំជម្រះ តាមករណីជាក់ស្តែង អាចចាត់តាំងចៅក្រមបំរុងមួយរូប ឬច្រើនរូប ចេញពីបញ្ជីឈ្មោះបេក្ខជនដែលបានដាក់ជូនដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដើម្បីចូលរួមនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី និងជំនួសចៅក្រមអន្តរជាតិណាម្នាក់ នៅពេលដែលចៅក្រមរូបនោះ ពុំអាចបន្តធ្វើការជំនុំជម្រះបានតទៅទៀត”[226]។ ការចាត់តាំងចៅក្រមជាតិ ដែលទាំងរួមបញ្ចូលចៅក្រមបំរុង “នៅពេលដែលចាំបាច់នោះ” ក៏មានចែងនៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ផងដែរ[227]។ បញ្ញត្តិទាំងនេះដែលកំណត់ពីតួនាទីរបស់ចៅក្រមនៅ អ.វ.ត.ក ត្រូវបានបកស្រាយក្នុងន័យធានានូវកិច្ចការរដ្ឋបាលតុលាការដ៏ល្អប្រសើរបំផុត នៅពេលដែលបន្ទុកការងារកើនឡើង បណ្តាលឱ្យចៅក្រម

---

[222] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥១។

[223] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥១។

[224] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥១។

[225] សេចក្តីសម្រេចដែលរងការជំទាស់ ជើងទំព័រ ២៧០។

[226] *សូមមើល* មាត្រា ៣(៨) នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក។ *សូមមើលផងដែរ* មាត្រា ១១ ថ្មី នៃច្បាប់របស់ អ.វ.ត.ក។

[227] *សូមមើល* មាត្រា ១១ ថ្មី នៃច្បាប់របស់ អ.វ.ត.ក។

"ពុំអាចបន្តជំនុំជម្រះបានតទៅទៀត" ទៅលើបញ្ហាដែលពុំទាន់បានសម្រេចទាំងអស់នោះ[228]។ ហេតុនេះ ពុំមានឧបសគ្គផ្នែកច្បាប់ណាកើតឡើង ក្នុងការឆ្លើយតបទៅនឹងភាពចាំបាច់ជាបន្ទាន់ សម្រាប់ដោះស្រាយលើបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២។ ពុំមានឧបសគ្គផ្នែកហិរញ្ញវត្ថុ ឬផ្នែករដ្ឋបាលណាមួយរារាំងដល់បញ្ហានេះទេ ដូចដែលការិយាល័យរដ្ឋបាលបានអះអាងបញ្ជាក់ នៅក្នុងការឆ្លើយតបទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល ដែលបង្គាប់ដល់ការិយាល័យរដ្ឋបាល ស្វែងរកការបង្កើតនូវក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដើម្បីស្តាប់ និងជំនុំជម្រះសំណុំរឿង ០០២/០២[229]។ ដូច្នេះ នេះជាការទទួលខុសត្រូវរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងការពិនិត្យលើលទ្ធភាពដែលមានស្រាប់ទាំងនេះ[230]។

75. អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការរំពឹងទុករបស់អង្គជំនុំជម្រះសាលាដំបូង លើបញ្ហាហិរញ្ញវត្ថុ ថាជាការពុំជាប់ពាក់ព័ន្ធ និងពុំសមស្របនៅក្នុងការធ្វើសេចក្តីសម្រេចនាពេលបច្ចុប្បន្ន។ ដោយហេតុថា ចៅក្រម នៅគ្រប់ពេលទាំងអស់ ជាក់ច្បាស់ណាស់ ត្រូវមានកាតព្វកិច្ចពិចារណាលើប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ដូច្នេះ ចៅក្រម ជានិច្ចកាលត្រូវអនុវត្តទៅតាមវិសាលភាពនៃច្បាប់ ដែលជាគោលការណ៍

---

[228] ជាឧទាហរណ៍ ក្នុងឆ្នាំ ២០១០ ដោយសារបន្ទុកការងារយ៉ាងធ្ងន់ធ្ងរនៅក្នុងអង្គបុរេជំនុំជម្រះ ប្រធានអង្គជំនុំជម្រះនេះ បានស្នើសុំចៅក្រមបំរុង ហើយបានជ្រើសតាំងចៅក្រមបំរុង (ពេលនោះ) ចៅក្រម Katinka LAHUIS ឱ្យបំពេញការងារពេញម៉ោងលើបណ្តឹងឧទ្ធរណ៍ ដែលពុំទាន់បានសម្រេចប្រឆាំងនឹងដីកាដំណោះស្រាយនាពេលនោះ ហើយដូច្នេះ បានបង្កើតនូវក្រុមប្រឹក្សាជំនុំជម្រះបន្ថែម ដើម្បីដោះស្រាយលើបណ្តឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័ស និងគោរពតាមកាលបរិច្ឆេទកំណត់។ *សូមមើល* អនុស្សរណៈរបស់ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ដែលមានចំណងជើងថា "ការជ្រើសតាំងចូលរួមនូវគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ឯកសារលេខ D427/1/30.1 ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០, អនុស្សរណៈរបស់ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ មានចំណងជើងថា "ការចាត់តាំងចៅក្រម Katinka Lahuis ដើម្បីជួយដល់អង្គបុរេជំនុំជម្រះ លើសំណុំរឿងដែលពុំទាន់បានសម្រេចមួយចំនួន", ឯសារលេខ D411/3/6.6, ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១។

[229] អនុស្សរណៈរបស់ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក Knut ROSANDHAUG, អនុប្រធានការិយាល័យរដ្ឋបាល មានចំណងជើងថា "ដីកាបង្គាប់របស់តុលាការទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ", ឯកសារលេខ E284/4/7/1/2, ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៣ ("ការិយាល័យរដ្ឋបាលបានពិនិត្យអំពីបញ្ហាហិរញ្ញវត្ថុ និងរដ្ឋបាល ស្តីពីការបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះសាលាដំបូង និងបានធ្វើការអះអាងនូវការត្រៀមខ្លួនរួចរាល់ ដើម្បីគាំទ្រដល់ការសម្រេចណាមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ឬអង្គជំនុំជម្រះសាលាដំបូង ក្នុងការបំពេញនូវកិច្ចនីតិវិធីរបស់តុលាការប្រកបដោយភាពត្រឹមត្រូវក្នុងសំណុំរឿង០០២"), *ការឆ្លើយតបទៅនឹង*ដីកាបង្គាប់ទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ឯកសារលេខ E284/4/7/1, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។

[230] *សូមមើល* អនុស្សរណៈរបស់លោក Knut ROSANDHAUG, អនុប្រធានការិយាល័យរដ្ឋបាល ទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ឯកសារលេខ E284/4/7/1/1, ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៣ ទំព័រ ២។

ដែលមានលក្ខណៈសំខាន់ជាងការសន្សំសំចៃផ្នែកថវិកា។ ដូចដែលបានពិភាក្សាខាងលើ[231] នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍ផ្នែកហិរញ្ញវត្ថុ អាចបង្កើតបានជាសមីការ និងជះឥទ្ធិពលដល់វិសាលភាពនៃបទចោទជាបីផ្នែក: តាមរយៈសេចក្តីសម្រេចរបស់អង្គនីតិបញ្ញត្តិ ដែលកំណត់ទ្រង់ទ្រាយនូវយុត្តាធិការលើអង្គហេតុ និងលើរូបបុគ្គល, តាមរយៈសេចក្តីសម្រេចរបស់អយ្យការ ដែលជំរុញឡើងដោយប្រសិទ្ធភាព លើរឿងក្តីដែលត្រូវចោទប្រកាន់, ហើយ ចុងក្រោយ តាមរយៈសេចក្តីសម្រេចដែលជំរុញឡើងដោយប្រសិទ្ធភាព ទៅលើការដកចេញ ឬការកាត់បន្ថយបទចោទ ដែលសេចក្តីសម្រេចនេះ ជាចាំបាច់ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ក្រៅពីករណីលើកលែងទាំងនេះ ចៅក្រមជំនុំជម្រះ មិនអាចកែប្រែការយល់ឃើញរបស់ខ្លួនអំពីបញ្ហា ដែលពុំទាន់បានសម្រេច ទៅតាមការសន្សំសំចៃផ្នែកថវិកាឡើយ។ វិបត្តិផ្នែកហិរញ្ញវត្ថុនៃ អ.វ.ត.ក ធ្វើឱ្យប៉ះពាល់ដល់ស្ថាប័នតុលាការទាំងមូល និងថា វិបត្តិនេះត្រូវតែបានដោះស្រាយ ឱ្យបានឆាប់រហ័សបំផុត ដោយការសន្យាផ្តល់យ៉ាងមុតមាំឥតកែប្រែរបស់ប្រទេសម្ចាស់ជំនួយ នូវការជួយឧបត្ថម្ភដោយស្ម័គ្រចិត្តរបស់ខ្លួន ឬដោយការកែប្រែដំណើរការផ្តល់ថវិកាដល់ អ.វ.ត.ក ទៅជាកញ្ចប់ថវិកាទៀងទាត់របស់អង្គការសហប្រជាជាតិ តាមរយៈថវិកាដែលត្រូវបានកំណត់ទុក ដើម្បីបំពេញនូវកិច្ចដំណើរការនីតិវិធី ប្រកបដោយប្រសិទ្ធភាព ក្នុងសំណុំរឿង ០០២ និងបញ្ហាដទៃទៀតបានត្រឹមត្រូវនៅចំពោះមុខ អ.វ.ត.ក។ ប្រសិនបើ ពុំមានថវិកាគ្រប់គ្រាន់ ក្នុងការធានានូវការជំនុំជម្រះដែលច្បាប់បានតម្រូវនោះទេ រាល់កិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក ត្រូវតែបញ្ចប់ ហើយតុលាការត្រូវបិទទ្វារ។ ដើម្បីរារាំងដល់បញ្ហានេះ កិច្ចដំណើរការនីតិវិធីត្រូវបន្ត ដោយពុំមានសេចក្តីសម្រេចណាមួយលើអង្គច្បាប់ និងអង្គហេតុ ត្រូវទទួលរងនូវឥទ្ធិពលដោយឥតសមស្របពីបញ្ហាហិរញ្ញវត្ថុឡើយ[232]។

[231] *សូមមើលខាងលើ* កថាខណ្ឌ ៦១ ដល់ ៦៤។

[232] *សូមមើលឧ.* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, *រឿងក្តី Salov ទល់នឹង Ukraine*, សាលក្រម, ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥, សំណើសុំលេខ 65518/01, កថាខណ្ឌ ៨៣, ៨៦។ *សូមមើលផងដែរ* Nuala Mole and Catharina Harby, *សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ការនាំទៅរកការអនុវត្តមាត្រា ៦ នៃសិទ្ធិសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* (អគ្គនាយកក្រុមប្រឹក្សានៃសិទ្ធិមនុស្ស, ក្រុមប្រឹក្សាអឺរ៉ុប: ឆ្នាំ ២០០១), ទំព័រ ៣៣-៣៤ ("ក្នុង*សំណុំរឿង Salov v. Ukraine*, ដែលជាប់ពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងម្ចាស់បណ្តឹង តុលាការពិនិត្យលើប្រវត្តិផ្នែកហិរញ្ញវត្ថុ និងផ្នែកតុលាការយ៉ាងទូលំទូលាយ ដោយចេញសេចក្តីសម្រេចអនុញ្ញាតឱ្យមានការប្តឹងតវ៉ាពីអយ្យការ និងការបង្វិលនៃរឿងក្តីរបស់ម្ចាស់បណ្តឹង។ នៅពេលធ្វើដូច្នោះ តុលាការបានកត់សម្គាល់លើសេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញរបស់ប្រទេស Ukrainian (Constitutional Court) ចាប់តាំងពីឆ្នាំ ១៩៩៩ ដែលសេចក្តីសម្រេចនេះ បានរកឃើញថា គណៈរដ្ឋមន្ត្រីបានអនុវត្តខុសរដ្ឋធម្មនុញ្ញ នៅពេលកាត់

## V. ផ្នែកសម្រេចសេចក្តី

76. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

**ទទួលយក**បណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៤(៤)(ក)នៃវិធានផ្ទៃក្នុង,

**បដិសេធ**បណ្តឹងសាទុក្ខលើអង្គសេចក្តី និង

**បង្គាប់**ថា សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ ត្រូវចាប់ផ្តើមក្នុងពេលឆាប់ៗដែលអាចធ្វើទៅបាន បន្ទាប់ពីសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល ក្នុងសំណុំរឿង ០០២/០១ និងថា សំណុំរឿង ០០២/០២ ត្រូវរួមបញ្ចូល ជាអប្បបរមា នូវបទចោទទាក់ទងនឹងមន្ទីរ ស-២១ ការដ្ឋានធ្វើការ សហករណ៍ និងអំពើប្រល័យពូជសាសន៍។

ភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

បន្ថយយ៉ាងច្រើននូវថវិកាជាតិសម្រាប់ប្រព័ន្ធតុលាការ, បញ្ហានេះត្រូវបានរកឃើញថាបានដាក់ឥទ្ធិពល ផ្នែកហិរញ្ញវត្ថុទៅលើតុលាការ និងបានរំលោភលើសិទ្ធិពលរដ្ឋក្នុងការទទួលបានការការពារពីតុលាការ")។